ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>
## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦**

**ម៉ោង ០៩:១១នាទី**

**សវនាការលើកទី៤៩៤**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Feb-2017, 11:03
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក ឌេល លីសាក់ *(Dale Lysak)*

លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផនៈ**

លោកស្រី ទូច វល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីៈ**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក ឡោ ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការៈ**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| សាក្សី 2-TCW-971 | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷** 2-TCW-971

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ................................................................. ទំព័រ ២៣

សួរដោយលោក នីកូឡាស គូមជែន ផ្តើមពី................................................................. ទំព័រ ៣៨

សួរដោយលោក ឡោ ជុនធី ផ្តើមពី......................................................................... ទំព័រ ៥៨

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........................................................... ទំព័រ ៦៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១១:១៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី 2-TCW-971 តាមប្រព័ន្ធសោតទស្សន៍ ពីខេត្តឧត្ដរមានជ័យ។ ហើយតែដោយសារមានបញ្ហាប្រព័ន្ធអ៊ីនធឺណែត និងការរៀបចំមិនទាន់រួចរាល់នោះ អង្គជំនុំជម្រះនឹងធ្វើសារណា -- ស្ដាប់សារណាផ្ទាល់មាត់របស់ភាគីលើបញ្ហាចំនួនពីរជាមុនសិន។

ហើយដំបូងនេះ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:១៣:០៨]

សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺមានរហស្សនាម 2-TCW-971។ សាក្សីនឹងផ្ដល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តឧត្ដរមានជ័យ។ សាក្សីមានមេធាវីប្រឹក្សា គឺលោក ម៉ម រិទ្ធា។ នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូប ដែលមានរហស្សនាម 2-TCW-1042។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សូមអរគុណលោកប្រធាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦។ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះជាប្រចាំ ហើយបើអង្គុយយូរ កាន់តែឈឺខ្លាំង និងផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

[០៩:១៥:00]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន១១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាដំបូងនេះ មុននឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-971 អង្គជំនុំជម្រះមានបំណងស្តាប់សារណាផ្ទាល់មាត់របស់ភាគី ទាក់ទងទៅនឹងបញ្ហាចំនួនពីរ។ ទី១ គឺសំណើសុំរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅសាក្សីបន្ថែមចំនួនពីររូប និងលទ្ធភាពនៃការធ្វើសវនាការបង្ហាញឯកសារគន្លឹះរបស់ភាគីពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ (ឯកសារ E452)។ និងបញ្ហាទី២ សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យទទួលឯកសារមួយ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង

(ឯកសារ E285/2)។ ភាគីទាំងអស់ត្រូវបានជូនដំណឹងតាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់កាលពីថ្ងៃម្សិលមិញ ដើម្បីត្រៀមខ្លួនធ្វើសារណាផ្ទាល់តបទៅនឹងសំណើទាំងពីរនេះ នៅថ្ងៃនេះ។ ឥឡូវនេះ អង្គជំនុំជម្រះនឹងស្ដាប់សារណាផ្ទាល់មាត់លើបញ្ហាទី១ ជាមុនសិន។

[០៩:១៦:៣០]

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានដាក់សំណើមួយ សុំឱ្យអង្គជំនុំជម្រះកោះហៅសាក្សីចំនួនពីររូបបន្ថែមទៀត ពាក់ព័ន្ធនឹងអង្គហេតុស្ដីពីតួនាទីរបស់ជនជាប់ចោទ អនុលោមតាមវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាបានអះអាងថា ដោយសារសាក្សីចំនួនពាក់កណ្ដាលនៃចំនួនសាក្សីសរុប១០រូបដែលខ្លួនបានស្នើសុំ មិនត្រូវបានកោះហៅឱ្យមកផ្ដល់សក្ខីកម្មលើប្រធានបទសវនាការស្ដីពីតួនាទីរបស់ជនជាប់ចោទ។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា សាក្សីនិងដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ក៏ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចដកចេញពីបញ្ជីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដោយសារមូលហេតុសុខភាព ឬមូលហេតុផ្សេងៗទៀត។ សហព្រះរាជអាជ្ញាក៏បានបញ្ជាក់ថា ខ្លួនពុំមានបំណងបង្ហាញឯកសារគន្លឹះនៅក្នុងសវនាការនៃការដាក់បង្ហាញឯកសារគន្លឹះស្ដីពីតួនាទីរបស់ជនជាប់ចោទនោះទេ។ ហេតុដូច្នេះហើយ បានជាជំនួសមកវិញ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាកោះហៅបុគ្គលទាំងពីរឱ្យមកផ្ដល់សក្ខីកម្មក្នុងឋានៈសាក្សី ដែលទំនងជាមិនចំណាយពេលវេលាលើសពីមួយថ្ងៃនៃសវនាការសម្រាប់សាក្សីនីមួយៗឡើយ។

ហើយដើម្បីឱ្យអង្គជំនុំជម្រះនឹងអាចយល់បានកាន់តែច្បាស់ អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីបញ្ជាក់ពីមូលហេតុនៃសំណើសុំរបស់ខ្លួនឱ្យច្បាស់លាស់ រួមទាំងលទ្ធភាពនៃការដាក់បង្ហាញឯកសារគន្លឹះស្ដីពីតួនាទីរបស់ជនជាប់ចោទផង។ សូមអញ្ជើញ!

[០៩:១៨:១៧]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ ខ្ញុំមិនមានអ្វីបន្ថែមលើសពីសារណារបស់យើងនោះឡើយ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ដោយសង្ខេបថា ជាការល្អ ប្រសិនបើអាចប្រើប្រាស់ពេលវេលារបស់យើងខ្ញុំដើម្បីស្ដាប់សាក្សីបន្ថែមទាំងពីរនេះ ព្រោះថាពួកគាត់ប្រហែលជាមានសក្ខីកម្មខ្លីនោះទេ ដោយសារតែគាត់មានការទំនាក់ទំនងជាមួយ ខៀវ សំផន។

ហើយចំពោះសវនាការលើឯកសារ យើងនឹងធ្វើការឆ្លើយតបទៅលើសារណារបស់ភាគី របស់មេធាវីការពារក្ដីប៉ុណ្ណោះ។ ហើយខ្ញុំគិតថា នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោល ទើបយើងខ្ញុំនឹងនិយាយលម្អិត។ ដូច្នេះខ្ញុំគិតថា ចំពោះសវនាការលើឯកសារគន្លឹះ គឺយើងខ្ញុំគិតថា វាហាក់ដូចជាការច្រំដែល ឬក៏ជាន់គ្នា។ ហេតុដូច្នេះខ្ញុំសូមបញ្ចប់នូវសារណាដោយសង្ខេបរបស់យើងខ្ញុំ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២០:៥៤]

**ប្រធានអង្គជំនុំ៖**

ជាគោលការណ៍ ឥឡូវថាឲ្យទៅភាគីដទៃទៀត ព្រោះខ្ញុំដូចអត់ច្បាស់ខ្លួនឯង។ ឥឡូវសូមព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់បន្តិចមើល។ យើង បញ្ហាអីចេះ យើងស្ដាប់ភាគីនេះ ក្នុងបំណងរៀបចំនូវកាលវិភាគសវនាការសម្រាប់ដើមឆ្នាំ ដើមខែមករា ២០១៧ ដើម្បីឲ្យយើង ថាអីចឹង តើយើងត្រូវរៀបចំកាលវិភាគសវនាការយ៉ាងដូចម្ដេច ប្រសិនបើភាគីមិនមានបំណង ឬក៏គ្មានឯកសារដាក់បង្ហាញ គន្លឹះដាក់បង្ហាញទេនោះ អង្គជំនុំជម្រះនឹងរៀបចំកាលវិភាគសវនាការហ្នឹង ជំនួសទៅការធ្វើសវនាការផ្សេងៗទៀតចាំបាច់ ដើម្បីជំរុញល្បឿនកិច្ចដំណើរការនីតិវិធីសវនាការឲ្យបានឆាប់រហ័ស តាមគម្រោងផែនការដែលបានគ្រោងទុក។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ។ ខ្ញុំសូមទោស ដែលខ្ញុំបញ្ជាក់មិនបានច្បាស់។ ប្រសិនបើភាគីដទៃទៀត គាត់បង្ហាញឯកសារ យើងខ្ញុំនឹងឆ្លើយតប។ ប៉ុន្តែប្រសិនបើមិនមានភាគីណាផ្សេងបង្ហាញឯកសារទេ ខាងព្រះរាជអាជ្ញាគិតថា មិនគួរមានសវនាការលើឯកសារគន្លឹះនោះឡើយ។ ហើយទុកឲ្យអង្គជំនុំជម្រះសម្រេច ថាតើធ្វើសារណាទៅលើស្ទីផ្សេងដែលចាំបាច់។ ដូច្នេះចំពោះយើងខ្ញុំ គឺយើងខ្ញុំគិតថា សវនាការលើឯកសារគន្លឹះ ជារឿងមិនចាំបាច់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ឆ្លើយតបទាំងពីរណ៎ា! ទាំងការបង្ហាញឯកសារផង ទាំងលទ្ធភាពនៃការដាក់បង្ហាញឯកសារគន្លឹះផង។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគី។ ចំពោះបញ្ហាទី១ ពាក់ព័ន្ធទៅ

នឹងការស្នើឲ្យមានសក្ខីកម្មសាក្សីថ្មីពីររូប ខាងមេធាវីនាំមុខ មិនមានការជំទាស់ទេ ហើយទុកជូនលោក លោកស្រីចៅក្រមជាអ្នកសម្រេចអំពីបញ្ហានេះ។ ចំពោះបញ្ហាទី២ ការបង្ហាញឯកសារគន្លឹះ មេធាវីនាំមុខ មិនមានអ្វីនឹងបង្ហាញទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។ យើងសម្រេចថា ឲ្យមេធាវីការពារក្តី ខៀវ សំផន គាត់ឆ្លើយមុន ព្រោះសាក្សីពីររូបហ្នឹង ទាក់ទងទៅនឹង ខៀវ សំផន។ ហើយខាងការពារក្តី នួន ជា នឹងធ្វើការឆ្លើយតប ក្រោយពេលមេធាវីការពារក្តី ខៀវ សំផន។ សូមលោកប្រធានអនុញ្ញាត។

[០៩:២៣:៣៦]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខាងមេធាវីការពារក្តី ខៀវ សំផន យើងមានការកត់សម្គាល់មួយចំនួន ឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា។ យើង គឺយើងជំទាស់ទៅនឹងសំណើដែលដាក់ពេលប្រថុចប្រញ៉ុចបែបនេះ។ យើងគិតថា យើងមិនធ្វើឲ្យអ្នកណាម្នាក់ភ្ញាក់ផ្អើលនោះទេ ដោយសារថា អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរួចមកហើយនៅក្នុងឯកសារ ក្នុងក្របខ័ណ្ឌនៃវិធាន៨៧(៤)។ សហព្រះរាជអាជ្ញា បានដាក់ឯកសារនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ គឺសល់តែប៉ុន្មានថ្ងៃទៀតហ្នឹង យើងជិតចប់សវនាការទៅហើយ។

ខ្ញុំសូមយោងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកាលពីថ្មីៗនេះ ជាពិសេស គឺឯកសារ E421/4 ដែលចុះថ្ងៃទី -- សុំទោសគឺ E421 គឺចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៦ <ដែលជាអនុស្សរណៈដែលត្រូវបានធ្វើសេចក្តីព្រាងឡើងចេញពីគោលការណ៍ ដែលលោកចៅក្រមបានបញ្ជាក់ក្រោមលក្ខខណ្ឌនៃវិធាន៨៧(៤) ដែលភាគីតែងតែលើកឡើងជាញឹកញាប់>។ ខ្ញុំគិតថា យើងគួរតែបញ្ជាក់ឲ្យបានច្បាស់នូវអ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចមកហើយ គឺឯកសារ E421/4។ ខ្ញុំសូមរំឭកជាគោលការណ៍ថា អង្គជំនុំជម្រះបានរំឭកនូវកថាខណ្ឌ១៥នៃឯកសារនេះ។ ខ្ញុំសូមដកស្រង់៖ "អង្គជំនុំជម្រះយល់ឃើញថា ភាគីនានា រួមទាំងសហព្រះរាជអាជ្ញាមានឱកាសគ្រប់គ្រាន់ក្នុងការ<ទទួលបាន>ភស្តុតាងក្នុងអំឡុងពេលស៊ើបអង្កេត៣ឆ្នាំ និងក្នុងអំឡុងសវនាការក្នុងសំណុំរឿង០០២/០១ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ និង

ក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នពីខែតុលា ឆ្នាំ២០១៤ រហូតដល់ពេលបច្ចុប្បន្ននេះ។” ដូច្នេះនេះ<ជាគំនិតមួយ។ នៅពេលមួយនោះ គឺ>កាលពីខែសីហា ឆ្នាំ២០១៦ ពេលនុំងគឺថាភស្តុតាងថ្មី គឺ<នៅពេលដែលយើងរវល់នៅក្នុងសវនាការជាច្រើនខែ ឆ្នាំរួចទៅហើយ>។

អ៊ីចឹងខ្ញុំសូមយោងទៅលើកថាខណ្ឌមួយទៀត គឺកថាខណ្ឌ១៧ នៃឯកសារដដែលនេះ។ “ទោះជាយ៉ាងនេះក្តី ប្រសិនបើភស្តុតាងថ្មីត្រូវបានរកឃើញពីសំណុំរឿង០០៣ និង០០៤ <ត្រូវតែបញ្ចេញឲ្យដឹង>នៅពេលវេលាមួយ<ក្នុងពេលជំនុំជម្រះ> ដែលមិនអាច<ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ>បាន ពេលនោះសហព្រះរាជអាជ្ញានឹងមានឱកាសប្តឹងសាទុក្ខ ស្នើសុំឲ្យធ្វើការពិចារណាទៅលើភស្តុតាងបែបនេះ ប្រសិនបើសហព្រះរាជអាជ្ញាយល់ឃើញថា ភស្តុតាងនេះអាចជាកត្តាសម្រេចនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះ។” សូមបញ្ចប់ការដកស្រង់នៃកថាខណ្ឌ១៧។

[០៩:២៦:៤៩]

ហើយខ្ញុំចង់សង្កត់ធ្ងន់ទៅលើកថាខណ្ឌ១៩នៃអនុស្សរណៈនេះដដែល។ គឺ “ទោះ<មានការលើកលែងចំពោះកាលបរិច្ឆេទកំណត់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦>ជាយ៉ាងនេះក្តី អង្គជំនុំជម្រះ<នឹងពិចារណាសំណើសុំរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ដើម្បីទទួលយកភស្តុតាងថ្មី ដែល <គេស្វែងរក ដើម្បីច្រានចោល>ភស្តុតាងដោះបន្ទុកថ្មីៗរបស់មេធាវីការពារក្តី ដែលត្រូវបានទទួលដោយអង្គជំនុំជម្រះក្រោយកាលបរិច្ឆេទកំណត់នេះ។” ក្នុងកថាខណ្ឌ២១ សន្និដ្ឋានថា “វាជាការយល់ឃើញរបស់អង្គជំនុំជម្រះចំពោះកាលបរិច្ឆេទកំណត់ខាងលើបានថ្លឹងថ្លែងយ៉ាងសមស្របចំពោះសិទ្ធិរបស់ភាគីទៅនឹងតម្រូវការ<ក្នុងការនាំយកសំណុំរឿងទី២នេះ>ដើម្បីបញ្ចប់ក្នុងពេលវេលាសមរម្យមួយ។”>

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវីការពារក្តីបន្ថយល្បឿនតិច គាត់និយាយលឿនណាស់។

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវីការពារក្តីគាត់ចាប់ផ្តើមអានកថាខណ្ឌ២១ ឡើងវិញ។

**ប្រធានអង្គជំនុំ៖**

បាត់ៗការបកប្រែ បកប្រែអត់បានទេ។ សូមអាននូវកថាខណ្ឌចុងក្រោយអំមិញម្តងទៀត ព្រោះ

អ្នកបកប្រែបកអត់បានទេ អត់ទាន់ទេ។

**កញ្ញា អង់តា ហ្គិសសេះ**

លោកប្រធានសូមអភ័យទោស គឺថានៅពេលដែលខ្ញុំអានទៅ ខ្ញុំតែងតែភ្លេចខ្លួន ហើយនិយាយលឿន។ ខ្ញុំសូមបញ្ជាក់ចំពោះអ្នកបកប្រែថា យើងបានប្រាប់ហើយថា យើងនឹងប្រើប្រាស់អនុស្សរណៈ E421/4 អ៊ីចឹងខ្ញុំគិតថាអ្នកបកប្រែអាចតាមខ្ញុំទាន់ ហើយខ្ញុំនឹងដកស្រង់នូវសេចក្ដីសន្និដ្ឋាននៃកថាខណ្ឌ ២១។ ខ្ញុំសូមដកស្រង់៖ "ដោយយោងទៅលើចំណុចទាំងអស់ខាងលើ អង្គជំនុំជម្រះយល់ឃើញថា កាលបរិច្ឆេទកំណត់ខាងលើបានថ្លឹងថ្លែងយ៉ាងសមស្រប អំពីសិទ្ធិរបស់ភាគីផ្សេងៗជាមួយនឹងតម្រូវការក្នុងការបញ្ចប់សំណុំរឿងនេះក្នុងពេលវេលាមួយសមស្រប។" សូមបញ្ចប់ការដកស្រង់។

ខ្ញុំសូមរំឭកថា នៅក្នុងអនុស្សរណៈនេះ អង្គជំនុំជម្រះបានបញ្ជាក់ថា សហព្រះរាជអាជ្ញាមានពេលរហូតទៅដល់ថ្ងៃទី០១ កញ្ញា ឆ្នាំ២០១៦ ដើម្បីបញ្ជាក់ ទី១ អំពីភស្តុតាងដែលខ្លួនចង់ឲ្យអង្គជំនុំជម្រះទទួលយកភស្តុតាង ហើយនិងបញ្ជាក់អំពីសាក្សីដែលខ្លួនចង់ឲ្យអង្គជំនុំជម្រះកោះហៅឲ្យមកផ្ដល់សក្ខីកម្ម។ ដូច្នេះគឺថា សហព្រះរាជអាជ្ញាមានពេលត្រឹមតែថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ តែប៉ុណ្ណោះ។ នៅក្នុងអនុស្សរណៈនេះអង្គជំនុំជម្រះបានរំឭកថា យើងមិនអាចបន្តធ្វើការស៊ើបអង្កេតនៅក្នុងពេលជំនុំជម្រះក្ដីនោះទេ ដូច្នេះសហព្រះរាជអាជ្ញាបានដាក់សំណើយឺតពេលទៅហើយ ហើយគាត់ផ្អែកទៅលើទឡ្ហីករណ៍ដែលមិនសមរម្យ។ ខ្ញុំនិយាយបែបនេះ ពីព្រោះថា ការកំណត់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦នេះត្រូវបានកំណត់រួចទៅហើយ មុនពេលដែលអង្គជំនុំជម្រះបានផ្ដល់បញ្ជីសាក្សីជាយថាហេតុ ដែលខ្លួនចង់កោះហៅមកផ្ដល់សក្ខីកម្មពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ។

[០៩:៣០:១៥]

ខ្ញុំសូមបញ្ជាក់ថា បញ្ជីសាក្សី១០រូប ដែលអង្គជំនុំជម្រះកំណត់ដើម្បីកោះហៅសាក្សីមកហ្នឹង គឺបានផ្ដល់នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ប្រសិនបើសហព្រះរាជអាជ្ញាចង់កោះហៅសាក្សីទាំងពីរដែលខ្លួនស្នើសុំនៅថ្ងៃនេះ គាត់មានពេលគ្រប់គ្រាន់ មានពេលច្រើនណាស់។ ដោយសារតែអនុស្សរណៈរបស់អង្គជំនុំជម្រះបានសម្រេចកំណត់ត្រឹមថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ រួចមកហើយ ហើយគាត់មិនបានធ្វើទេពេលនុ៎ង។ គាត់លើកទឡ្ហីករណ៍មិនត្រឹមត្រូវទៀត គឺខុសតែម្ដង។ គាត់ថា មានមនុស្សជាច្រើនដែលមិនបានមកផ្ដល់សក្ខីកម្ម ពិតមែន! ប៉ុន្តែគាត់ភ្លេចថា ក្នុងចំណោមសាក្សីទាំង១០រូប ដែលអង្គជំនុំជម្រះសម្រេចកោះហៅពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ គឺមានប្រាំបីនាក់ ដែលសហព្រះរាជអាជ្ញាបាន

ស្នើសុំ។ អ៊ីចឹងគាត់បានស្នើសុំប្រាំបីនាក់រួចមកហើយ។ ហើយក្នុងចំណោមអ្នកទាំង១០ ក្នុងចំណោមប្រាំបីនាក់ដែលសហព្រះរាជអាជ្ញាស្នើសុំនោះ គឺមានតែពីរនាក់តែប៉ុណ្ណោះដែលមិនបានមកផ្តល់សក្ខីកម្មនោះ គឺ 2-TCW-871 ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ដែលយើងដឹងមូលហេតុហើយថាម៉េចបានគាត់មិនផ្តល់សក្ខីកម្មនោះ។ ពាក់ព័ន្ធនឹងសាក្សី 2-TCW-871 ខ្ញុំសូមរំឭកថា អង្គជំនុំជម្រះបានសម្រេចជំនួសសាក្សីរូបនេះដោយសាក្សី <2-TCW-823 ដែលបានមកផ្តល់សក្ខីកម្មសប្តាហ៍នេះ>។ ដូច្នេះការជំនួសនេះ គឺថាបានសម្រេច បានដំណើរការរួចមកហើយ។ ហើយលើសពីនេះទៅទៀត អង្គជំនុំជម្រះក៏បានស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលបានស្នើសុំដោយសហព្រះរាជអាជ្ញាយោងតាមវិធាន៨៧(៤) គឺ 2-TCCP-1063។ នេះជាសំណើរបស់សហព្រះរាជអាជ្ញាដែលអង្គជំនុំជម្រះបានទទួលយក។

[០៩:៣២:១៩]

ហើយខ្ញុំសូមរំឭកផងដែរថា មានសាក្សីបន្ថែមទៀតដែលត្រូវបានកោះហៅពាក់ព័ន្ធនឹងការបោសសម្អាត ហើយគេក៏បានផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទបន្ថែមទៅទៀត។ សហព្រះរាជអាជ្ញាបាននិយាយថា យើងចង់បានសាក្សីបន្ថែម ពីព្រោះថាយើងចង់ពិនិត្យបន្ថែម មិនមែនជាសាក្សីជំនួសទេ គឺជាសាក្សីបន្ថែម ដែលសហព្រះរាជអាជ្ញាមិនបានគិតមុនថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ នោះ ហើយក្នុងពេលប្រជុំចញ្ចុំចនេះ នៅនាទីចុងក្រោយនេះ សហព្រះរាជអាជ្ញាបានបំពេញបន្ថែមនូវកង្វះខាតក្នុងការរៀបចំរបស់ខ្លួន ដោយស្នើសុំកោះហៅសាក្សីបន្ថែម។

ខ្ញុំសូមរំឭកនៅក្នុងអនុស្សរណៈមួយទៀតគឺ E408/6/2 នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានបដិសេធនការកោះហៅជាថ្មីម្តងទៀតនៅលោក ប៊ុងសូជ៍ ហើយនិងលោក ស្ទីវ ហេដឌ័រ <ដែលស្នើសុំឡើងដោយមេធាវីការពារក្តី ខៀវ សំផន> ជំនួសសក្ខីកម្មរបស់ វីកឃើរី ដែលមិនបានមកផ្តល់សក្ខីកម្មនោះ អង្គជំនុំជម្រះបាននិយាយថា សក្ខីកម្មហ្នឹងគឺវាមិនដូចគ្នាទៅនឹង វីកឃើរី ទេ អ៊ីចឹងអង្គជំនុំជម្រះបានបដិសេធចោលសំណើនេះ។ ពាក់ព័ន្ធនឹងសាក្សីទាំងពីររូប ដែលសហព្រះរាជអាជ្ញាស្នើសុំនោះ គឺមានតែចំណុចខ្លីតែប៉ុណ្ណោះដែលនិយាយអំពីលោក ខៀវ សំផន នោះ។ អ៊ីចឹងទោះជាយ៉ាងណាក៏ដោយ នៅមានប្រធានបទ គាត់និយាយអំពីប្រធានបទផ្សេង ហើយប្រធានបទទាំងអស់នោះគឺអត់ពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទទេ។

ហើយខ្ញុំសូមរំឭកអំពីការលើកឡើងរបស់មេធាវី កូប៉េ នៅក្នុងក្របខ័ណ្ឌនៃការស្តាប់សក្ខីកម្ម

ពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទនោះ គាត់ថា អ្នកដែលគាត់ហៅមកហ្នឹង ភាគច្រើនមកបាននិយាយរឿងផ្សេងទៅវិញ មិននិយាយអំពីប្រធានបទតួនាទីរបស់ជនជាប់ចោទទេ។ អ៊ីចឹងគឺសហព្រះរាជអាជ្ញាគាត់ចង់ស្នើសុំភស្តុតាងបន្ថែមដាក់យឺតពេលហ្នឹង គឺថាចង់ពន្យារពេលសវនាការឲ្យតែយូរទេ ហើយធ្វើអ៊ីចឹងវារំលោភទៅលើសិទ្ធិរបស់លោក ខៀវ សំផន។

ហេតុអីបានជាខ្ញុំសង្កត់ធ្ងន់លើចំណុចនេះ គាត់សូមសាក្សីបន្ថែម មិនមែន<>សាក្សីជំនួសទេនៅពេលទាន់ហាន់នេះ ពីព្រោះថា តាំងពីយើងចាប់ផ្ដើមសវនាការនៅឆ្នាំ២០១១មកនោះ គឺថានៅពេលដែលយើងមានបញ្ជីសាក្សីហ្នឹង យើងដឹងថាមានសាក្សីណាដែលនឹងមិនមកផ្ដល់សក្ខីកម្ម។ អ៊ីចឹងហើយបានជាសហព្រះរាជអាជ្ញាហ្នឹង ចេះតែទម្លាប់ស្នើសុំសាក្សីបម្រុងអ៊ីចឹង។ យើងដឹងថាមានសាក្សីបម្រុងនៅក្នុងបញ្ជីដំបូងនោះ ក៏ប៉ុន្តែមិនគួរណាមកស្នើសុំនៅពេលហ្នឹងទេ ហើយយើងដឹងហើយថា មានសាក្សីបម្រុងមួយទៀតពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ។ នៅក្នុងសំអាងហេតុរបស់ខ្លួនសហព្រះរាជអាជ្ញានិយាយថា យើងចង់ស្នើសុំសាក្សីពីររូបបន្ថែមដែលនិយាយអំពី ខៀវ សំផន ពីព្រោះថាលោក ថេត សម្បត្តិ មិនបានមកផ្ដល់សក្ខីកម្មទេ។

[០៩:៣៥:៣៩]

ខ្ញុំដឹងថា ថេត សម្បត្តិ ហ្នឹងគឺថាសហព្រះរាជអាជ្ញាតែងតែលើកឡើងមកនិយាយពេលនិយាយអំពី នួន ជា នោះ។ ក៏ប៉ុន្តែគាត់មិនបាននិយាយអំពីជនជាប់ចោទ ខៀវ សំផន ទេ អ៊ីចឹងវាជាភស្តុតាងបន្ថែមដែលបង្ហាញថាសហព្រះរាជអាជ្ញាស្នើសុំហ្នឹង មិនមែនជាសាក្សីជំនួសទេ គឺជាសាក្សីបន្ថែមហើយសុំហ្នឹងសុំទាន់ហាន់ទៅទៀត។ ហើយអត់មានពន្យល់ឲ្យបានច្បាស់ថា ហេតុអីបានជាសំណើហ្នឹងមិនធ្វើតាំងពីថ្ងៃ០១ កញ្ញា ២០១៦មក ទើបតែធ្វើមកឥឡូវ គឺសហព្រះរាជអាជ្ញាអត់បានពន្យល់ច្បាស់ពីចំណុចហ្នឹងទេ។ នេះជាឧទាហរណ៍មួយ។

សាក្សីទី១ ដែលស្នើសុំនៅកថាខណ្ឌ៥នៃឯកសារ <E452> នៃសំណើរបស់គាត់នោះ គាត់ស្នើសុំឲ្យទទួលយកកំណត់ហេតុនោះ គឺនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៦។ កំណត់ហេតុហ្នឹងត្រូវបានទទួលយកដោយអង្គជំនុំជម្រះហើយ តាមរយៈសេចក្ដីសម្រេច E319/47/3<ទទួលយកកំណត់ហេតុស្ដាប់ចម្លើយកលើពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦>។ ខ្ញុំសូមរំឭកថា នៅពេលនោះ ពេលដែលយើងជំទាស់ទៅនឹងការទទួលយកកំណត់ហេតុមួយនេះ នេះវាជាចំណុចសំខាន់ដែលខ្ញុំត្រូវតែលើកឡើង យើងជំទាស់ជានិច្ច ជាគោលការណ៍ហ្នឹង គឺថានៅពេលដែលយកឯកសារពីសំណុំរឿងផ្សេង យកមកដាក់នៅ

ក្នុងសំណុំរឿងយើងនេះ ហើយនៅពេលដែលសំណុំរឿងយើងនេះជិតចប់ទៅហើយនេះ។ ហើយនៅពេលដែលយើងផ្តល់ជំហររបស់យើងច្បាស់លាស់នៅក្នុងសវនាការនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ <ដោយសហភាតារបស់ខ្ញុំ លោក គង់ សំអុន ដោយលើកឡើងថាប្រសិន> បើសហព្រះរាជអាជ្ញាយល់ឃើញថា សាក្សីទាំងពីរហ្នឹងសំខាន់ហ្នឹង អ៊ីចឹងម៉េចក៏គាត់មិននិយាយពេលហ្នឹងទៅ គឺពេលហ្នឹងមុនថ្ងៃទី០១ កញ្ញា ឆ្នាំ២០១៦ទៀត។ ពេលនោះសហព្រះរាជអាជ្ញាគួរតែស្នើសុំការកោះហៅសាក្សីរូបនុ៎ង ប៉ុន្តែគាត់មិនបានធ្វើទេ។ ទោះបីជាយើងបានទាញចំណាប់អារម្មណ៍សហព្រះរាជអាជ្ញាទៅលើចំណុចហ្នឹងក៏ដោយ ក៏គាត់មិនបានធ្វើទេពេលនុ៎ង គាត់អត់មានចេតនាកោះហៅសាក្សីហ្នឹងទេ។ ហើយពេលហ្នឹងគាត់មិនទាន់ដឹងថា តើអង្គជំនុំជម្រះគ្រោងនឹងកោះហៅសាក្សីណាខ្លះមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន នោះទេ។

[០៩:៣៨:០០]

សាក្សីទី២ គឺឯកសារ E3/10751 ដែលស្នើសុំដោយ<សហព្រះរាជអាជ្ញា នៅក្នុង>កថាខណ្ឌ៦ នៃសំណើរបស់ខ្លួន ដែលស្នើសុំនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ឯកសារហ្នឹងគឺ E319/52។ អ៊ីចឹងគាត់ស្នើសុំហ្នឹង គឺវាពាក់ព័ន្ធទៅនឹងការបោសសម្អាតចំពោះសាក្សីរូបនោះ។ ការទទួលយកឯកសារហ្នឹងគឺនៅថ្ងៃទី២៣ ខែ<វិច្ឆិកា> ឆ្នាំ២០១៦ គឺឯកសារ E319/52/4។ <ក្នុងករណីទាំងពីរនេះ>ដោយសារតែសហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកឯកសារហ្នឹងតាំងពីថ្ងៃទី២៥ កក្កដា ឆ្នាំ២០១៦ អ៊ីចឹងសហព្រះរាជអាជ្ញាពេលហ្នឹង គួរតែមានពេលគ្រប់គ្រាន់ក្នុងការស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅសាក្សីរូបហ្នឹងតាំងពីមុនថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦មកម្ល៉េះ។ ហើយឥឡូវគាត់មកលើកឡើងថា គាត់ដាក់សំណើនៅពេលហ្នឹង ពីព្រោះថាដោយសារតែមានសាក្សីខ្លះហ្នឹងមិនបានមកផ្តល់សក្ខីកម្ម ហើយស្នើសុំឲ្យមានសាក្សីជំនួស។ អ៊ីចឹងបើគាត់គិតថា សាក្សីហ្នឹងសំខាន់នោះ គាត់គួរតែធ្វើតាំងពីមុនពេលផុតកាលកំណត់ដែលអង្គជំនុំជម្រះបានសម្រេចនៅថ្ងៃទី០១ ខែកញ្ញា ២០១៦ទៅទៀត។

សហព្រះរាជអាជ្ញាបានពន្យល់ប្រាប់យើងថា យើងមានឯកសារពីស-២១ អ៊ីចឹងយើងគិតថាជាច្បាប់ដើម ឯកសារថ្មី ហើយសាក្សីដែលមកផ្តល់សក្ខីកម្មហ្នឹងមិនបាននិយាយពីសៀវភៅថ្មីហ្នឹងទេ អ៊ីចឹងកាលនុ៎ង យើងស្នើសុំឲ្យកោះហៅសាក្សីថ្មីដើម្បីឲ្យយើងមកសួរពាក់ព័ន្ធហ្នឹង កាលហ្នឹងព្រះរាជអាជ្ញាថាដូចជាមិនចាំបាច់ទេ។ <នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ សាក្សីពីរនាក់បន្ថែមទៀតត្រូវកោះហៅឲ្យមកផ្តល់សក្ខីកម្មពីតួនាទីរបស់ ខៀវ សំផន ប្រឆាំងនឹងជនជាប់ចោទទៅវិញ ថ្វីត្បិតថាព្រះរាជអាជ្ញា

មានកំណត់ហេតុស្ដាប់ចម្លើយមុនកាលកំណត់ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ក៏ដោយ។>

អ៊ីចឹងយើងត្រូវតែឱ្យវាមានភាពប្រាកដប្រជា។ អង្គជំនុំជម្រះត្រូវតែបង្ហាញថា ខ្លួននៅទីនេះ មិនមែនដើម្បីជួសជុល ឬក៏ប៉ះប៉ូវជួយដល់សហព្រះរាជអាជ្ញាដែលមិនបានបំពេញភារកិច្ចរបស់ខ្លួន ឱ្យបានត្រឹមត្រូវទេ។ ដូច្នេះយើងខ្ញុំសូមជំទាស់យ៉ាងដាច់អហង្ការទៅនឹងការកោះហៅសាក្សីទាំងពីររូបហ្នឹង។ ខ្ញុំមិនដឹងថា អង្គជំនុំជម្រះសម្រេចយ៉ាងម៉េចទេ ក៏ប៉ុន្តែ ខ្ញុំជំទាស់។

ខ្ញុំបានលើកឡើងអនុស្សរណៈខែសីហា ឆ្នាំ២០១៦ ហើយ អ៊ីចឹងខ្ញុំយល់ថា អនុស្សរណៈហ្នឹងគឺមានសារៈសំខាន់ណាស់ពាក់ព័ន្ធទៅនឹងកាលកំណត់នោះ។ ហើយអ៊ីចឹង ខ្ញុំគិតថា អង្គជំនុំជម្រះនឹងគោរពអ្វីដែលខ្លួនបានកំណត់នៅក្នុងក្របខ័ណ្ឌនៃសេចក្ដីសម្រេចរបស់ខ្លួននោះ មិនមែនចេះតែធ្វើអ្វីតាមតែការស្នើសុំរបស់សហព្រះរាជអាជ្ញានោះទេ។

[០៩:៤០:៤៥]

ខ្ញុំអម្បាញ់មិញដូចភ្លេចឆ្លើយទៅលើបញ្ហាឯកសារ។ ចំពោះយើង គឺយើងនឹងបង្ហាញឯកសារពាក់ព័ន្ធទៅនឹងតួនាទីជនជាប់ចោទនៅក្នុងសវនាការស្ដីពីឯកសារគន្លឹះនោះ។ ហើយអង្គជំនុំជម្រះបានបញ្ជាក់ជាច្រើនរួចមកហើយ ជាពិសេសនៅក្នុងអនុស្សរណៈ E315/2 ថាឯកសារពាក់ព័ន្ធនឹងគោលនយោបាយថ្នាក់ជាតិនោះ អាចនឹងមានផលប្រយោជន៍ក្នុងការបង្ហាញផងដែរ ពាក់ព័ន្ធនឹងក្របខ័ណ្ឌនៃសវនាការស្ដីអំពីតួនាទីរបស់ជនជាប់ចោទ។ អ៊ីចឹងលោកប្រធានគឺ យើងមានឯកសារដែលត្រូវបង្ហាញនៅក្នុងសវនាការគន្លឹះ ឯកសារគន្លឹះនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមធ្វើការកត់សម្គាល់មួយ ទៅលោកស្រីមេធាវី អង់តា ហ្គីសសេ។ ខ្ញុំកត់សម្គាល់ឃើញថា សាក្សីដែលគាត់សុំមកឱ្យផ្ដល់សក្ខីកម្មនៅទីនេះ ទាំងពីរនាក់នេះ បានផ្ដល់សក្ខីកម្មនៅចំពោះមុខចៅក្រមស៊ើបអង្កេត ហើយមានកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ដែលត្រូវបានទទួលយកហើយ គឺនៅមានក្នុងសំណុំរឿងរួចអស់ទៅហើយ។ តែបញ្ហាគឺថា តើមានផ្នែកណាខ្លះដែលទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទនេះ។ អ៊ីចឹងផ្នែកទាំងអស់នេះត្រូវ កំណត់ហេតុស្ដាប់ចម្លើយពួកគាត់នោះ ត្រូវតែសួរដេញដោលនៅទីនេះ។ ហើយអ្វីដែល ខ្ញុំចង់ដឹងឱ្យច្បាស់ៗហ្នឹងគឺថា មេធាវី ខៀវ សំផន នោះមិនចង់សួរ

 E1/514.1

ដេញដោលគាត់ទេ ឬក៏យ៉ាងណា?

[០៩:៤២:៣០]

**កញ្ញា អង់តា ហ្គីសសេ៖**

យើងមានបញ្ហាច្បាប់នេះច្បាស់ណាស់ គឺថាតាមផ្លូវច្បាប់នោះ បើកាលណាមានកំណត់ហេតុស្ដាប់ចម្លើយទាក់ទងទៅនឹងតួនាទី និងអត្តចរិតរបស់ជនជាប់ចោទហើយ ហេតុអីមិនគិតពី ម៉េចក៏អង្គជំនុំជម្រះមិនគិត។ ហើយបើយើង បើនិយាយថា<កំណត់ហេតុស្ដាប់ចម្លើយ ហើយអង្គជំនុំជម្រះយល់ឃើញថា> ខាងព្រះរាជអាជ្ញាគាត់នោះស្នើឃើតមកហើយ <>យើងមិនចាំបាច់ទៅសួរដេញដោលអីគាត់<អំពីតួនាទីរបស់ជនជាប់ចោទ>ទៀតទេ បើអង្គជំនុំជម្រះបដិសេធសំណើរបស់ព្រះរាជអាជ្ញាទៅហើយនោះ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយតទៅនេះ ផ្ដល់វេទិកាជូនទៅសហមេធាវីការពាក្ដីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន យើងខ្ញុំមានកំណត់សម្គាល់ពីរបី ឆ្លើយតបទៅនឹងសំណើសុំនេះ។ ទី១ ដើម្បីឲ្យជ្រះស្រឡះនោះ គឺថា តាមធម្មតា យើងខ្ញុំមិនដែលបានបង្ហាញនូវឯកសារសារៈសំខាន់ណាមួយជាពិសេស ចាប់តាំងពីសវនាការខែសីហា ឆ្នាំ២០១៥មក យើងមិនដែលបានផ្លាស់ប្ដូរជំហររបស់យើងខ្ញុំទេ។ ហើយជាការពិតហើយ យើងខ្ញុំនឹងមិនមានប្រតិកម្មអ្វីទេ ប្រសិនណាសហព្រះរាជអាជ្ញាស្នើសុំឲ្យបង្ហាញនូវឯកសារ ហើយបើទោះបីជាក្រុម ខៀវ សំផន មានការជំទាស់ក៏ដោយ។

[០៩:៤៤:១៧]

ទី២ ទាក់ទងទៅនឹងសំណើសុំ <E452> ដែលស្នើសុំឲ្យកោះហៅសាក្សី<ពីរនាក់>បន្ថែមទៀតនោះ ដែលពាក់ព័ន្ធទៅនឹងផ្នែកចុងក្រោយគឺតួនាទីរបស់ជនជាប់ចោទ។ លោកប្រធាន ជាញឹកញាប់ណាស់មកហើយ នៅក្នុងពេលផ្ដល់សក្ខីកម្មនៅក្នុងសវនាការវគ្គនេះ យើងខ្ញុំបានបង្ហាញឲ្យឃើញថាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះហេតុផលក្នុងការកោះហៅសាក្សីទាំងអស់នេះ ដែលបានចូលខ្លួនមកក្នុងសវនាការផ្នែកនេះ<រួចមកហើយ>។ ហើយមានឱកាសជាច្រើនយើងមិនបាន យើងឃើញថា ការកោះហៅសាក្សីមួយចំនួននោះ ហេតុអ្វី គឺថា សាក្សីខ្លះគាត់មកនោះ គឺមិនមានអ្វីនិយាយអំពីតួនាទីរបស់ជនជាប់ចោទទេ ផ្ទុយទៅវិញ គឺថាភាគីបែរជាសួរអ្វីៗក្រៅពីតួនាទីរបស់ជនជាប់ចោទទៅវិញ។ ហើយ

ផ្នែកនៃស្តីអំពីតួនាទីរបស់ជនជាប់ចោទនេះ ហាក់បីដូចជាជាផ្នែកមួយទុកចោលអ៊ីចឹង។ ហ្នឹងអ្វីដែលយើងខ្ញុំបានកត់សម្គាល់ឃើញ។

ហើយដូចគ្នានេះដែរ គឺខ្ញុំនិយាយសំដៅទៅលើសាក្សីពីរនាក់ ដែលសហព្រះរាជអាជ្ញាបានស្នើសុំនៅនាទីចុងក្រោយ ដើម្បីមកឲ្យផ្តល់សក្ខីកម្មនោះ ពីព្រោះថាសាក្សីទី១ គឺជាអ្នកដែលក្តោបក្តាប់កងចល័តមួយនៅក្នុងតំបន់មួយ ហើយគាត់ជាកម្មាភិបាលជាន់ទាប ដែលប្រហែលជាមិនអាចផ្តល់ព័ត៌មានអ្វី ឬក៏និយាយអ្វីពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទបានទេ។

ហេតុផលមួយដែលថា គាត់ជាសាក្សីអាចគួរឲ្យចាប់អារម្មណ៍នោះ គឺប្រហែលជាយើងអាចនឹងសួរទៅកាន់សាក្សីរូបនេះ ដោយសារថាគាត់នេះគឺជាក្មួយប្រុស ឬក៏ថាជាជីដូនមួយរបស់<បុគ្គលទី២ ឬបុគ្គលទី៣>ហេង ទាវ នៅភូមិភាគពាយ័ព្យហ្នឹង<ហៅ ប៉ែត> ឬក៏ហៅថា “តាកន្ទុល” នេះ។ ហើយយើងខ្ញុំចង់ដឹងមែនទែនអំពីសកម្មភាពបះបោររបស់កម្មាភិបាលនៅភូមិភាគពាយ័ព្យ។ ហើយសាក្សីរូបនេះជាជីដូនមួយរបស់ <ហេង> ទាវ។ ប្រហែលជាគាត់អាចមានព័ត៌មាន។

[០៩:៤៧:០៩]

យើងខ្ញុំក៏សូមលើកឡើងជាបន្ទាន់ ដូចតទៅនេះ។ ប្រសិនណាជាអង្គជំនុំជម្រះសម្រេចទទួលយកសំណើសុំរបស់សហព្រះរាជអាជ្ញា ហើយបដិសេធនូវរាល់ទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន បើដូច្នេះយើងខ្ញុំសូមលើកឡើងដូចតទៅ។ មានឯកសារជាខ្សែអាត់សំឡេងពីរពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍ជាមួយនឹង ហេង ទាវ ដែលលោក ស្ទីវ ហេដឌ័រ ជាអ្នកសម្ភាស។ កិច្ចសម្ភាសន៍មួយគឺត្រូវបានកត់ត្រាជាប្រតិចារឹកខ្លះៗហើយ គឺនៅក្នុងឯកសារ E3/5309។ ក៏ប៉ុន្តែខ្សែអាត់សំឡេងមួយផ្សេងទៀតនោះ ក៏ក្រុមយើងខ្ញុំ ក្រុមមេធាវីការពារក្តី នួន ជា នេះក៏មានចំណាប់អារម្មណ៍ចំពោះខ្សែអាត់មួយផ្សេងទៀត។ ឯកសារនេះមានតែខ្សែអាត់សំឡេងជាភាសាខ្មែរទេ។ ដូចដែលអង្គជំនុំជម្រះបានជ្រាបហើយ ស្ទីវ ហេដឌ័រ នេះចេះខ្មែរស្ទាត់មែនទែន។

ហើយជាពិតនោះ យើងខ្ញុំមានការបកប្រែផ្ទៃក្នុងអង្គភាពការពារក្តី <ប៉ុន្តែមិនមានប្រយោជន៍អីទេ។> ក៏ប៉ុន្តែយើងខ្ញុំនឹង<សួរទៅ>សាក្សី<បើសិនណាគាត់>ត្រូវបានកោះហៅពាក់ព័ន្ធទៅនឹងកិច្ចសម្ភាសន៍នេះ។ ប្រសិនណាជាគាត់ត្រូវមក យើងខ្ញុំនឹងស្នើសុំឲ្យមានការបកប្រែជាបន្ទាន់នូវឯកសារនេះ គឺឯកសារ E3/2767R ឬហៅថាឯកសារ <D210/12R> ដែល ហេង ទាវ នេះបានឆ្លើយទៅនឹង ស្ទីវ ហេដឌ័រ។

[០៩:៤៩:១១]

ការដែលខ្ញុំលើកឡើងបែបនេះ ក៏វាពាក់ព័ន្ធទៅនឹងសាក្សីទី២ សហព្រះរាជអាជ្ញាស្នើសុំឲ្យកោះហៅសាក្សីទី២ដែរ គឺថាគាត់មកពីកងពល១៦៤ ជាកម្មាភិបាលជាន់ទាបមែនទែន។ ហើយគាត់មានការលើកឡើងពាក់ព័ន្ធទៅនឹងឈ្មោះ ខៀវ សំផន តិចតួចដែរ ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ហាក់ដូចជាមិនមានព័ត៌មានអ្វីទេ។

យើងខ្ញុំ គឺថាក៏បានស្នើសុំឲ្យកោះហៅសាក្សីពាក់ព័ន្ធទៅនឹងសវនាការដូចគ្នា គឺតួនាទីរបស់ជនជាប់ចោទ។ សហព្រះរាជអាជ្ញានិយាយថា សំណើសុំឲ្យកោះហៅសាក្សី គឺថាតែពាក់កណ្ដាលទេ បានទទួលយក។ ឯសាក្សីរបស់ខាងយើងខ្ញុំ ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទនោះ<មិនបានបង្ហាញខ្លួនទេ។ យើងខ្ញុំគិតថា> សំណើ<របស់យើងខ្ញុំ>សុំឲ្យកោះហៅបងប្អូន មាន ជួន ប្រសិទ្ធិ, ជួន ជឿន ដែលយើងខ្ញុំថា សក្ខីកម្មរបស់ពួកគាត់ហ្នឹង គឺថាមានសារៈសំខាន់មែនទែន ពាក់ព័ន្ធនឹងសវនាការផ្នែកនេះ។ យើងខ្ញុំគឺថាអស់សង្ឃឹមទាំងស្រុង ដែលថា អង្គជំនុំជម្រះអាចនឹង<>កោះហៅសាក្សីសំខាន់ៗពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ជាពិសេស អ្នកដែលធ្លាប់<ស្គាល់> នួន ជា <គឺធ្លាប់ធ្វើជានីរសាររបស់គាត់នៅពេលណាមួយ ហើយគាត់ជាសាក្សីអំពីអត្តចរិតរបស់ នួន ជា> គឺ ហេង សំរិន នេះឯង។ ឥឡូវនេះ យើងខ្ញុំដឹងហើយថា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា <>មិនហៅគាត់ឲ្យមកចូលខ្លួននៅក្នុងសំណុំរឿងលើ០០២/០១ ជាការមិនត្រឹមត្រូវទេ <ហើយគ្មានហេតុផលទៀតផងហើយវារឹតតែមិនសមហេតុផលទៅទៀត បើមិនកោះហៅគាត់ឲ្យចូលខ្លួនក្នុងសំណុំរឿង០០២/២ នោះទេ>។ យើងខ្ញុំតែងតែស្នើសុំឲ្យគាត់ចូលខ្លួននៅគ្រប់ផ្នែកទាំងអស់នេះ ជាពិសេសនេះ គឺស្នើសុំឲ្យកោះហៅពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ មិនមែនពាក់ព័ន្ធតែ<សាក្សីអំពីអត្តចរិតជនជាប់ចោទនោះ>ទេ។ ហើយ<នៅពេលនេះត្រូវមកដោះស្រាយជាមួយនឹងសាក្សីពីរនាក់>ចុងក្រោយនេះ <ខ្ញុំគិតថា វាជារឿងដែលហួសចិត្ត>។ បាទ លោកប្រធាន ខ្ញុំអស់មានមតិយោបល់អ្វីហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា!

[០៩:៥២:០២]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំស្ដាប់ការបកប្រែចុងក្រោយនេះអត់ឮ ប៉ុន្តែខ្ញុំសូមធ្វើការឆ្លើយតបលោកប្រធាន។ លោក លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចៅក្រម ទី១ ពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍ពីក្រុម ខៀវ សំផន សំណើសុំឲ្យកោះហៅសាក្សីនេះ អាស្រ័យទៅលើកិច្ចសម្ភាសន៍ដែលបាន ក្រោយពីពេលចាប់ផ្តើមសវនាការ។ ក្រោយពីសហព្រះរាជអាជ្ញាបានដាក់ជូននូវបញ្ជីសាក្សី។ កំណត់ហេតុស្តាប់ចម្លើយដែលសហព្រះរាជអាជ្ញាស្នើសុំតាំងពីមុនថ្ងៃទី០១ ខែកញ្ញា មកម្ល៉េះ។ បញ្ហានៅទីនេះ មិនមែនជារឿងការទទួលយកឯកសារនានា ឬ/និងកំណត់ហេតុ<ស្តាប់ចម្លើយនោះទេ គឺបញ្ហាផ្តល់>សក្ខីកម្ម<>។ ដូចដែលខ្ញុំបានពន្យល់នៅក្នុងសំណើសុំរបស់យើងខ្ញុំហើយ យើងខ្ញុំយល់ឃើញថា សាក្សីបន្ថែមនេះ គឺមានសាក្សីមួយចំនួនដែលរៀបរាប់ឈ្មោះនៅក្នុងកថាខណ្ឌ៣<> ដែលយើងទើបតែដឹងនៅក្នុងខែនេះ គឺថាមិនអាចមកផ្តល់សក្ខីកម្មបានទេ។ នេះនៅក្នុងកថាខណ្ឌ៣នៃសំណើសុំរបស់យើងខ្ញុំ។

ក្រុមមេធាវីការពារក្តីខៀវ សំផន ក៏បានលើកឡើង<ហើយយើងយល់ស្រប>ផងដែរថា សារទាំងឡាយពាក់ព័ន្ធទៅនឹង ខៀវ សំផន និងតួនាទីរបស់គាត់ហ្នឹង គឺថាមានកម្រិតណាស់។ ជាពិសេសនៅក្នុងកំណត់ហេតុស្តាប់ចម្លើយទាំងពីរនេះ។ ប៉ុន្តែពួកគាត់មិនបានពន្យល់តាមរបៀបណាមួយ ថាហេតុអ្វីបានជាពេលវេលានៃការស្នើសុំបែបនេះ ធ្វើឲ្យមានព្យសនកម្មទៅដល់ក្រុមគាត់នោះ។ ពួកគាត់<មិនបាននិយាយថា តើហេតុអ្វីបានជាពួកគាត់មិនអាច>ត្រៀមលក្ខណៈសួរសំណួរទៅកាន់សាក្សីរូបនេះទេ <ឬក៏ថាតើពេលវេលានៃការស្នើសុំប៉ះពាល់យ៉ាងណាដល់ពួកគេ ក្នុងករណីដែលពួកគេចូលមកនៅខែក្រោយ>។ ហើយពួកគាត់មានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមខ្លួនតាំងសំណួរទៅកាន់សាក្សីទាំងនេះ។

[០៩:៥៤:០១]

ទាក់ទងទៅនឹងទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តី នួន ជា វិញ គឺថាជាការគួរឲ្យចាប់អារម្មណ៍ណាស់ គឺថា "សាក្សីដែលពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ មិនគួរណាសាកសួរពាក់ព័ន្ធទៅនឹងផ្នែកផ្សេងៗនោះទេ។" ហើយក្រុមមេធាវីការពារក្តី នួន ជា គឺថាភាគច្រើននៅក្នុងផ្នែកនីមួយៗ សវនាការនោះ ក៏មិនបានបង្ហាញឲ្យឃើញថា ខ្លួនហ្នឹងសួរឲ្យចំៗចំណុចដែរ សួររាលដាលដូចជាពិសេសពាក់ព័ន្ធទៅនឹងការបះបោរនេះ។ ហើយខ្លួនមានចំណាប់អារម្មណ៍ខ្លាំងតែទៅលើការបះបោរតែប៉ុណ្ណោះ។ យើងខ្ញុំមិនជំទាស់ទេ បើសិនណាជាក្រុមមេធាវីការពារក្តីនេះ គាត់មានសំណួរសួរមកកាន់សាក្សីរូបនេះ ឬមិនមានក៏ដោយ។

យើងខ្ញុំសូមបញ្ជាក់អំពីជំហររបស់យើងខ្ញុំ ពាក់ព័ន្ធទៅនឹងសាលដីកាតុលាការកំពូល ពាក់ព័ន្ធទៅ

នឹងលោក ហេង សំរិន។ អ្វីដែល<គេបាននិយាយនោះគឺថា> វាជាកំហុសឆ្គងមួយ <ដែលមិនស្រាវជ្រាវថាតើគាត់មានឆន្ទៈចង់មកផ្តល់សក្ខីកម្មឬទេ>។ ឯខ្ញុំ ខ្ញុំសូមនិយាយតែសម្រាប់ ដោយសារសហព្រះរាជអាជ្ញាជាតិមិននៅទីនេះព្រឹកនេះ អ៊ីចឹងខ្ញុំនិយាយតែក្នុងនាមខ្លួនខ្ញុំផ្ទាល់តែប៉ុណ្ណោះ ព្រោះថាយើងខ្ញុំស្នើសុំដែរថា បើសិនណាជាគាត់មានចំណាប់អារម្មណ៍អាចមកផ្តល់សក្ខីកម្ម គឺថា<គាត់ជាសាក្សីដ៏>អស្ចារ្យ<សម្រាប់ខាងសហព្រះរាជអាជ្ញា។ ខ្ញុំមិនមានមន្ទិលអ្វីទេចំពោះរឿងនេះ ក្នុងការផ្តល់នូវព័ត៌មានដែលយើងដឹងថា គាត់បាននិយាយ>នៅក្នុងកិច្ចសម្ភាសន៍<នាពេលកន្លងមក>។ យើងខ្ញុំ<នឹងជំរុញឲ្យសាក្សីទាំងអស់>សហការជាមួយតុលាការ<> ដើម្បីឲ្យគាត់បង្ហាញឲ្យឃើញនូវការពិតដែលបានកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ សូមអរគុណលោកប្រធាន។

[០៩:៥៥:៥២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមយល់ឲ្យច្បាស់ពីសំណើ ឬក៏ការកត់សម្គាល់របស់មេធាវី នួន ជា។ លោកមេធាវី កូប៉េ តើលោកចង់ស្តាប់សាក្សីដែលព្រះរាជអាជ្ញាគាត់ស្នើ? លោកចង់ស្តាប់តែម្នាក់ទេ ឬក៏ទាំងពីរនាក់? គឺខ្ញុំដូចជាមិនយល់ច្បាស់អំពីគោលជំហររបស់លោកមេធាវី។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមែនទេ លោកចៅក្រម ឡាវែន៍។ យើងខ្ញុំបានជំទាស់ទៅនឹងសំណើសុំ ដោយសំអាងទៅលើសំអាងហេតុដូចក្រុម ខៀវ សំផន លើកឡើងអ៊ីចឹងដែរ។ យើងខ្ញុំគ្រាន់តែថា ប្រសិនណាជាអង្គជំនុំជម្រះសម្រេចថា កោះហៅជីដូនមួយរបស់ ហេង ទាវ ជាសាក្សី យើងខ្ញុំជឿជាក់ថា វាមានសារៈសំខាន់ណាស់ ដែលត្រូវតែធ្វើការបកប្រែកំណត់ហេតុស្តាប់សំឡេងនៃឪពុកមារបស់គាត់នេះ។ ខ្ញុំយល់ឃើញថា គាត់មានតួនាទីលេខ២ ឬក៏លេខ៣ នៅក្នុងភូមិភាគពាយ័ព្យ។ ហើយកិច្ចសម្ភាសន៍របស់ ហេង ទាវ និង ស្ទីវ ហេដឌ័រ ហ្នឹងគឺថា ជាផ្នែកមួយគួរឲ្យចាប់អារម្មណ៍មែនទែន។ បើសិនណាជាសាក្សីមានព័ត៌មានពាក់ព័ន្ធទៅនឹងបញ្ហានេះ យើងខ្ញុំនឹងសួរតទល់ជាមួយនឹងសាក្សី។ <វាជាសេណារីយ៉ូមួយកាលណាអង្គជំនុំជម្រះយល់ព្រមនឹងការស្នើសុំរបស់សហព្រះរាជអាជ្ញា។>

[០៩:៥៧:៣៤]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំនិយាយខ្លីទេ ដើម្បីឆ្លើយទៅនឹងសហព្រះរាជអាជ្ញា។ បើសិនសហព្រះរាជអាជ្ញាមិនយល់ថា ហេតុអ្វីបានថា ម៉េចបានថាជាជនជាប់ចោទ នៅពេលដែលយកសាក្សីមកនាទីចុងក្រោយនេះ គឺវាបង្កព្យសនកម្មដល់គាត់នោះ គឺខ្ញុំថា ដូចជាយើងហ្នឹងមិនយល់ពីហេតុផលទាល់តែសោះ។ វាមិនមែនត្រឹមតែបញ្ហាការរៀបចំលក្ខណៈនោះទេ គឺជាបញ្ហាគោលការណ៍ ពីព្រោះថាសាក្សីទាំងពីរដែលព្រះរាជអាជ្ញាអញ្ជើញមកនេះ គឺពិតហើយ ដូចលោកចៅក្រម ឡាវែន៍ បាននិយាយអំមិញ គឺគាត់ទាំងពីរនាក់ហ្នឹង បានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតហើយ ក៏ប៉ុន្តែវា ចំពោះគាត់ការដែលគាត់បានឆ្លើយតែចំពោះមុខសហចៅក្រមស៊ើបអង្កេតហ្នឹង <ដែលលោក ខៀវ សំផន មិនមែនជាភាគី។ ហើយវាមិនបានផ្អែកទៅលើសក្ខីកម្មរបស់សាក្សីទាំងពីរនាក់នេះក្នុងការកោះហៅមកចំពោះមុខអង្គជំនុំជម្រះនោះទេ>។ ការដែលកោះគាត់មកថ្ងៃនេះមក មកកោះហៅជាលើកចុងក្រោយនេះ ដើម្បីបង្កើនភស្តុតាងដាក់បន្ទុកនោះ ដែលព្រះរាជអាជ្ញាយល់ឃើញថា ប្រហែលជាដាក់បន្ទុកនុំង មិនទាន់គ្រប់គ្រាន់ហ្នឹង នេះហើយបញ្ហា។

ដូចដែលក្នុងអនុស្សរណៈរបស់តុលាការយើងនេះស្រាប់ហើយ នៅសំណុំរឿង០០២/១នេះ គឺថាវាវែងណាស់ទៅហើយ ហើយរហូតដល់ឥឡូវ នាទីចុងក្រោយនេះ យកភស្តុតាងដាក់បន្ទុកក្រោយមកទៀត នាទីចុងក្រោយហើយ យកមកសង្កត់បន្ថែមទៀតនេះ មកសង្កត់កលោក ខៀវ សំផន នេះ វាអយុត្តិធម៌ណាស់ មិនត្រឹមត្រូវទេ។

[០៩:៥៩:១០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវបញ្ចប់បញ្ហាហ្នឹងត្រឹមហ្នឹងចុះ ហើយតទៅបញ្ហាទី២។ អង្គជំនុំជម្រះនឹងស្ដាប់សារណាផ្ទាល់មាត់របស់ភាគីលើបញ្ហាទី២ ដែលពាក់ព័ន្ធនឹងសំណើអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ដែលបានដាក់ដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សូមឲ្យទទួលយកសេចក្ដីបន្ថែមនៃការបោះពុម្ពផ្សាយជាលើកទី២ នៃសៀវភៅមួយក្បាល ដែលមានចំណងជើងថា “ខេមបូឌា ឌីហេដ ស្គែ -- ស្ក៊ែរ”។

នៅក្នុងដំណើរសំណើរបស់ខ្លួន ដែលបានដាក់កាលពីថ្ងៃម្សិលមិញ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកសេចក្ដីបន្ថែមនៃឯកសារនេះ ដោយបញ្ជាក់

ថាខ្លួនទើបទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦។ ហើយសហមេធាវី បានអះអាងថា សេចក្ដីបន្ថែមនៃឯកសារនេះ មានភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ជាពិសេស វាអាចជួយដល់អង្គជំនុំជម្រះ ក្នុងការទទួលស្គាល់ អំពីផលប៉ះពាល់ផ្លូវចិត្តជាក់ស្ដែង ដែលទទួលរងដោយដើមបណ្ដឹងរដ្ឋប្បវេណី និងអាចជួយដល់អង្គជំនុំជម្រះក្នុងការទទួលស្គាល់គម្រោងសំណងដ៏សមស្រប ដែលនឹងអាចបង្ហាញដោយសហមេធាវីនាំមុខនៅក្នុងគម្រោងសំណងចុងក្រោយ។

ហើយជាដំបូងនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីឡើងបង្ហាញដោយសង្ខេបនូវសំណើសុំរបស់ខ្លួន។ សូមអញ្ជើញបាទ!

[១០:០០:៤៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរភាគីទាំងអស់គ្នា។ ខ្ញុំសង្ខេបសំណើរបស់យើង សូមឲ្យទទួលយកភស្តុតាងថ្មី ដោយយោងតាមវិធាន៨៧(៤)។ សំណើនេះគឺចុះបានស្នើនៅថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ២០១៦ <គឺអាចនិយាយថា> បន្ទាប់ពី<ថ្ងៃទី០១ ខែកញ្ញា ដែលបានលើកឡើងនៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះដែលរំឭកឡើងដោយសហភាតារបស់យើងនូវឯកសារ> E421/4 ហើយនិង E421។ យើងបានសូមឲ្យទទួលឯកសារមួយ គឺជាសេចក្ដីបន្ថែមនៃការបោះពុម្ពផ្សាយលើកទី២ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលតុលាការមានចំណងហើយ។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ព្រោះថាមានតែជាភាសាអង់គ្លេសទេនៅពេលនេះ។ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសលោកប្រធាន "លទ្ធផលនៃបញ្ហាចិត្តសាស្ត្រ គឺបណ្ដាលមកពីឧក្រិដ្ឋកម្មដែលបង្កឡើងដោយខ្មែរក្រហម។"

បើអ៊ីចឹងឯកសារនេះមានភាពពាក់ព័ន្ធណាស់ ពីព្រោះថាវាផ្សារភ្ជាប់ទំនាក់ទំនងព្យសនកម្មផ្លូវចិត្ត ហើយនិងសំណុំរឿងដែលយើងកំពុងតែជំនុំជម្រះនេះ គឺសំណុំរឿង០០២/០២។ ឯកសារនេះគួរឲ្យទុកចិត្តបាន ព្រោះវាចេញពីមន្ទីរពិសោធន៍មួយដ៏ល្បី គឺមន្ទីរពិសោធន៍ដែល><មានអ្នកឯកទេស>រោគចិត្តសាស្ត្រ ហើយនិង<អ្នកវិទ្យាសាស្ត្រផ្នែកឥរិយាបទនៅមហាវិទ្យាល័យវេជ្ជសាស្ត្រ>នៃសាកលវិទ្យាល័យ<>ស្ដេនហ្វត។

អ៊ីចឹងសំណើរបស់យើងខ្ញុំនេះ គឺជាសំណើដែលសមគួរ ហើយឆាប់រហ័ស ព្រោះថាយើងបានទទួលដំណឹងតាមរយៈញូវស្លេតធ័រ ដែលផ្ញើមក ស៊ី.ឌី.ខេម នេះ មជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃ<២៣> វិច្ឆិកា<>។ ហើយយើងបានសូមស្នើឲ្យបកប្រែភាសានេះជាភាសាខ្មែរ ហើយអង្គភាពបកប្រែ

នោះបានឆ្លើយប្រាប់មកយើងវិញថា ការបកប្រែជាភាសាខ្មែរនេះនឹងរួចរាល់នៅសប្តាហ៍ទី១ នៃខែមករា ហើយដើម្បី--។ ជាទីបញ្ចប់ គឺថាឯកសារនេះមានភាពពាក់ព័ន្ធណាស់ ចំពោះសំណើសុំសំណងផ្លូវចិត្ត ហើយនិងជាសមូហភាពនៅក្នុងសំណុំរឿងយើងនេះ និងសំណើចុងក្រោយរបស់យើងនោះ គឺដើម្បីជួយអង្គជំនុំជម្រះក្នុងការវាយតម្លៃភាពសមរម្យនៃសំណើសុំសំណងរបស់យើង។ អ៊ីចឹងយើងខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាទទួលយកឯកសារនេះលោកប្រធាន។

[១០:០៣:៤៦]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយបន្តទៅនេះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីធ្វើការ សារណាតប ឬក៏ធ្វើការកត់សម្គាល់។

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម យើងគិតថាសំណើសុំនេះមានមូលហេតុសមរម្យ ហើយយើងខ្ញុំគាំទ្រ។

**ប្រធានអង្គជំនុំ៖**

តទៅនេះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី។ ដំបូងនេះ មេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េះ៖**

បាទ លោកប្រធាន យើងមិនមានការកត់សម្គាល់អ្វីនោះទេ ទាក់ទងទៅនឹងពេលវេលានៃការដាក់ឯកសារនេះ។ ក៏ប៉ុន្តែយើងខ្ញុំមានចំណុចមួយចំនួនដែលយើងខ្ញុំចង់លើកឡើង ទាក់ទងទៅនឹងខ្លឹមសារនៃសំណើ។ វាជារបាយការណ៍ស្មុគស្មាញមួយ ហើយយើងខ្ញុំមិនទាន់មានឱកាសគ្រប់គ្រាន់ដើម្បីពិនិត្យមើលត្រួសៗនៅឡើយ។ យើងខ្ញុំយល់ស្របជាមួយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលថា ស្តេនហ្វត គឺជាស្ថាប័នដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ។ ពិតណាស់ថា របាយការណ៍ដែលចេញដោយ -- ដែលចេញកាលពីមួយឆ្នាំមុន ដោយ ស្តេនហ្វត ដាប់ប៊ែលយូ.អេស.ឌី <មជ្ឈមណ្ឌលហានដា សម្រាប់>សិទ្ធិមនុស្ស និង<យុត្តិធម៌អន្តរជាតិ។ ពាក់ព័ន្ធ>ទៅលើសាលក្រមសំណុំរឿង ០០២/០១ហ្នឹង គឺជារបាយការណ៍ត្រឹមត្រូវជាក់លាក់ ហើយនិងជារបាយការណ៍ល្អ។

[១០:០៥:៤១]

ដូច្នេះប្រសិនបើយើង ដូច្នេះយើងមិនគួរជជែកអំពីកេរ្តិ៍ឈ្មោះរបស់សាកលវិទ្យាល័យស្តេតហ្វត នោះទេ។ ប៉ុន្តែតាមដែលខ្ញុំយល់ទៅលើសេចក្តីសង្ខេបនៅក្នុងសំណើ ក៏ដូចជាការពិនិត្យមើលទៅលើ

របាយការណ៍នេះគឺខ្ញុំសូមដកស្រង់នូវកថាខណ្ឌ១១នៃសំណើតាម៨៧ គឺថាវាជារបាយការណ៍វេជ្ជសាស្ត្រ គឺជារបាយការណ៍ស្រាវជ្រាវអនុវត្តផ្ទាល់ជាមួយអ្នកជំងឺ និងជាលក្ខណៈទ្រឹស្តី។ ហើយនៅពេលដែលខ្ញុំមើលទៅលើរបាយការណ៍នោះ គឺបង្ហាញថាព្រឹត្តិការណ៍ដែលប៉ះទង្គិច គឺជាបទពិសោធន៍ ហើយអ្នកដែលចូលរួមនៅក្នុងការព្រាងរបាយការណ៍នេះ គឺផ្អែកទៅលើសក្ខីកម្ម ដើម្បីឈានទៅដល់ការសន្និដ្ឋានអំពីផលប៉ះពាល់ផ្លូវចិត្តរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានមកផ្ដល់សក្ខីកម្មនេះ។ ព្រោះថា ដោយសារតែខ្ញុំគ្រាន់តែជាមេធាវីតែមួយរូបប៉ុណ្ណោះ ដូច្នេះខ្ញុំមិនដឹងថាតើរបាយការណ៍អនុវត្តផ្ទាល់ជាមួយអ្នកជំងឺហ្នឹង ឬមួយក៏ថាតើអ្នកដែលមានជំនាញខាងវេជ្ជសាស្ត្រ គេធ្វើការសន្និដ្ឋានស៊ីជម្រៅដល់ថ្នាក់បែបហ្នឹងឬ នៅពេលដែលគេគ្រាន់តែមើលទៅលើសក្ខីកម្ម និងមើលទៅលើរបាយការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងតុលាការ។

ខ្ញុំបានឃើញអ្នកដែលសរសេរហ្នឹង ហើយខ្ញុំបានធ្លាប់ជួបជាមួយដើមបណ្ដឹងរដ្ឋប្បវេណីពីររូប ខ្ញុំគិតថា មិនគួរបញ្ចូលរបាយការណ៍នេះទេ ព្រោះថារបាយការណ៍នេះវាមិនមានវិធីសាស្ត្រស្រាវជ្រាវច្បាស់លាស់ ហើយមាននៅ ហើយឲ្យខ្វះខាតនូវសំអាងហេតុសម្រាប់ការសន្និដ្ឋាន ព្រោះថាមានតែការត្រួតពិនិត្យទៅលើអត្ថបទប៉ុណ្ណោះ ដែលនិយាយអំពីសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះខ្ញុំគិតថានៅក្នុងដំណាក់កាលនេះ គឺវាជាការមិនសមស្រប ឬក៏មិនសមរម្យគ្រប់គ្រាន់ដើម្បីបញ្ចូលទៅក្នុងឯកសារភស្តុតាងនោះឡើយ។ សូមអរគុណ។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន មេធាវី ខៀវ សំផន អត់មានការកត់សម្គាល់អីទេ លោកប្រធាន។

[១០:០៨:៤៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

ខ្ញុំសូមឆ្លើយតបដោយខ្លី ទៅមេធាវី នួន ជា លោកប្រធាន។ ពីព្រោះថាសហភាតារបស់ខ្ញុំ មេធាវី កូប៉េ នេះគាត់ដូចជាច្រឡំអំពីការពិភាក្សាដើម្បីទទួលយកជាភស្តុតាង ហើយនិងតម្លៃនៃភស្តុតាង គឺថាយើងត្រូវគិតអំពី បើនិយាយពីតម្លៃជាភស្តុតាងនេះ គឺថាយើងអាចគិតបានថា អ្វីដែលសំណើ តាមសំណើរបស់ខ្ញុំហ្នឹង គឺប្រើតាមវិធាន<៨៣>នេះ គឺថាយើងអាចទទួលយកបាន។ ក៏ប៉ុន្តែបើនិយាយអំពីតម្លៃនៃភស្តុតាងនេះគឺ ត្រូវឲ្យមេធាវី នួន ជា គាត់ត្រូវពិភាក្សាអំពីតម្លៃនៃភស្តុតាងនេះ។ ហើយសំណើរបស់ខ្ញុំនេះ បើយើងនិយាយអំពីវិធីសាស្ត្រនៃការស្រាវជ្រាវ ហើយពីភាពពាក់ព័ន្ធអីនេះ គឺវាច្បាស់ហើយ

មានភាពពាក់ព័ន្ធ។ អ៊ីចឹងអាស្រ័យលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះទេ តើផ្ដល់តម្លៃជាភស្តុតាងប៉ុនណា អីប៉ុនណីនោះនោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសង្ខេបដោយខ្លីទេ វាជាការឆ្លើយតបដ៏គួរចាប់អារម្មណ៍មួយ។ ខ្ញុំគិតថា ភស្តុតាដែលពាក់ព័ន្ធខ្លាំង ហើយនិងមានភាពសំខាន់ខ្លាំង ត្រូវបានអង្គជំនុំជម្រះបដិសេធ <ហើយ ខ្ញុំគិតថា>សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី គាត់<ក៏>ពេញចិត្ត<ដែរ>។ ខ្ញុំនិយាយអំពីឯកសាររបស់ រ៉ូប៊ីត លឹមគិន។ ខ្ញុំគិតថា អ្វីដែលសហមេធាវីនាំមុខតំណាងរដ្ឋប្បវេណីធ្វើនោះជារឿងចម្លែកណាស់។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបម្ដងទៀតដើម្បីកំណត់ត្រាប្រតិចារឹក។ ការកំណត់សម្គាល់របស់លោកមេធាវី កូប៉េ ដែលលើកឡើងពាក់ព័ន្ធជាមួយនឹង លឹមគិន នេះ មើលទៅវាដូចមិនសមស្របទាល់តែសោះ អ៊ីចឹងខ្ញុំសូមឲ្យកត់បញ្ចូលក្នុងប្រតិចារឹកសវនាការ។

[១០:១១:០២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណរាល់មតិលើកឡើងរបស់ភាគី ពាក់ព័ន្ធនឹងបញ្ហាពីរដែលអង្គជំនុំជម្រះដាក់ពិភាក្សាព្រឹកមិញ -- ដាក់ពិភាក្សានេះ។ ហើយអង្គជំនុំជម្រះនឹងយកមតិយោបល់ទាំងនេះ ទៅពិនិត្យពិចារណា ចេញសេចក្ដីសម្រេចលើសំណើនេះឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

*(សម្រាករយៈពេលខ្លី)*

សួស្ដីលោកសាក្សី 971 មានវត្តមាននៅ?

**2-TCW-971៖**

បាទ មានហ្នឹង។ មានហើយលោកប្រធាន ជម្រាបសួរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយដូចស្រស់បស់ណាស់ថ្ងៃនេះ ដូចមិនអីទេណ៎ា អាចមកធ្វើសវនាការបានណ៎ា?

**2-TCW-971៖**

បាទ ទ្រាំធ្វើឲ្យផុតទៅ ចប់ទៅ។ បើទោះបីរោយចង្កេះអីយ៉ាងណា ក៏ចេះតែទ្រាំទៅ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងឥឡូវអ៊ីចេះ វាដោយសារខាងណោះបានធ្វើការងារផ្សេងដែរ អ៊ីចឹងឥឡូវនេះសម្រាក អ៊ីចឹងចង់ឲ្យប្រាប់ថាសម្រាកសិន ១៥នាទី ហើយចាំដល់ម៉ោងដប់ ម្ភៃប្រាំនាទី សូមអញ្ជើញចូលវិញណា។

បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់ និងម្ភៃប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកសិនចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:២៩ នាទី)*

[១០:២៩:២៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការតទៅនេះបន្តស្តាប់សក្ខីកម្មសាក្សី 2-TCW-971។

សួស្តីលោកសាក្សី តើលោករៀបចំខ្លួនហើយនៅ?

**2-TCW-971៖**

បាទ រៀបចំរួចហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយលោកមេធាវី ម៉ម រិទ្ធា លោកមានវត្តមាន ត្រៀមខ្លួននៅ?

**លោក ម៉ម រិទ្ធា៖**

បាទ លោកប្រធានត្រៀមរួចរាល់អស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅមេធាវីការពារក្តី លោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក រ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[១០:៣០:៤៤]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក រ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្ដីលោកសាក្សី!

**2-TCW-971៖**

**ឆ៖** បាទ សួស្ដី។

**ស៖** ខ្ញុំនឹងបន្តសួរសំណួរទៅកាន់រូបលោក បន្តពីអ្វីដែលខ្ញុំបានសួរកាលពីសប្ដាហ៍មុន។ ខ្ញុំសូមរំឭកលោកផងដែរ នៅពេលដែលខ្ញុំសួរសំណួរទៅកាន់លោក គឺថា លោកបានឆ្លើយអំពីការកត់សម្គាល់របស់លោក នៅពេលដែលលោកទៅដល់ភូមិភាគពាយ័ព្យនៅបាត់ដំបង នៅថ្ងៃទី០១ ខែមករា ១៩៧៨។ លោកបានជម្រាបជូនអង្គជំនុំជម្រះថាលោកបានកត់សម្គាល់ថា ប្រជាជននេះមិនមានចំណីអាហារហូបគ្រប់គ្រាន់ទេ បើទោះណាមានស្រូវអង្ករគ្រប់គ្រាន់នៅក្នុងឃ្លាំងក៏ដោយ។ ហើយលោកក៏បានឆ្លើយថា លោកនិងអ្នកដែលទៅពីភូមិភាគនិរតីហ្នឹងគឺថា បានចែកចាយស្រូវអង្ករ ហើយប្រជាជនសប្បាយចិត្តមែនទែន។ ខ្ញុំមានសំណួរពីរបីសួរភ្ជាប់ទៅនឹងបញ្ហានេះ លោកសាក្សី។ លោកបាននិយាយអំពីស្រូវអង្ករដែលគេបានរក្សាទុកក្នុងឃ្លាំង ហើយដែលលោកបានឃើញ។ តើលោកបានឃើញគេទុកស្រូវអង្ករនៅក្នុងឃ្លាំងហ្នឹងនៅឯណាដែរ? តើគេរក្សាទុកស្រូវអង្ករហ្នឹង នៅថ្នាក់គោលមែនទេ?

*(មានបញ្ហាប្រព័ន្ធអ៊ីនធឺណែត)*

[១០:៣៣:០៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមឆ្លៀតឱកាសនេះ លោកមេធាវី កូប៉េ សូមលោកផ្ដល់ឯកសារយោងផងដើម្បីឱ្យយើងដឹងអំពីទីតាំងដែលលោកបានលើកឡើងនេះ។ ពេលដែលយើងអានប្រតិចារឹកទៅ យើងអត់អាចដឹងអត្តសញ្ញាណមនុស្សដែលលោកចង់និយាយ ហើយនិងទីតាំងកន្លែងដែលលោកនិយាយហ្នឹងទេ។

**លោក រ៉ិចទ័រ កូប៉េ៖**

វាជាសេចក្ដីព្រាងប្រតិចារឹកនៅថ្ងៃទី០៩ <ខែធ្នូ> ២០១៦ នៅម៉ោង១០:១៤នាទី ដែលគាត់បាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និយាយអំពីការរក្សាទុកស្រូវអង្ករនៅក្នុងឃ្លាំងមួយនៅថ្មគោល។ ហើយខាងក្រោមនេះបន្តិចនៅម៉ោង ១០:១៦នាទី គាត់បានឆ្លើយថា ប្រជាជនសប្បាយចិត្តណាស់នៅពេលដែលពួកគាត់ចែកស្រូវអង្ករទៅឲ្យប្រជាជន។ ហើយគាត់ក៏នៅម៉ោង១០:១០នាទីពេលព្រឹកនោះ គាត់បាននិយាយថា នៅម៉ោង១០:១១នាទី គាត់និយាយថា ប្រជាជនមិនមានស្រូវអង្ករហូបគ្រប់គ្រាន់ទេ ហើយគាត់មិនដឹងថា ហេតុអ្វីបានជាគេទុកស្រូវអង្ករធ្វើអី? ហើយហេតុអ្វីគេមិនចែកស្រូវអង្ករទៅឲ្យប្រជាជនហូប? នេះគឺជាសម្រង់ប្អូន ដកស្រង់ចេញពីប្រតិចារឹកកាលពីសប្តាហ៍មុន ហើយក៏មានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ផងដែរ។

*(មានបញ្ហាប្រព័ន្ធអ៊ីនធឺណេត)*

[១០:៤០:០៦]

**ប្រធានអង្គជំនុំ៖**

សួស្តី លោកសាក្សី!

**2-TCW-971៖**

បាទ សួស្តី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយរវល់តែដាច់អ៊ីចឹង ដឹងពេលណាបានចប់នោះ។

**2-TCW-971៖**

បាទ ចង់តែចប់ឆាប់។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីសាជាថ្មី លោកសាក្សី។ ខ្ញុំដឹងថា លោកស្តាប់ខ្ញុំមិនបានទេ សំណួរសួរពីមុននេះ។ កាលពីសប្តាហ៍មុន លោកផ្តល់សក្ខីកម្មថា លោកផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ក្រោយពេលលោកទៅដល់បាត់ដំបង នៅថ្ងៃទី០១ ខែមករា ១៩៧៨។ លោកបាននិយាយអំពីការកត់សម្គាល់របស់លោក។ លោកថា ប្រជាជនមិនមានម្ហូបអាហារគ្រប់គ្រាន់ បើទោះបីមានស្រូវនៅក្នុងឃ្លាំងក៏ដោយ ហើយក្រោយមក លោកបានចែកស្រូវអង្ករទៅឲ្យប្រជាជន ដែលលោកបានឃើញនៅក្នុងឃ្លាំង

ហ្នឹង ហើយប្រជាជនសប្បាយចិត្តណាស់។ អ៊ីចឹងខ្ញុំសូមសួរសំណួរខ្លះៗ ពាក់ព័ន្ធទៅនឹងស្រូវ អង្ករដែលលោកបានរកឃើញនៅក្នុងឃ្លាំង។ លោកថា ឃ្លាំងហ្នឹងគឺមានទីតាំងនៅថ្មគោល តើលោកអាចរៀបរាប់ជូនអង្គជំនុំជម្រះបានទេ លោករកឃើញថា មានស្រូវទុកនៅក្នុងឃ្លាំងនៅថ្មគោល មែនទេ?

[១០:៤១:៣៨]

2-TCW-971៖

**ឆ៖** បាទ សូមបញ្ជាក់ជូនលោកមេធាវីមួយសាទៀតឲ្យច្បាស់។ ពាក្យថា "ប្រជាពលរដ្ឋអត់បាយ" គឺជាសម្តីរបស់អ្នកដែលគេប្រើឲ្យខ្ញុំទៅ ជាពាក្យសម្តីរបស់ តាម៉ុក ដែលគាត់ប្រើខ្ញុំ ពីតាកែវជាមួយនឹង តាចាយ ឲ្យមកមើលនៅបាត់ដំបង ឮថាប្រជាពលរដ្ឋអត់បាយ ហើយនិងអ្នកខ្លះ គេឃុំឃាំងមែនឬ អ្អែងទៅឲ្យរហ័ស។ បាទ សូមលោកមេធាវី ស្តាប់ឲ្យច្បាស់។ "ឲ្យទៅឲ្យរហ័ស" គឺចេញពីម៉ោងមួយដណ្តប់ថ្ងៃ ឲ្យដល់នេះម៉ោងបួនព្រឹក។ នេះៗ ជាពាក្យសម្តីរបស់ តាម៉ុក ដែលគាត់បញ្ជាឲ្យខ្ញុំ និង តាចាយ មកមើល បញ្ជា តាចាយ និងខ្ញុំ ឲ្យមកមើល តើពិត ឬមិនពិត។ ហ្នឹងៗជាពាក្យសម្តីរបស់គាត់ដែលគាត់ៗនិយាយ។ តែដល់ទៅជាក់ស្តែង ខ្ញុំមកដល់ហើយ គាត់ តាម៉ុក ហ្នឹងបញ្ជាឲ្យ តាចាយ ប្រើខ្ញុំទៅមើលនៅដូនទាវ។ ពេលដែលខ្ញុំទៅដល់ដូនទាវ ចង់ដឹងថាតើមានមនុស្សគេឃុំឃាំងមែនឬ ហើយមានមនុស្សអត់បាយ មែនឬទេ។ ពេលនុ៎ងខ្ញុំចូលទៅដល់សហករណ៍ ចូលទៅដល់សហករណ៍ អ្នកដែលរស់នៅក្នុងសហករណ៍នោះ គេដាំបាយហូបរួមគ្នា មានឆ្នាំងធំៗ។ ការហូបចុករបស់ផងគេ មិនជាអត្តខាត់ទេ។ អាហ្នឹងខ្ញុំបរិយាយឲ្យវែងបន្តិចចុះ គឺមានការហូបចុកគ្រប់គ្រាន់។

[១០:៤៣:១៨]

ឯ ខ្ញុំបានពង្រឹងថែមថា ធ្វើយ៉ាងណាពីថ្ងៃនេះតទៅ សូមឲ្យរក្សារបបមួយនាក់ ក្នុងមួយនាក់មួយកំប៉ុងជារៀងរហូត កុំឲ្យមានការចុះថយ។ ម្យ៉ាងទៀត ចំពោះកងចល័តដែលគេប្រមូលផ្តុំ មិនមែនមានមនុស្សជាប់ឃុំឃាំងទេ សូមលោកមេធាវី លោកស្តាប់។ មនុស្សគេប្រមូលផ្តុំនៅធ្វើការតាមកង អាហ្នឹងគេហៅថា "កងចល័ត"។ ហ្នឹងគឺមនុស្សដែលគេប្រមូលផ្តុំ មិនមែនជាមនុស្សជាប់ឃុំទេ ជាប់ឃុំនៅកន្លែងការងារ គេហៅថា "ការដ្ឋានកងចល័ត"។ ដល់ចំពោះអ្នកដែលនៅតាមកងចល័ត មានការខ្វះខាតហូបមិនគ្រប់ ប៉ុន្តែមិនមែនអត់ទេ។ ខ្វះខាតដោយសារ មួយ បញ្ហាដឹកជញ្ជូន មធ្យោបាយអត់គ្រប់គ្រាន់។ ដល់អ៊ីចឹងខ្ញុំឃើញរបៀបនេះ ខ្ញុំក៏និយាយប្រាប់ថា ចំពោះអ្នកដែលធ្វើការនៅក្នុងកងចល័តប្រមូលផ្តុំ សូមលោករំសាយឲ្យគេទៅផ្ទះវិញ។ នេះតាមបញ្ជារបស់ តាចាយ ដែលគាត់ប្រាប់ឲ្យខ្ញុំទៅៗធ្វើការនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កន្លែងហ្នឹង។ អ្នកដែលនៅក្នុងកងចល័ត រំសាយ ឲ្យគេទៅផ្ទះវិញឲ្យអស់។ ឯអ្នក--

**ស៖** នៅម៉ោង១០:១១ កាលពីសប្ដាហ៍មុននោះ លោកបានឆ្លើយថា លោកមិនយល់ថា ហេតុអ្វីបានជាគេទុកស្រូវចោល អង្ករចោលនៅក្នុងឃ្លាំងហើយ អត់ចែកឲ្យប្រជាជនហូប។ ហើយលោកបានឆ្លើយថា “អ្វីដែលខ្ញុំឃើញ គឺថាខ្ញុំឃើញគេទុកអង្ករចោលក្នុងឃ្លាំងហ្នឹងយូរមកហើយ។ អ៊ីចឹងស្រូវហ្នឹងវាខូចគុណភាព។” ហើយ<បន្ទាប់មកលោក>បាននិយាយថា “<ហើយដូចខ្ញុំបាននិយាយអ៊ីចឹង> នៅកន្លែងខ្លះប្រជាជនមិនមានចំណីអាហារហូបគ្រប់គ្រាន់ទេ។”

មិនមានការបកប្រែ ឬក៏យ៉ាងម៉េចលោកប្រធាន?

[១០:៤៥:៣៧]

*(មានបញ្ហាបច្ចេកទេស)*

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤៨:០២]

**ប្រធានអង្គជំនុំ៖**

សួស្ដីលោកសាក្សី!

**2-TCW-971៖**

បាទៗ។

**ប្រធានអង្គជំនុំ៖**

បាទយើងបន្តទៀត សាកល្បងបន្តទៀតមើល ព្យាយាមបន្តិចមើលក្រែងលោបានឆាប់ចប់ណា។

**2-TCW-971៖**

បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ ហើយសូមរៀបចំសំណួរលោកសាជាថ្មីម្ដងទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី គឺនិយាយអំពីការអត់ឃ្លានរបស់ប្រជាជននៅភូមិភាគពាយ័ព្យ លោកថា តាម៉ុក ជាអ្នកនិយាយអ៊ីចឹង។--

**2-TCW-971៖**

**ឆ៖** បាទៗ។

[១០:៤៨:៤៥]

**ស៖** ហើយលោកកាលពីសប្តាហ៍មុននេះក៏បាននិយាយផងដែរថា លោកមិនយល់ ថាហេតុអ្វីបានជាគេទុកអង្ករចោលនៅក្នុងឃ្លាំង ហើយមិនចែកចាយទៅឱ្យប្រជាជន។ ហើយនៅពេលដែលលោកយកអង្ករទៅចែកប្រជាជននោះ ប្រជាជនត្រេកអរណាស់។ តើនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ នេះជារឿងមួយទៀតដែលនៅថ្មគោល រឿងវាពីរ។

**ស៖** លោកបានលើកឡើងនិយាយអំពីតំបន់មួយចំនួន ដូចជាថ្មគោល ដូចជាវាលទ្រា ហើយនិងដូនទាវ។ ឥឡូវនេះយើងនិយាយអំពីថ្មគោលមុនសិន។ ហើយនៅថ្មគោលនេះ យើងនិយាយអំពីការទុកអង្ករនៅក្នុងឃ្លាំងដែលលោកបានឃើញនោះ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ឃ្លាំងដែលនៅថ្មគោល<ដែលមានស្រូវអង្ករពេញ>ហ្នឹង វានៅកន្លែងណាឱ្យពិតប្រាកដនោះ?

**ឆ៖** បាទ ឃ្លាំងថ្មគោលគឺនៅៗនឹងថ្មគោលហ្នឹងតែម្តង នៅនឹងផ្សារថ្មគោលចាស់ហ្នឹង។ ខ្ញុំមិនដឹង*(ឮមិនច្បាស់)* នៅនឹងថ្មគោល។

**ស៖** តើឃ្លាំងនេះមានទំហំប៉ុន្មានដែរ? ហើយលោកបានរកឃើញអង្ករគេទុកនៅក្នុងឃ្លាំងនៅថ្មគោលនោះចំនួនប៉ុន្មានដែរ?

**ឆ៖** បាទ លោកមេធាវី ខ្ញុំមិនបានវាស់វែង ដឹងទំហំឃ្លាំងនោះប៉ុន្មាន ហើយមិនគិត បានគិតជាទម្ងន់តោនអង្ករ ឬក៏សម្ភារៈហ្នឹងប៉ុន្មានដែរទេ។ ឃើញនៅក្នុងឃ្លាំងហ្នឹង មិនបានគិតគូរថ្លឹងថ្លែងវាស់វែងអីច្បាស់លាស់។

[១០:៥១:០៦]

**ស៖** ខ្ញុំយល់ហើយលោក ប៉ុន្តែលោកគ្រាន់តែប្រាប់ថាតើអង្ករប្រហែលជាប៉ុន្មាន ដែលលោកបានឃើញនៅក្នុងឃ្លាំងនោះ? ឃ្លាំងនោះទំហំប៉ុនណា?

**ឆ៖** ខ្ញុំមិនឱ្យតម្លៃត្រូវ មិនដឹងជាប៉ុន្មាន។ នៅក្នុងហ្នឹងគេមានផ្ទុកអង្ករផង មានពាងស្អុរផង មានសម្ភារៈជាក្រណាត់ស្អីខ្លះដាក់ចម្រុះគ្នា ខ្ញុំមិនបានគិតថាតើអង្ករប៉ុន្មានអីប៉ុន្មាន គ្រាន់តែឃើញមានចំនួន មួយចំនួន។

**ស៖** ប្រសិនបើលោកចាំ តើថ្មគោលហ្នឹងចំណុះឱ្យតំបន់ណាដែរ នៅក្នុងភូមិភាគពាយ័ព្យនោះ?

**ឆ៖** បាទ លោកមេធាវីកាលខ្ញុំទៅដល់ហ្នឹង គឺកន្លែងហ្នឹងគេដាក់នៅក្នុងតំបន់៣។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ហើយយើងក៏ទើបតែនិយាយគ្នាអម្បាញ់មិញដែរ អំពីដូនទាវ តើដូនទាវហ្នឹងចំណុះឲ្យតំបន់ណាដែរ នៅក្នុងភូមិភាគពាយ័ព្យនោះ?

*(មានបញ្ហាបច្ចេកទេស)*

**លោក វិុចទ័រ កូប៉េ៖**

ខ្ញុំមិនមែនជាអ្នកបច្ចេកទេសទេ លោកប្រធាន ក៏ប៉ុន្តែបើសិនណាជាយើងកុំឃើញរូបគាត់ យើងគ្រាន់តែស្តាប់តែសំឡេង អាចដំណើរការទៅមុខបានល្អ។

[១០:៥៣:២២]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគាំទ្រសំណើសុំរបស់ គំនិតរបស់មេធាវីការពារក្តី។ បើសិនណាជាយើងផ្តាច់វីដេអូចោលទៅ ហើយស្តាប់តែសំឡេងគាត់ ប្រហែលជានឹងដំណើរការទៅបាន យ៉ាងហោចណាស់ក៏បានស្តាប់សំឡេងដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បើមានសំណើសុំ ហើយសហព្រះរាជអាជ្ញាគាំទ្រអ៊ីចឹង ភាគីដទៃទៀតយល់ស្របដែរឬទេ ឬក៏មានភាគីណាជំទាស់ទៅនឹងការលើកឡើងនេះ? អ៊ីចឹងដើម្បីប្រតិចារឹកគឺថាមិនមានការជំទាស់ទេ ដោយស្នើសុំឲ្យផ្តាច់វីដេអូ តែស្តាប់តែ<សំឡេង>បានហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ដោយមានសំណើពីភាគី ឥឡូវនេះភាគីលើកបញ្ហាហ្នឹងហើយ ហើយវាអត់មានភាគីណាជំទាស់ទេ រួចចុះរៀបចំសួរខាងអ្នកបច្ចេកទេសមើល ឲ្យរៀបចំប្រព័ន្ធនេះគឺមានតែសំឡេងបានហើយ មិនបាច់រូបភាពទេ ក្រែងលោវាបានប្រសើរឡើង អាចធ្វើបានទេ។

*(សម្រាករយៈពេលខ្លី)*

[១០:៥៥:៣៦]

**ប្រធានអង្គជំនុំ៖**

អ្នកបច្ចេកទេសឆ្លើយហើយថា បើប្រើប្រាស់ទោះបីតែសំឡេងនោះ ក៏មិនអាចប្រព្រឹត្តទៅបានដែរ បើបាន១ទាំងសំឡេង ទាំងរូបភាពតែម្តង។

*(មានបញ្ហាបច្ចេកទេស)*

បាទ ឥឡូវយើងសាកល្បងម្តងទៀត ព្រោះឥឡូវថាដំណើរការឡើងវិញហើយ។ ហើយនេះសាកល្បងចុងក្រោយហើយ ប្រសិនបើព្យាយាមទៅៗមិនរួចទេ យើងនឹងរកពិនិត្យលទ្ធភាពផ្សេងទៀតដើម្បីដោះស្រាយនៃដំណើរការសវនាការរបស់យើងថ្ងៃនេះ។ សូមលោកមេធាវីបន្តការងាររបស់លោក។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី យើងនិយាយគ្នាអំពីឃ្លាំងអង្ករដែលរកបានឃើញនៅឯថ្មគោល។ លោកមិនអាចប្រាប់អំពីបរិមាណអង្ករនេះបានទេ ក៏ប៉ុន្តែតើលោកអាចនិយាយបានថា អង្ករដែលលោកបានឃើញនោះ តើវាជាស្រូវ ឬក៏ជាអង្ករដែលលោកឃើញនៅក្នុងឃ្លាំងនោះណា?

**2-TCW-971៖**

**ឆ៖** បាទ ដែលៗខ្ញុំឃើញនៅក្នុងឃ្លាំងហ្នឹងគឺគ្មានស្រូវទេ លោកមេធាវី មានតែអង្ករ ត្រីងៀតពេលខ្លះ ហើយនិងស្ករ និងក្រណាត់អីមួយចំនួន គ្មានស្រូវទេ។

[១០:៥៧:៥៤]

**ស៖** ពាក់ព័ន្ធទៅនឹងទីតាំងភូមិសាស្ត្រវិញ លោកថាថ្មគោលចំណុះឲ្យតំបន់៣ តើលោកធ្លាប់ឮ ឬក៏ស្គាល់កន្លែងមួយទៀតគេហៅថា "ថ្មពួក" ដែរឬទេ?

**ឆ៖** ថ្មពួក--<អត់មាននៅជិតថ្មគោលហ្នឹងផង។ បាទ មិនច្បាស់។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមរៀបសំណួរខ្ញុំឡើងវិញ។ តើលោកដឹងថាមានឃ្លាំងស្រដៀងគ្នានេះ ដែលគេទុកអង្ករពេញៗដែលគេរកឃើញនៅក្នុងតំបន់ពាយ័ព្យ ដូចជានៅភូមិភាគពាយ័ព្យ ដូចជានៅបាត់ដំបង ឬក៏នៅថ្មពួកជាដើមនេះ?

**2-TCW-971៖**

**ឆ៖** បាទ ខ្ញុំអត់ដែលឃើញផង អត់ដឹង។

[១០:៥៩:០៩]

**ស៖** មិនថ្វីទេ លោកសាក្សី។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ចម្លើយលេខ៤ ត្រង់ចម្លើយលេខ៤ លោកបានឆ្លើយថា ក្រោយពីរកឃើញថា មានបញ្ហាខ្វះខាតចំណីអាហារ ហើយនិង "<សម្រាល>ការងារដ៏ធ្ងន់ធ្ងររបស់ប្រជាជន <>អត់ឃ្លានអីចឹង" លោកថាគេបានឲ្យខ្ញុំទៅដោះស្រាយបញ្ហាស្បៀងអាហារ។ សំណួររបស់ខ្ញុំ តើលោក ហើយនិងកម្មាភិបាលមកពីភូមិភាគនិរតីដទៃទៀតនោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចុងក្រោយដោះស្រាយបញ្ហានោះបានឬទេ?

**ឆ៖** បាទ លោកធារី មេធាវី។ ការដោះស្រាយនោះ ខ្ញុំបានទៅធ្វើការដោះស្រាយនៅនឹងឃ្លាំងថ្ម គោលហ្នឹងឯង គឺអញ្ជើញអ្នកជិតខាងហ្នឹង បងប្អូនប្រជាពលរដ្ឋ ហើយនិងកងចល័តដែលនៅធ្វើការជិតហ្នឹង ទៅចែកចាយអង្ករដែលរកឃើញនៅក្នុងឃ្លាំងហ្នឹង។ ហើយឃ្លាំងនោះទៀតគឺ វាមិនមែនបម្រើឲ្យតែប្រជាពលរដ្ឋទេ គឺអ្នកបុគ្គលិកការងារហ្នឹង ក៏នៅហូបចុកជាមួយគ្នា។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ គឺការដោះស្រាយបញ្ហាភ្លាមៗនៅពេលដែលលោកទៅដល់។ ប៉ុន្តែ តើលោកអាចដោះស្រាយបញ្ហាស្បៀងអង្ករនៅក្នុងតំបន់នុ៎ង តើដោះស្រាយជាប្រព័ន្ធនៅពេលក្រោយបានទេ? គឺបានន័យថា ក្រោយពេលដែលមានការបែងចែកស្រូវអង្ករឲ្យប្រជាជនមានអង្ករហូបគ្រប់គ្រាន់ ហើយតើក្រោយមកហ្នឹងលោកមានរៀបចំជាប្រព័ន្ធ ឬក៏ដោះស្រាយឲ្យមានជាប្រព័ន្ធអីទៅលើការបែងចែកស្រូវអង្ករហ្នឹងទេ?

**ឆ៖** បាទ សូមអធ្យាស្រ័យ។ ពេលវេលាវាខ្លី ខ្ញុំគ្រាន់តែបានចូលទៅដល់រយៈកាលខ្លី ខ្ញុំរុករើឃ្លាំងហ្នឹង ហើយហៅអ្នកជិតខាងហ្នឹងមកចែកចាយតែប៉ុណ្ណឹង។ មិនបានប៉ុន្មានផង គេនឹងផ្លាស់ខ្ញុំឲ្យទៅនៅកន្លែងផ្សេងទៀត។ ដូច្នេះការរៀបចំនេះក្នុងមួយវគ្គដែលខ្ញុំបានរៀបចំហ្នឹងគឺតែប៉ុណ្ណឹង តែក្រោយមក មិនមែនមានការកាន់កាប់នៅលើខ្ញុំទៀតទេ។ បាទ សូមអរគុណ។

[១១:០១:២៩]

**ស៖** ខ្ញុំយល់លោកសាក្សី។ ខ្ញុំចង់សួរបន្តទៀត ថាតើលោក ហើយនិងកម្មាភិបាលផ្សេងទៀតហ្នឹងធ្វើយ៉ាងណាដឹងថា មានអង្ករគេស្តុកទុកនៅឃ្លាំងនៅថ្មគោលហ្នឹង? ថាតើលោកធ្វើយ៉ាងណាដឹងថាមានឃ្លាំងនៅថ្មគោល? ព្រោះលោកអត់ទាន់ លោកអត់ស្គាល់ថ្មគោលហ្នឹងច្បាស់ទេ ប៉ុន្តែធ្វើយ៉ាងណាបានលោកស្គាល់ ឬក៏លោកដឹងថា នៅក្នុងឃ្លាំង មានឃ្លាំងនៅថ្មគោល ហើយនៅក្នុងឃ្លាំងហ្នឹងមានអង្ករស្តុកពេញហ្នឹង?

**ឆ៖** បាទ ពេលដែលខ្ញុំទៅដល់មានមនុស្សគេធ្វើការងារនៅនឹងកន្លែងឃ្លាំងហ្នឹង គេនៅកាន់កាប់ហ្នឹងដែរ គេនារីៗ ពួកនារីៗ។ អ៊ីចឹងហើយដឹងតាមរយៈនារីអស់ទាំងនោះ គេប្រាប់ខ្ញុំ ហើយខ្ញុំក៏ចូលទៅពិនិត្យឃើញហើយ ក៏បានចាត់ចែង ចែកចាយ ទាំងអង្ករខូច ទាំងអង្ករមិនខូចហ្នឹង គឺហៅគាត់មកយកតែម្តង បងប្អូនជិតខាង។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយពីអ្នកដែលប្រាប់លោកអំពីការស្តុកទុកអង្ករហ្នឹង តើអ្នកដែលប្រាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកហ្នឹង គាត់មកពីខាងនិរតីដែរមែនទេ?

**ឆ៖** បាទ គឺជានារីដែលគេមកមុន មកមុនខ្ញុំ មកមុនខ្ញុំ គេមកពីខាងស្រែអំបិលមក មកនៅធ្វើការនៅនុំង។

**ស៖** តើលោកស្គាល់ពួកគាត់ទេ?

[១១:០៣:១៩]

**ឆ៖** បែកគ្នាបាត់អស់លោកមេធាវី មិនដឹងទៅណាទេ ចូលជំរំ ចូលអី ខ្លះទៅស្រុកក្រៅ បាត់អស់ហើយ ខ្លះក៏ទៅមិនដឹងឯណាឯណី មានស្លាប់ មានអីខ្លះ បាត់បង់។

**ស៖** បន្ទាប់ពីលោកត្រូវបានគេប្រាប់ គឺថាបន្ទាប់ពីខាងកម្មាភិបាលនារី មកពីខាងនិរតីប្រាប់លោកអំពីឃ្លាំងហ្នឹង តើលោកដឹងទេថា អ្នកណាជាអ្នកបញ្ជាឱ្យទុកអង្ករនៅក្នុងឃ្លាំង គឺបានន័យថា បញ្ជាឱ្យទុក ដោយមិនឱ្យចែកទៅប្រជាជនហ្នឹង? តើលោកដឹងទេ អ្នកណាជាអ្នកចេញបញ្ជាឱ្យរក្សាទុក មិនឱ្យចែកទៅប្រជាជនហ្នឹង?

**ឆ៖** បាទ ខ្ញុំមិនបានដេញដោលសួរ។ ប៉ុន្តែគេមកដល់ ខ្ញុំឃើញគេនៅហ្នឹង ខ្ញុំក៏ចាត់ចែងតែម្តង ដោយសារ តាចាយ គាត់ថា អ្វីដែលនៅសល់ក្នុងហ្នឹងគឺចែកចាយឱ្យគេយកទៅហូប ទោះបីវាខូចក៏ដោយ បើយកទៅហូបកើតក៏កើត បើមិនកើតទេ កុំឱ្យទុក វាអាក្រក់មើល។

**ស៖** កាលពីសប្តាហ៍មុនយើងបាននិយាយអំពីហេតុផល ដែលអាចកើតឡើងមួយចំនួនដែលថា គេទុកអង្ករដែលមិនចែកប្រជាជននោះ។ ឥឡូវនេះខ្ញុំសូមអានឱ្យលោកស្តាប់នូវរបាយការណ៍ប្រចាំសប្តាហ៍របស់តំបន់មួយទៀត គឺតំបន់៥ មិនមែនជាតំបន់របស់លោកទេ។ លោកប្រធាន គឺឯកសារ E3/178, អង់គ្លេសមានលេខ 00342708, ខ្មែរមានលេខ 00275587, បារាំងមានលេខ 002 -- សូមទោស 00623304។ នេះគឺជាអ្វីដែលរបាយការណ៍ប្រចាំសប្តាហ៍ហ្នឹងរៀបរាប់ គឺថ្ងៃ២១ ឧសភា ៧៧ គឺបានរាយការណ៍ដូចតទៅនេះ៖ "ដោយស្វែងរក ហើយនិងរុករកនូវល្បិចរបស់ខ្មាំង គឺថាអង្ករត្រូវបានគេលាក់ទុកនៅភ្នំស្រុក។ អំបិល អង្ករ ត្រូវបានគេទុកនៅស្រុកព្រះនេត្រព្រះ។ ហើយអង្ករ គេលាក់ទុកនៅថ្មពួក។ អង្ករលាក់នៅស្រុកស៊ីសុផុន។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី ទោះបីថាលោកមិនធ្វើការនៅកន្លែងនេះក៏ដោយ ប៉ុន្តែតើលោកធ្លាប់ស្តាប់ឮនៅក្នុងការប្រជុំ ឬក៏នៅកម្មវិធីអ្វីផ្សេងណាមួយ ដែលគេនិយាយថា មានការលាក់ទុកអង្ករនៅភូមិភាគពាយ័ព្យដែរនោះ តើលោកធ្លាប់ឮទេ?

[១១:០៦:៣៦]

**ឆ៖** បាទ ខ្ញុំអត់បានដែលធ្លាប់ឮទេ លោកមេធាវី។ ខ្ញុំទៅហ្នឹង រយៈកាលខ្លីណាស់។ រឿងកើតហេតុអីពីមុន ក៏ខ្ញុំអត់បានដឹង។ ដូច្នេះអារឿងព័ត៌មាន ថាមានលាក់អង្ករលាក់អីនៅឯណា ស្អីកន្លែងប៉ុន្មាន ប៉ុន្មានកន្លែងអំមិញ ខ្ញុំអត់បានដឹង ទទួលព័ត៌មានទេ។

**ស៖** តើលោកធ្លាប់ឮថា គេយកអង្ករចេញពីពាយ័ព្យទៅប្រទេសថៃទេ?

**ឆ៖** បាទ អត់ ខ្ញុំអត់ដឹង ខ្ញុំទៅក្រោយគេ។

**ស៖** ខ្ញុំមានសំណួរមួយទៀត ថាតើលោកធ្លាប់ស្ដាប់ឮនៅពេលប្រជុំ ថាតើអ្នកណាជាអ្នកទទួលខុសត្រូវលើការស្តុកទុកអង្ករនៅកន្លែងផ្សេងៗទាំងអស់នោះ? តើលោកធ្លាប់ឮឈ្មោះ ហាំ ដែរឬទេ?

**ឆ៖** បាទ អត់ លោកមេធាវី អត់ស្គាល់ទេ ខ្ញុំទៅក្រោយទាំងអស់ ក្រោយគេ អត់ដឹងរឿងអីសោះ។ ឈ្មោះនេះ ឈ្មោះនោះអី លាក់អង្ករឯណា អត់បានដឹង។

**ស៖** មិនអីទេលោកសាក្សី។ ឥឡូវនេះខ្ញុំសូមបន្តទៅស្ថានភាពធ្វើការងារវិញម្តង គឺនៅភូមិភាគពាយ័ព្យ ក៏ដូចជានៅកន្លែងមួយចំនួនទៀត។ តើលោកអាចប្រាប់បានទេ ថាលោករកឃើញអ្វីទាក់ទងទៅនឹងស្ថានភាពការងាររបស់ប្រជាជននៅភូមិភាគពាយ័ព្យនោះ?

**ឆ៖** មិនយល់សំណួរ។

[១១:០៨:៥៧]

**ស៖** ឥឡូវនេះខ្ញុំអានទៅលើអ្វីដែលលោកបានឆ្លើយ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក។ សំណួរចម្លើយ៦៣ លោកបានឆ្លើយថា៖ “នេះគឺជាហេតុផលដែលគេបញ្ជូនពួកខ្ញុំទៅមើលថាអ្នកណាខ្លះឲ្យប្រជាជនធ្វើការហួសកម្លាំង ហូបមិនឆ្អែតជាដើម។” ហើយនៅក្នុងសំណួរចម្លើយទី៤ លោកឆ្លើយថា៖ “គេបញ្ជូនលោកទៅសម្រួលការងារចំពោះអ្នកទាំងនោះ។” ហើយនៅក្នុងសំណួរចម្លើយ៦៥ លោកនិយាយថា៖ “នៅពេលដែលខ្ញុំទៅដល់ ឲ្យមនុស្សប្រុសស្រីនៅក្នុងកងចល័ត និងកងកុមារ ត្រឡប់ទៅផ្ទះរបស់ពួកគេវិញ។” ដូច្នេះខ្ញុំចង់សួរ ថាតើលោកធ្វើយ៉ាងណា ដើម្បីសម្រាលការងាររបស់មនុស្សនៅទីនោះ?

**ឆ៖** បាទ កាលពីកាលនុ៎ង ទី១ គឺទៅដល់ទៅ ឃើញចំណីអាហារក្នុងឃ្លាំងដែលនៅសល់ហ្នឹងបានចាត់ចែងចែកចាយឲ្យអស់ កុំឲ្យមានស្តុកទុក។ រួច២) កងកុមារ និងកងចល័ត ដែលធ្វើការប្រមូលផ្តុំហ្នឹង ខ្ញុំបានសួរមតិទៅ តាចាយ, តាចាយ គាត់ថា ប្រកាសឲ្យគេទៅផ្ទះវិញទៅ ឲ្យគេទៅផ្ទះវិញឲ្យអស់ទៅ។ ហើយពេលវេលានេះ ខ្ញុំមិនបាននៅគ្រប់គ្រងហ្នឹងយូរទេ។ ប្រកាសហើយ គាត់ទៅ ឲ្យគាត់

ទៅផ្ទះវិញ។

**ស៖** តើអ្នកណាខ្លះ ដែលលោកឲ្យទៅផ្ទះវិញ?

**ឆ៖** ខ្ញុំម៉េចនឹងចាំ មនុស្សច្រើនម្ល៉េះ។

**ស៖** តើ -- ខ្ញុំយល់ ប៉ុន្តែខ្ញុំចង់ដឹងថា តើគាត់ជាអ្នកធ្វើការនៅកងចល័ត ឬ<កងកុមារ>? តើអ្នកណា តើមនុស្សណាដែលលោកបញ្ជូនត្រឡប់ទៅវិញ?

[១១:១១:២០]

**ឆ៖** មនុស្សដែលខ្ញុំឲ្យត្រឡប់ទៅតាមគេហដ្ឋាន តាមគ្រួសារវិញ គឺកងចល័ត ហើយនិងកងកុមារ ដែលនៅប្រមូលផ្តុំនឹងថ្មគោលហ្នឹងឯង។

**ស៖** ឥឡូវនេះខ្ញុំសួរបន្តទៀត ហើយខ្ញុំនឹងអានទៅលើអ្វីដែលលោកឆ្លើយ។ នៅសំណួរចម្លើយ ៦៣ លោកនិយាយថា៖ "មូលហេតុដែលគេបញ្ជូនទៅ គឺដើម្បីឲ្យទៅមើលអ្នកដែលធ្វើការហួសកម្លាំង ហូបមិនឆ្អែត។ ហើយលោកឆ្លើយថា៖ យើងត្រូវទៅនោះ ដើម្បីលុបបំបាត់អំពើទាំងអស់នោះ ប៉ុន្តែយើងមិនទាន់បានធ្វើផង វៀតណាមក៏មកដល់។" តើលោកចង់មានន័យយ៉ាងម៉េច នៅពេលដែលលោកថា យើងទៅ លុបបំបាត់នូវអំពើទាំងអស់នោះ?

**ឆ៖** ចង់និយាយថា ទៅដល់ហ្នឹង គឺឈប់ឲ្យមានការធ្វើការងារហួសកម្លាំង ហើយឲ្យមានការហូបចុកគ្រប់គ្រាន់ ហើយមនុស្ស មិនចង់ឲ្យមានការប្រមូលផ្តុំ។ នេះជាគោលបំណងដែលទៅ។

**ស៖** តើលោកដឹងថា អ្នកដែលលោកឲ្យត្រឡប់ទៅផ្ទះវិញហ្នឹង ពួកគេអាចស្នាក់នៅផ្ទះរបស់ពួកគេបន្ត ឬមួយក៏យ៉ាងណា?

**ឆ៖** បាទ ខ្ញុំមិនបានដឹង លោកមេធាវី ព្រោះអីមិនស្គាល់ផ្ទះម៉ែ ផ្ទះឪ បងប្អូនកូនចៅហ្នឹង ដឹងមកពីខាងណាខ្លះទេ។ គ្រាន់តែឃើញ គេនៅក្នុងកងហ្នឹង រំសាយ ប្រកាសថា ផ្ទះនៅឯណា ឲ្យទៅនុ៎ង។

**ស៖** ហើយនៅពេលដែលលោកឲ្យទៅហ្នឹង គ្រប់គ្នាក៏គេទៅ អ៊ីចឹងមែនទេ?

**ឆ៖** បាទ បែកគ្នាខ្ចាត់ខ្ចាយហើយ បែកទៅ បែកខ្ញែកគ្នាទៅតាមផ្ទះ តាមសម្បែង។

[១១:១៣:៣៨]

**ស៖** លោកសាក្សី ឥឡូវនេះខ្ញុំសុំអាននូវកិច្ចសម្ភាសន៍មួយទៀត ដែលរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច <អៀង ធីរិទ្ធ>បានឆ្លើយទៅនឹងអ្នកសារព័ត៌មានអាមេរិក គឺឯកសារ E3/659 អង់គ្លេសមានលេខ 00182322, ខ្មែរមានលេខ 00741117 ដល់ 118, បារាំងមានលេខ <00743047>។ នេះគឺជាអ្វី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែល អៀង ធីរិទ្ធ ឆ្លើយ ហើយខ្ញុំចង់ឲ្យលោកមានប្រតិកម្មចំពោះចម្លើយនេះ។ "ចាស ពិតហើយខ្ញុំធ្វើដំណើរ ដើម្បីមើលស្ថានភាពរបស់ប្រជាជន។ ហើយនៅពេលនោះ នៅពេលដែលខ្ញុំត្រឡប់ភ្នំពេញវិញ ខ្ញុំរាយការណ៍ទៅមេដឹកនាំថា វាមានបញ្ហា<ចម្លែក>ខ្លះនៅតាមខេត្ត ឧទាហរណ៍នៅបាត់ដំបង។ ខ្ញុំឃើញច្បាស់ថា ពួកគេឲ្យប្រជាជនទៅធ្វើការនៅវាលស្រែឆ្ងាយពីភូមិ ហើយពួកគេគ្មានផ្ទះសម្បែង។ ហើយខ្ញុំឃើញថា ពួកគេគ្មានផ្ទះសម្បែង ហើយពួកគេឈឺ។ ខ្ញុំរាយការណ៍ទៅមេដឹកនាំរបស់ខ្ញុំ គឺរាយការណ៍ទៅនាយករដ្ឋមន្ត្រី។ វាចម្លែកណាស់ វាមិនមែនជារឿងធម្មតាទេ វាប្រាកដជាមានបញ្ហាអ្វីមួយមិនប្រក្រតី។"

ហើយក្រោយបន្តិចគឺឆ្លើយថា៖ "នៅពេលនោះខ្ញុំប្រាប់មេដឹកនាំថា មានបញ្ហានៅក្នុងខេត្ត ព្រោះខ្ញុំដឹងថាមិនមែនជាបញ្ហារបស់នាយករដ្ឋមន្ត្រី គឺមិនមែនឲ្យក្មេង ឲ្យមនុស្សចាស់ ឲ្យស្ត្រីមានផ្ទៃពោះ និងអ្នកបំបៅកូនទេ គឺថាខ្ញុំឃើញទាំងអស់គ្នាតែម្តង មិនមែនតែពួកនេះទេ គឺនៅធ្វើការកណ្តាលវាលថ្ងៃនៅក្រោមព្រះអាទិត្យដ៏ក្តៅ ហើយខ្ញុំឃើញមានអ្នករាក អ្នកគ្រុនចាញ់ ហើយខ្ញុំរាយការណ៍ប្រាប់គាត់។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកអាចបញ្ជាក់បានទេថា នៅពេលដែលលោកទៅដល់បាត់ដំបង គឺវាមានស្ថានភាពប្រហែលនេះដែរឬទេ?

[១១:១៥:៥៧]

**ឆ៖** ពេលដែលខ្ញុំទៅដល់បាត់ដំបង ខ្ញុំមិនបានចុះសព្វទីកន្លែង។ ធ្វើដំណើរតាមផ្លូវពីថ្មគោលទៅដល់មង្គលបុរី ឃើញមានអ្នកធ្វើការនៅកណ្តាលវាលស្រែ អត់ទីជម្រកមែនកងចល័ត។ នៅប្រមូលផ្តុំដូចខ្ញុំបានជម្រាបខាងលើអ៊ីចឹង គ្មានផ្ទះនៅទេ គឺគេនៅតាមរោងតាមអី។

**ស៖** ខ្ញុំដឹងថាលោកមិនទៅគ្រប់កន្លែងនោះទេ។ ប៉ុន្តែតើលោកយល់ស្របជាទូទៅទេ ទាក់ទងទៅនឹងអ្វីដែល អៀង ធីរិទ្ធ បានសង្កេតឃើញថាវាមានបញ្ហាមិនប្រក្រតីនៅតាមខេត្តនោះ?

**ឆ៖** បាទ របាយការណ៍គាត់ហ្នឹងគឺខ្ញុំធ្លាប់ឃើញអ៊ីចឹងដែរ ឃើញការធ្វើការនៅកណ្តាលវាលកណ្តាលអីហ្នឹង ដូចគាត់បាននិយាយមែន។

**ស៖** ហើយថាតើលោកយល់ស្របជាមួយចំណុចផ្សេងទៀតទេ នៅក្នុងកិច្ចសម្ភាសន៍ដែល អៀង ធីរិទ្ធ បានឆ្លើយនោះ?

**ឆ៖** ចំណុចណាខ្លះ ខ្ញុំស្តាប់អត់ទាន់?

**ស៖** ឧទាហរណ៍ដូចជាការសង្កេតរបស់គាត់ដែលថា មានបញ្ហានៅតាមខេត្ត ព្រោះថាអ្វីដែលគាត់ឃើញ គឺវាខុសទៅនឹងការណែនាំរបស់នាយករដ្ឋមន្ត្រី គឺបានន័យថា គាត់សំដៅទៅលើ ប៉ុល ពត។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តើលោកសង្កេតឃើញថា ស្ថានភាពហ្នឹងវាផ្ទុយទៅនឹងគោលការណ៍ណែនាំទាក់ទងទៅនឹងការបំពេញការងារ ឬក៏គោលការណ៍ណែនាំអីផ្សេងៗដែរឬទេ?

[១១:១៨:១១]

**ឆ៖** បាទ សកម្មភាពបើថា ដូចគាត់និយាយហ្នឹង ហើយនិងខ្ញុំឃើញខ្លះ ដូចថាធ្វើការគ្មានទីតាំងរស់នៅស្រួលបួល អាហ្នឹងវាខុសនឹងការណែនាំហើយ។ ធ្វើការខ្លាំង ដូចថាធ្វើការខ្លាំង ហូបចុកមិនគ្រប់គ្រាន់ អាហ្នឹងវា ខ្ញុំក៏ធ្លាប់ឃើញអ៊ីចឹងដែរ។

**ស៖** នៅក្នុងចម្លើយរបស់លោកគឺលេខ៤ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកនោះ លោកក៏បាននិយាយអំពីទំហំការងារ គឺបានន័យថា លោកមិនត្រឹមតែបញ្ជូនត្រឡប់ទៅផ្ទះវិញទេ ប៉ុន្តែលោកនិយាយអំពីការសម្រាលការងារចំពោះអ្នកដែលកំពុងអត់ឃ្លាន។ តើលោកធ្វើយ៉ាងណាដើម្បីសម្រាលការងារ? តើលោកមានវិធានការអ្វីដើម្បីសម្រាលការងារ?

**ឆ៖** ដើម្បីសម្រាលការងារ ខ្ញុំយល់ឃើញថា បើបែកចេញជាក្រុមប្រមូលផ្ដុំទៅនៅធ្វើការតាមផ្ទះ វាមិនធូន់ធូរដូចនៅអ៊ីចឹងទេ ការគ្រប់គ្រងខុសគ្នា។

**ស៖** តើលោកមានចាត់វិធានការដើម្បីកាត់បន្ថយម៉ោងធ្វើការងារក្នុងមួយថ្ងៃទេ?

**ឆ៖** ពេលខ្ញុំទៅនេះ ខ្ញុំមិនទាន់បានរៀបចំកាត់បន្ថយម៉ោងទេ តែគ្រាន់តែថាបានរំសាយកម្លាំងតែប៉ុនន្ទុំងទេ ព្រោះខ្ញុំបានជម្រាបលោកមេធាវីថា ខ្ញុំនៅរយៈកាលខ្លីណាស់ មិនបាននៅយូរ។

**ស៖** ខ្ញុំយល់ តើលោកដឹងថាមានគោលការណ៍ណែនាំអ្វីទាក់ទងទៅនឹងការធ្វើការងារ? ថាតើមានការកំណត់ថា ធ្វើការប៉ុន្មានថ្ងៃ ប៉ុន្មានម៉ោងក្នុងមួយថ្ងៃ ប៉ុន្មានថ្ងៃក្នុងមួយ<ខែ>អ្វីដែរឬទេ?

**ឆ៖** ការបែងចែកពេលវេលាជាកាលវិភាគមិនបានច្បាស់លាស់ កន្លងមក ឃើញគេធ្វើការមិនបានបែងចែក ទៅដល់ម៉ោងដប់មួយហ្នឹងគឺឈប់ ប៉ុន្តែចូលវាមិនទៀង។

**ស៖** ខ្ញុំចង់សួរលោកថា តើមានការណែនាំទាក់ទងទៅនឹងម៉ោងធ្វើការ ថាឲ្យធ្វើការ៨ម៉ោងក្នុងមួយថ្ងៃ និងឲ្យមានការសម្រាក១៥នាទី<ជារៀងរាល់ម៉ោង> ហើយមានការឈប់សម្រាកអាហារថ្ងៃត្រង់ឲ្យបានយូរអីដែរឬទេ?

[១១:២១:១៦]

**ឆ៖** កាលពីជំនាន់នុ៎ង អាកាលវិភាគហ្នឹងគេមិនបានធ្វើច្បាស់លាស់ទេ ក៏ប៉ុន្តែដល់ម៉ោងដប់មួយហ្នឹងគឺសម្រាក សម្រាកត្រឹមម៉ោងមួយកន្លះ ម៉ោងពីរហ្នឹងចូលវិញហើយ ចូលធ្វើការងារ។ ហើយ

ចេះតែដឹងតៗគ្នា មិនបានបែងចែកជាកាលវិភាគអីដាក់ធ្វើការផ្សព្វផ្សាយអីទេ។

**ស៖** ខ្ញុំយល់ច្បាស់ហើយលោកសាក្សី។ យើងបាននិយាយអំពីការដែលលោកព្យាយាមដោះ-ស្រាយស្ថានភាពអាហារ ព្រមទាំងសម្រាលការងារ ចំពោះអ្នកដែលធ្វើការហួសកម្លាំង។ តើលោកដឹងទេ ថាមានការងារ ឬក៏ភារកិច្ចអ្វីរបស់កម្មាភិបាលនិរតីដែលត្រូវ<ធ្វើ> ក៏ដូចជាត្រូវស៊ើបអង្កេត ឬក៏តាមដាន? ថាតើលោកដឹងថា មានវិធានការអ្វីផ្សេងទៀតដែលខាងកម្មាភិបាលនិរតីបានអនុវត្តនៅក្នុងភូមិភាគពាយ័ព្យទេ?

**ឆ៖** បាទ កម្មាភិបាល ឬក៏មនុស្សដែលគេឲ្យទៅធ្វើការនោះ វាមិនមែនទៅតែមួយលើកទេ។ មានគេទៅមុនខ្ញុំខ្លះ ឯខ្ញុំទៅក្រោយខ្ញុំធ្វើតាមការងាររបស់ខ្ញុំ ខ្ញុំដឹងតែប៉ុណ្ណឹង។ ឯខាងគេ ខាងមុន មិនដឹងគេចាត់ចែងម៉េចខ្លះ។ មានទៅមុនទៅក្រោយ។

**ស៖** តើលោកដឹងទេ ថាមានការស្រាវជ្រាវទៅលើការសម្លាប់មនុស្សដោយខុសច្បាប់នៅខាងពាយ័ព្យដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេលោកមេធាវី។

[១១:២៣:១៨]

**ស៖** តើលោកដឹងថា មានកម្មាភិបាលដែលមិនមែនមកពីខាងនិរតីទេ ប៉ុន្តែជាកម្មាភិបាលដែលបញ្ជូនដោយផ្ទាល់ដោយ ប៉ុល ពត ទៅខាងពាយ័ព្យ ដើម្បីស្រាវជ្រាវលើការសម្លាប់ប្រជាជនកម្ពុជាក្រោមដោយ រស់ ញឹម នោះទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងផង។ ទៅដល់ មិនមានដឹងរឿងអស់ហ្នឹងសោះ មិនបានដឹង។

**ស៖** គឺកម្មាភិបាលដទៃទៀត ថាតើ<>មានតែកម្មាភិបាល<>និរតី ឬមួយក៏មានកម្មាភិបាលមកពីខាងផ្សេងមកស្រាវជ្រាវបញ្ហានៅខាងពាយ័ព្យដែរ?

**ឆ៖** ខ្ញុំមិនបានស្គាល់លោកមេធាវី ខ្ញុំដឹងតែក្រុមខ្ញុំទៅប៉ុន្មានក្រោយតែប៉ុណ្ណឹង ហើយមនុស្សមិនស្គាល់គ្នាផងហ្នឹង អត់ស្គាល់គ្នា។ ទោះបីអ្នកទៅពីនិរតី ទៅលើកមុនគ្នាហ្នឹង ក៏អត់ស្គាល់។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ ខ្ញុំគិតថា ខ្ញុំនៅសល់សំណួរនេះមួយទៀត លោកសាក្សីតើលោកដឹងទេថាហេតុផលសំខាន់មួយដែល រស់ ញឹម<អ្នកដឹកនាំនៅភូមិភាគពាយ័ព្យ> ត្រូវបានចាប់ខ្លួន<ដោយសារតែ>គាត់បានចូលរួមនៅក្នុងការសម្លាប់ប្រជាជនខ្មែរកម្ពុជាក្រោម? តើលោកដឹងអំពីបញ្ហានេះទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** រឿង រស់ ញឹម រស់ អីហ្នឹងខ្ញុំអត់បានដឹងទេ អត់ដឹងសោះ។ ដឹងតែគេឲ្យខ្ញុំទៅក្រោយហ្នឹងគឺទៅ មិនដឹងថាពីណាធ្វើការពីមុនមក ខ្ញុំអត់បានដឹងផង។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំគ្រាន់តែចង់សុំឯកសារយោងនៅពេលដែលគាត់និយាយ ឬក៏ពេលដែលគាត់សួរអំពី រស់ ញឹម ដែលថា រស់ ញឹម ទាក់ទងការសម្លាប់ខ្មែរក្រោមនោះ។

[១១:២៥:៤១]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ គឺថា គឺឯកសារនេះមិនទាន់បានទទួលយក<ជាភស្តុតាង>នៅឡើយ គឺមានលេខ ERN--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមទោស ប្រសិនបើមិនទាន់ទទួលជាភស្តុតាងទេ មិនចាំបាច់ត្រូវបន្តទៅមុខទៀតទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ដោយសារតែព្រះរាជអាជ្ញាគាត់ស្នើសុំ ខ្ញុំត្រូវផ្តល់ឲ្យ។ <វាគឺជាភស្តុតាងដែលបានមកពីកិច្ចសម្ភាសន៍ដោយ រ៉ូប៊ីត លឹមគិន ដែលអង្គជំនុំជម្រះបដិសេធន៍មិនទទួលយក។>

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមបញ្ចេញមតិរបស់ខ្ញុំ។ អ្វីដែលមេធាវីការពារក្តីបាននិយាយ ប៉ុន្តែមិនអីទេ ខ្ញុំចាំដល់វេនខ្ញុំនិយាយជាមួយសាក្សីតែម្តងទៅចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកបានមកដល់ខេត្តបាត់ដំបងនៅថ្ងៃ០១ មករា ៧៨ ហើយ រស់ ញឹម ត្រូវបានចាប់ខ្លួននៅចុងខែឧសភា ដើមខែមិថុនា ៧៨។ តើលោកធ្លាប់ឮ ឬក៏ធ្លាប់ឃើញទាក់ទងទៅនឹងការចាប់ខ្លួន រស់ ញឹម ដែលជាប្រធានភូមិភាគពាយ័ព្យដែរឬទេ?

*(មានបញ្ហាបច្ចេកទេស)*

[១១:៣០:០០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ! ធ្វើម៉េចប្រឹងប្រែងក្រែងលោបានចប់ យ៉ាងហោចណាស់ ក៏ព្រឹកនេះ ក្រែងលោចប់ លោកមេធាវីអាចសួរបញ្ចប់សំណួរចំពោះគាត់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាននេះ គឺជាសំណួរចុងក្រោយរបស់ខ្ញុំហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោក<ចាំច្បាស់ថា>មកដល់ខេត្តបាត់ដំបង ថ្ងៃ០១ មករា ៧៨ ហើយ រស់ ញឹម ត្រូវបានចាប់ខ្លួនប្រហែលជា៥ខែក្រោយ។ តើលោកធ្លាប់ឮអំពីការចាប់ខ្លួន ឬក៏ធ្លាប់ឃើញអំពីការចាប់ខ្លួន ឬក៏ថា ធ្លាប់មានកម្មាភិបាលណាផ្សេងប្រាប់លោកអំពីការចាប់ខ្លួន រស់ ញឹម នេះដែរទេ?

**2-TCW-971៖**

**ឆ៖** បាទខ្ញុំអត់បានដឹង ទៅដល់ខ្ញុំមិនបានដេញដោលសួររឿងរ៉ាវអស់ហ្នឹងផង។ អត់ហ៊ានដេញដោលសួរទេ ព្រោះរឿងរបស់គេ រឿងគេ។ ខ្ញុំដឹងតែគេប្រើធ្វើអី ខ្ញុំធ្វើប៉ុណ្ណឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីឱកាសសួរដេញដោលចំពោះសាក្សី។ ហើយយើងនឹងប្រឹងឲ្យបានត្រឹម១៥នាទីទៀត។

[១១:៣១:២៦]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកថា លោកហ្នឹងគឺទៅហ្នឹង <ជាកម្មាភិបាលភូមិភាគនិរតីតំណាក់កាល>ទី៣ហើយទៅភូមិភាគពាយ័ព្យនោះ។ លោកដឹងទេថា យាយរឹម គេបញ្ជូនទៅស្រុកបាកាន លោកដឹងដែរ?

**2-TCW-971៖**

**ឆ៖** ខ្ញុំអត់ស្គាល់ អត់ស្គាល់ យាយរឹម ណាផង អត់បានស្គាល់ទេ។

**ស៖** តើលោកមានដឹង មានឮគេសម្លាប់ខ្មែរក្រោមនៅក្នុងខែសីហា ១៩៧៨ នៅស្រុកបាកានដែរឬទេ?

**ឆ៖** អត់យល់សំណួរ។ បាទ សូមអញ្ជើញសួរម្តងទៀត។

**ស៖** តើលោកមានបានឮអំពីការសម្លាប់ខ្មែរក្រោមនៅក្នុងខែសីហា ១៩៧៨?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

សូមសហព្រះរាជអាជ្ញាផ្ដល់លេខយោងផង។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំនឹងផ្ដល់លេខយោងនៅក្រោយពេលឈប់សម្រាក ពេលយើងចូលមកវិញ។

[១១:៣២:៤៧]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើលោកមានបានឮថា មានការសម្លាប់ខ្មែរក្រោមនៅស្រុកបាកានដែរឬទេ? <លោកមេធាវីដឹងពីរឿងនេះនៅក្នុងវីដេអូមួយ។>

**ឆ៖** បាទ ខ្ញុំអត់ដែលបានដឹងទេ។

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក លោកបាននិយាយថា លោកគឺជាគ្រូបង្រៀន ហើយថា ដោយសារតែលោកគ្រូបង្រៀន លោកត្រូវតែប្រុងប្រយ័ត្នខ្លួនណាស់ក្នុងរបបខ្មែរក្រហម។ តើលោកចង់និយាយថាម៉េចត្រង់ចំណុចនេះ?

**ឆ៖** បាទ ខ្ញុំខ្លាចខ្លួន បើគេប្រើធ្វើអីគឺត្រូវតែធ្វើ ខ្ញុំខ្លាច តែរឹងទទឹងគឺរកអីមន្ត្រីរាជការចាស់ក្រែងលោថាទំនាស់នឹងគេ ប្រឆាំងនឹងគេ ខ្ញុំត្រូវប្រយ័ត្ន។

**ស៖** ខ្ញុំសូមអានចម្លើយរបស់លោកគឺ ចម្លើយលេខ២៤ លោកថា៖ “ក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវប្រុងប្រយ័ត្ន ដោយសារខ្ញុំធ្លាប់ធ្វើជាគ្រូបង្រៀន។ ឪពុក<មា>របស់ខ្ញុំ ខ្ញុំ បីនាក់ បងប្អូនបង្កើត ពីរនាក់ និងបងប្អូន<ជីដូនមួយ>ប្រាំពីរនាក់បានស្លាប់ក្នុងរបបខ្មែរក្រហម។” សូមលោកពន្យល់បន្តិចមើលថា នេះដោយសារថាលោក គិតឃើញថា លោកជាគ្រូបង្រៀន គេសង្ស័យលោក ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្លាចគេសង្ស័យ។ ឯបងប្អូនទាំងជីដូនមួយ ទាំងអីដែលបានស្លាប់ហ្នឹង មិនមែនស្លាប់នៅក្រោយឆ្នាំ៧៥ទេ គឺកាលពីសង្គ្រាមជាមួយ លន់ នល់ ដែលវាចូលធ្វើទាហាន។ បាត់បង់ជីវិតគឺចូលធ្វើទាហាន សង្គ្រាមជាមួយ លន់ នល់។

**ស៖** មុននឹងសួរលោក នៅពេលលោកទៅដល់នៅភូមិភាគពាយ័ព្យនោះ ខ្ញុំសុំសួរម្ដងមួយវគ្គពាក់ព័ន្ធទៅនឹងពេលវេលាដែលលោកទៅដល់ទីនោះ។ លោកថា លោកចាកចេញពីភូមិភាគនិរតី នៅថ្ងៃទី៣១ ខែធ្នូ ហើយទៅដល់នោះគឺនៅថ្ងៃទី០១ ខែមករា ៧៨។ លោកថា លោកចំណាយពេលវេលាប្រហែលជា១០ថ្ងៃនៅដូនទាវ ហើយក្រោយមក គេបញ្ជូនលោកទៅថ្មគោល។ ត្រឹមត្រូវដែរឬទេ?

[១១:៣៥:៣៣]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយលោកស្នាក់នៅថ្មគោលរហូតដល់ពាក់កណ្តាលខែ លោកនៅឯថ្មគោលហ្នឹងរហូតដល់ពេលមុនវៀតណាមចូលមកដល់ នៅពេលដែលគេបញ្ជូនលោកទៅមង្គលបុរី។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំនៅថ្មគោល មិនចាំខែទេ ក៏ប៉ុន្តែមិនជាយូរទេ។ ទៅដល់ គ្រាន់តែរៀបចំចែកចាយស្បៀងដែលនៅសល់ហ្នឹងហើយ រំសាយកងកុមារប្រមូលផ្តុំអីហ្នឹង ហើយនិងដោះលែង។ ប្រកាសៗអ្នកដែលប្រមូលផ្តុំនៅចល័តហ្នឹង ឲ្យមកផ្ទះហើយ ខ្ញុំក៏គេឲ្យទៅនៅមង្គលបុរី ប៉ុណ្ណឹង។

**ស៖** សូមបញ្ជាក់ឲ្យបានច្បាស់អំពីពេលវេលានេះ។ គេចាត់ឲ្យលោកទៅមង្គលបុរីហ្នឹង គឺទើបតែមុនពេលវៀតណាមចូលមកហ្នឹង គឺគេបញ្ជូនលោកទៅនៅក្នុងម៉ុខែធ្នូ ឆ្នាំ១៩៧៨។ ត្រឹមត្រូវទេ?

**ឆ៖** កាលហ្នឹង វាតាមខ្ញុំចាំ វៀតណាមចូលព្រំដែនហើយ ក៏ប៉ុន្តែវាមិនទាន់ដល់ក្នុងជ្រៅ មកក្នុងកម្ពុជាទេ។ ពេលដែលខ្ញុំទៅដល់មង្គលបុរីហ្នឹង វាមានសភាពការណ៍រំដើបរំជួលហើយ គឺមានការឲ្យភ្ញាក់។

**ស៖** សូមបញ្ជាក់ឲ្យបានច្បាស់ជាងនេះបន្តិច។ តើលោកចំណាយពេលវេលាប៉ុន្មាននៅមង្គលបុរីមុននឹងរត់គេចពេលវៀតណាមចូលមក?

**ឆ៖** ខ្ញុំមិនចាំ ប្រហែលជាៗពីរបីខែប៉ុណ្ណឹង ខ្ញុំមិនបានកត់ត្រាទុកទេ ប៉ុន្តែខ្លីណាស់ ខ្លីនៅនុ៎ង។ សភាពការណ៍នៅខាងព្រំដែនហ្នឹង វាខ្លាំងទៅហើយហ្នឹង។

[១១:៣៧:៣៩]

**ស៖** សូមអរគុណ។ នៅពេលលោកទៅដល់ភូមិភាគពាយ័ព្យ តើ តាម៉ុក ជាប្រធាន ជាលេខាភូមិភាគពាយ័ព្យមែនទេ?

**ឆ៖** បាទ កាលហ្នឹងគាត់លេខាហើយ គាត់លេខា។

**ស៖** តើលោករាយការណ៍ទៅ តាម៉ុក ដោយផ្ទាល់ ឬក៏លោករាយការណ៍ទៅអ្នកណាផ្សេងសិន?

**ឆ៖** អ្ហូ! បាទ សុំទោស។ ខ្ញុំមានមេខ្ញុំបន្ទាប់មកគឺ តាចាយ គាត់ទៅជាប់មួយហ្នឹងដែរ ដែលគាត់គេប្រើទៅដំណាលគ្នាហ្នឹង ប៉ុន្តែ តាចាយ ហ្នឹងគាត់មេខ្ញុំ។ អ៊ីចឹងមានបញ្ហាអីៗ ខ្ញុំជម្រាបជូន តាចាយ ហ្នឹងឯង ខ្ញុំត្រូវរាយការណ៍។ ឯតានុ៎ង មិនដឹងគាត់ មិនដឹងនៅឯណា ជួនណាក៏ឃើញ ជួនណាក៏អត់ មិនដឹងគាត់ កន្លែងមិនទៀង។

សៈ ចុះ តើ តាចាយ តាមដែលលោកដឹង តើ តាចាយ រាយការណ៍ទៅ តាម៉ុក ផ្ទាល់ឬ?

ឆៈ បាទ តាមលំដាប់លំដោយ កាលហ្នឹងអ៊ីចឹងឯង។

សៈ នៅពេលលោកនៅថ្មគោល លោកថា លោក<ធ្វើការនៅមន្ទីរពាណិជ្ជកម្មតំបន់>ក្នុងតំបន់៣។ អ៊ីចឹងពេលនៅទៅនោះ លោករាយការណ៍ទៅឲ្យអ្នកណា?

ឆៈ កាលហ្នឹង នៅជាមួយ តាចាយ តើ! តាចាយ ក៏គាត់នៅហ្នឹងដែរ។ មានៗអី ខ្ញុំសួរមតិគាត់ សួរយោបល់គាត់ ប្រាប់គាត់។

សៈ ចុះតើអ្នកណាជាលេខាតំបន់?

[១១:៣៩:៤១]

ឆៈ លេខាតំបន់ កាលហ្នឹង ទៅដល់វាមិនទាន់បានតែងតាំងអីច្បាស់លាស់ទេ ប៉ុន្តែក្នុងនាម តាចាយ ហើយ គាត់ធ្វើការក្នុងនាមជាតំបន់ហើយ ប៉ុន្តែមិនទាន់មានឃើញការប្រកាសអីទេ ប៉ុន្តែតាមខ្ញុំយល់ គឺគាត់ទៅទទួលការងារតំបន់។

សៈ ចុះ តាគុំ? តើ តាគុំ ជាលេខាតំបន់៣ឬ នៅពេលលោកទៅដល់ទីនោះ?

ឆៈ បាទ ខ្ញុំទៅដល់ អត់មានឃើញ ដឹងអ្នកណាអីទេ គឺកន្លែងធ្វើការងារទំនេរតែម្តង អត់មាន អត់មានតំបន់ អត់មានពាណិជ្ជកម្មអី ក៏អត់មានឃើញមនុស្ស។

សៈ អ៊ីចឹងលោកមិនដែលឮឈ្មោះ តាគុំ ដែលជាលេខាតំបន់នោះទេឬ?

ឆៈ ខ្ញុំឮឈ្មោះក្រោយហើយ ដែលពេលខ្ញុំទៅដល់ គ្រាន់តែសួរថា ចុះពីណាគេធ្វើតំបន់? បងប្អូនក្មេងៗ--<>គេឆ្លើយថាឈ្មោះ គុំ ប៉ុន្តែខ្ញុំក៏មិនដែលឃើញមុខឃើញមាត់គាត់ មិនដឹងមុខគាត់ម៉េច ហើយគាត់បាត់ខ្លួនពីអង្កាល់ ក៏ខ្ញុំអត់ដឹង។ ប៉ុន្តែទៅដល់សួរគាត់ថា ចុះកន្លែងតំបន់គេហ្នឹងអ្នកណាគេធ្វើតំបន់ពីមុនមក? បានកងចល័តហ្នឹងគាត់ប្រាប់ ប៉ុន្តែរឿងមុខមាត់គាត់ ខ្ញុំអត់ដែលឃើញ អត់ដែលស្គាល់ ហើយមិនដឹងជាគាត់ទៅណា ពីណា អង្កាល់ណាៗ អត់បានដឹង។

[១១:៤១:៣៦]

សៈ យើងមានឯកសារមកពីស-២១ ហើយនិងបញ្ជីពីសហព្រះរាជអាជ្ញា គឺលេខរៀង <៦៨៥៧> បញ្ជីរបស់អ្នកទោស។ មានអ្នកទោសហៅថា គុំ ហៅថា ប៉ុក គុំ ឬ ប៉ុក សារី ដែលជាលេខាតំបន់៣។ ហើយឯកសារនេះបង្ហាញថា គាត់ចូលមកស-២១ នៅ<>ចន្លោះពីថ្ងៃទី២៥ ទៅ ៣០ <ខែមិថុនា> ៧៨។ លោកសាក្សី តើលោកធ្លាប់បានជួប តាគុំ ទេពីមុន មុននឹងគេបញ្ជូន តាគុំ មកស-

២១ ក្នុងអំឡុងខែ<មិថុនា> ៧៨?

**ឆ៖** បាទ អត់សោះ អត់ដែលឃើញមុខឃើញមាត់អីស្គាល់សោះ។

**ស៖** លោកនិយាយអំពីអង្ករនៅក្នុងក្រុងមួយ គឺថ្មគោល ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទបានជម្រាបជូនរឿងហ្នឹង រឿងអង្ករហ្នឹង។

**ស៖** អ៊ីចឹងនៅពេលដែលលោកចូលទៅដល់ឃ្លាំងភ្លាម លោកឃើញអង្ករហ្នឹងតែម្តង អ៊ីចឹងឬ?

**ឆ៖** បាទ ខ្ញុំចូលទៅមើល ចូលទៅមើល ទៅរកមើល មាននៅមែនឬអី ហើយដើម្បីចែកចាយឲ្យបងប្អូនជិតខាងហ្នឹង ហើយនិងប្រជាពលរដ្ឋ។

**ស៖** លោកសាក្សីសូមឆ្លើយទៅនឹងសំណួរខ្ញុំតែម្តងថា នៅពេលដែលលោកដើរចូលទៅឃ្លាំង លោកឃើញអង្ករហ្នឹងច្បាស់ក្រឡែតអ៊ីចឹងតែម្តង ឬក៏អង្ករក្នុងឃ្លាំងគេមានលាក់អីយ៉ាងរបៀបណាទៀត?

**ឆ៖** បាទ អត់ទេ មិនមែនមានលាក់ទេ គឺដាក់នៅនឹងបង្ហាញធម្មតា ក៏ប៉ុន្តែវាមានខូច។ នៅច្រកក្នុងបាវ ក្នុងជង្រុក អាធ្វើស្បោងធំៗហ្នឹង មិនមានលាក់លៀមបិទបាំងអីទេ ប៉ុន្តែស្ពាយអង្ករដែលវាខូចខ្លះ មិនខូចខ្លះ វាមានពីយូរ មានថ្មី។

[១១:៤៤:១៩]

**ស៖** លោកបានឆ្លើយថា លោកបានទៅដល់ភូមិភាគពាយ័ព្យនៅខែមករា។ លោកថា លោកបានទៅដល់ទួលគៀតនៅក្នុងខែមករា ហើយលោកមិនបានចេញពីទីនោះទេរហូតដល់ដំណាច់ឆ្នាំ <-- ពីរខែមុនពេលដាច់ឆ្នាំ>។ តើ<លោកបានប្រមូលស្រូវទេ? តើ>ស្រូវដែលបងប្អូនយើងធ្វើនៅតំបន់ដែលលោក<នៅ>ហ្នឹង គេប្រមូល<និងបែងចែក>ដោយរបៀបណា?

**ឆ៖** ពេលដែលខ្ញុំទៅដល់ហ្នឹង គេមិនទាន់បានប្រមូលផលស្រូវទេ ឃើញតែកងចល័តនៅធ្វើតាមពាសវាលហ្នឹងឯង មិនទាន់បានប្រមែប្រមូលដឹកជញ្ជូនដាក់ត្រង់ណាត្រង់ណី ខ្ញុំមិនទាន់ដឹង។ បានឃើញបាន ៗឃើញ មិនទាន់ប្រមូលផលទេ។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ នៅពេលទៅដល់ភូមិភាគពាយ័ព្យ តើគេមានដឹកជញ្ជូនស្រូវអង្ករហ្នឹងយកមកភ្នំពេញ ឬក៏ដឹកទៅប្រទេសក្រៅដែរទេ?

**ឆ៖** បាទ អត់មានបានឃើញទេ។ ខ្ញុំទៅដល់គឺមិនមានឃើញការដឹកជញ្ជូនចេញអី អត់។

**ស៖** តើលោកមានបានដឹងថា ស្រូវមួយចំនួនត្រូវបាន<>ដឹកចេញពីភូមិភាគពាយ័ព្យ<ទៅកាន់

មជ្ឈិម ឬ>យកចេញទៅក្រៅប្រទេស គឺមុនពេលលោកទៅដល់នៅក្នុងឆ្នាំ<១៩៧៧-១៩៧៦> ឯណោះ លោកដឹងដែរ?

**ឆ៖** បាទអត់ ខ្ញុំអត់បានដឹងទេ។

[១១:៤៦:៣៤]

**ស៖** មានឯកសារមួយគឺឯកសារ E3/201, ERN ជាភាសាខ្មែរ 00292805, បារាំង 00612166, អង់គ្លេស 00419513។ នេះជាសុន្ទរកថារបស់ ខៀវ សំផន៖ "គឺថានៅក្នុងឆ្នាំ៧៧ យើងទទួលបានផលស្រូវច្រើនណាស់ <>យើងក៏មានកំណើនស្រូវនេះ ក៏នាំឱ្យយើងអាចនាំចេញទៅក្រៅបាន។" លោកដឹងអំពីការនាំស្រូវអង្ករចេញទៅក្រៅប្រទេសទេ?

**ឆ៖** ការងារធំៗខ្ញុំអត់បានដឹងទេ។ ខ្ញុំនៅឯថ្នាក់ក្រោមៗឯណោះ ការងារគេធំៗអីចឹង ខ្ញុំអត់បានដឹង។

**ស៖** មានឯកសារមួយទៀតគឺ E3/2059, ERN ជាភាសាខ្មែរ 00088796, បារាំង 00623416, អង់គ្លេស 00583647។ នេះជាបញ្ជីស្ថិតិ<នាំចេញ>តាមភូមិភាគផ្សេងៗនៅខែមករា <ដល់ខែកញ្ញា> ៧៨ គឺនៅពេលដែលលោកទៅដល់ថ្មគោល ហើយ<ឯកសារនេះបានបញ្ជាក់ថាមកពី>ភូមិភាគពាយ័ព្យនេះ អង្ករនិងស្រូវ គឺឃើញថាមានអង្កររហូតដល់ <២៩.៧៥៨.១៤៥>តោន ត្រូវបានគេ<នាំចេញ។ តើលោកបានទទួលបញ្ជាណាមួយ ដែលលោកដឹងថានៅឧត្តរ ពី>មជ្ឈិម ដើម្បីនាំ<អង្ករទៅមជ្ឈិម ដើម្បីនាំ>ចេញទៅក្រៅប្រទេស<ដែរទេ>?

**ឆ៖** បាទអត់ ខ្ញុំទៅដល់មិនមានឃើញសកម្មភាពដឹកជញ្ជូនអីទាំងអស់ អត់មានបានឃើញអីទេ។

**ស៖** នៅពេលដែលគេឱ្យលោកទៅដោះស្រាយបញ្ហាប្រជាជនអត់ឃ្លាននៅភូមិភាគពាយ័ព្យ តើមានអ្នកណាមាននិយាយប្រាប់លោកថា គេនាំស្រូវចេញពីភូមិភាគពាយ័ព្យ ហើយគេនាំចេញទៅក្រៅប្រទេសដើម្បី<លក់យកលុយឱ្យ>របបខ្មែរក្រហមហ្នឹង<>ដែរ<ទេ>?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមជំទាស់ចំពោះការតាំងសំណួរនេះ។ មើលទៅឃើញថា មិនច្បាស់លាស់ទាល់តែសោះថាតើព័ត៌មាននេះបានមកពីណា? ចំណុចនេះហាក់បីដូចជាសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាពីព្រោះនៅពេលហ្នឹងគឺថាគេអាចមានលាក់ស្រូវអង្ករ ហើយក៏អាចនាំចេញទៅក្រៅក្នុងពេលជាមួយគ្នា។

[១១:៤៩:៣៧]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគ្រាន់តែសួរសំណួរគាត់ឆ្លើយ "បាទ ឬ ទេ" ទៅបានហើយ។ ហើយគាត់ក៏បានឆ្លើយទៅនឹងសំណួររបស់មេធាវីការពារក្ដីហើយតើ <ថាគាត់បានឮថាមានបញ្ហានៅពាយ័ព្យ ហើយ>ប្រជាជនអត់<មានអាហារគ្រប់គ្រាន់។> ខ្ញុំសួរ<គាត់ថា តើ>គាត់<បានឮពីការ>ពន្យល់<ដែរទេ>។

**លោក នីកូឡាស គូមជែន៖**

ដោយសារតែពេលវេលា ខ្ញុំសូមបន្តទៅមុខទៀត។ អ៊ីចឹងខ្ញុំសូមបង្ហាញជូននូវប្រភពឯកសារឲ្យមេធាវីការពារក្ដីគាត់ពេញចិត្ត។ ឯកសារមួយE3/1593, ERNជាភាសាបារាំង 00639160, អង់គ្លេស 001150196, ខ្មែរ 00637932។ គាត់បានសរសេរថា៖ "មានជនភៀសខ្លួនជាច្រើន និងអ្នករស់រានពីរបបនេះនៅក្នុងប្រទេសកម្ពុជារាយការណ៍ថា គេបានដឹកស្រូវអង្ករទៅ<ប្រទេសចិន> បើទោះណាជាមានភាពអត់ឃ្លានយ៉ាងខ្លាំងនៅក្នុងប្រទេសក៏ដោយ។ ក៏ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៦ មន្ត្រីកម្ពុជាប្រជាធិបតេយ្យអះអាងថា <>ខ្មែរក្រហម<>បាននាំអង្ករចេញ១០០.០០០តោន<នៅឆ្នាំកន្លងមក" អាចថានៅក្នុងឆ្នាំ១៩៧៧ មុនពេលលោកទៅពាយ័ព្យ> "ហើយនាំទៅប្រទេសយូហ្គោស្លាវី ទៅម៉ាដាហ្គាស្កា ទៅហុងកុង។" តើលោកធ្លាប់ដែលឮទេ ថាគេនាំអង្ករចេញពីភូមិភាគពាយ័ព្យទៅក្រៅប្រទេស នៅក្នុងពេលនោះ គឺប្រជាជនកំពុងតែអត់ឃ្លាន?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមជំទាស់ទៅនឹងសំណួរនេះ មិនមានអ្វីពាក់ព័ន្ធទៅនឹងសួរសាក្សី <នូវ>អ្វីដែលគាត់មិនដឹងនោះទេ។ ហើយការសួរនេះ ការសួរបែប សួរទៅគាត់បែបសន្មតហើយ។ ហើយការដកស្រាយសម្រង់របស់ ប៉ែន យៀរនិន នេះគឺថាវាជារឿងមួយគួរភ្ញាក់ផ្អើលណាស់ ព្រោះតុលាការកំពូលថា មិនអាចដកស្រង់របស់ប្រភព ប៉ែន យៀរនិន នេះមកធ្វើជាភស្តុតាងបានទេ។

[១១:៥១:៥៥]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមើលទៅមេធាវីការពារក្ដី ដូចខ្លាចមិនហ៊ានចង់ឲ្យសាក្សីឆ្លើយម៉េចមិនដឹងទេ ខ្ញុំសូមឲ្យសាក្សីឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនឹងសេចក្ដីជំទាស់នេះ។ សំណួរនេះអាចសួរបាន។ សាក្សីឆ្លើយតប

សំណួរនេះ។

**2-TCW-971៖**

**ឆ៖** ខ្ញុំមិនចាំសំណួរ ស្ដាប់មិនទាន់ផង មិនយល់រឿង។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំសួរលោកម្ដងទៀត។ មុននឹងសួរលោក ខ្ញុំសូមផ្ដល់ភស្តុតាងបង្ហាញទៅលោកសិន ពាក់ព័ន្ធទៅនឹងបញ្ហា។ នេះគឺរបាយការណ៍កិច្ចសម្ភាសន៍ជាមួយនឹងកូនសុំរបស់ រស់ ញឹម ឯកសារ E3/10665។ ឯកសារនេះ មិនទាន់បកប្រែជាបារាំងនៅឡើយទេ អង់គ្លេស 01156820 ហើយខ្មែរ 01168475។ គាត់បានឆ្លើយថា៖ "ចំនួនអង្ករនេះ គឺយកមកឲ្យអង្គការដែលជាផែនការ <វាបានទៅបាត់ហើយ> ហើយប្រជាជនវិញគឺថាហូបតែបបរ អត់មានបាយហូបទេ ដោយសារតែគេនាំស្រូវចេញអស់ទៅហើយ អ៊ីចឹងអត់មានអីជាស្រូវឯណាកិនទៅជាអង្ករទៀតទេ។ អ៊ីចឹងប្រជាជនខ្វះខាតអង្ករហូបទាំងស្រុង។"

[១១:៥៣:៤៣]

ហើយគាត់បានឆ្លើយបន្តទៅទៀត គាត់បានសរសេរបន្តទៅទៀតថា៖ "គេនិយាយថា អង្ករ១លានតោន យើងនិយាយថាតែ<៥០.០០០>តោន -- តែកន្លះលានតោនទេ <ព្រោះយើងប្រមូលផលមិនបានល្អ។ នេះជាផែនការ>។ បើសិនណាជាយើងមិនមានស្រូវអង្ករបញ្ជូនមកថ្នាក់លើហ្នឹង មិនបានគ្រប់ចំនួនកំណត់នេះ គេថាយើងក្បត់គេហើយ។" លោកសាក្សី ដោយសារលោកធ្វើនៅផ្នែកពាណិជ្ជកម្មមួយនៃភូមិភាគពាយ័ព្យ អ៊ីចឹងខ្ញុំសួរលោកជាថ្មីម្ដងទៀត តើលោកមានបានទទួលបញ្ជាពីមជ្ឈិមឲ្យបញ្ជូនអង្ករមកមជ្ឈិម ឬក៏ឲ្យនាំអង្ករចេញទៅក្រុងកំពង់សោមដើម្បីនាំចេញទៅក្រៅប្រទេសទេ?

**ឆ៖** បាទ អត់ដឹងទេ លោកមេធាវី ព្រោះអ៊ីចេះ ខ្ញុំការងារថ្នាក់ក្រោមបំផុត រួចអាការងារដែលគេធ្វើពីលើនោះមុន គេដែលឲ្យខ្ញុំដឹងអ្ហេ ខ្ញុំមិនបានដឹងរឿងអស់ហ្នឹងផង។ ទោះបីសួរយ៉ាងណា ក៏ៗអត់នឹកឃើញដែរ បើមិនបានដឹងការងារគេធំៗប៉ុនៗណាណី រួចខ្ញុំនៅត្រឹម – ហើយពាក្យថាពាណិជ្ជកម្មៗនេះ ខ្ញុំសូមបំភ្លឺឲ្យច្បាស់ វាមិនមែនជាកន្លែងលក់ចេញ ទិញចូលទេ គ្រាន់តែស្ដុករបស់អីតិចតួចដែលគេដឹកមកឲ្យ សម្រាប់ចែកចាយប្រជាជន តែប៉ុននុ៎ងទេ មិនមែនមានដាក់ឃ្លាំងស្រូវឃ្លាំងអីនៅហ្នឹងណាអត់ទេ។ ហើយដឹកជញ្ជូនធំៗ ខ្ញុំអត់បានដឹងរឿងទេ រឿងអស់នេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ យើងសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញណ៎ា ទាំងសាក្សី ទាំងមេធាវីប្រឹក្សាសាក្សី។ ឥឡូវលោក--

**2-TCW-971៖**

បាទ។

**ប្រធានអង្គជំនុំ៖**

បាទ សម្រាកបានហើយណ៎ា!

**2-TCW-971៖**

បាទ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ -- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៥៦ នាទី ដល់ម៉ោង ១៣:៤០ នាទី)*

[១៣:៤០:០០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សួស្តីលោកសាក្សី តើលោករៀបត្រៀមខ្លួនរួចហើយឬនៅ?

**2-TCW-971៖**

បាទ រៀបចំហើយ បាទ សូមគោរព។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាតទៅនេះ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំ--

[១៣:៤១:០៣]

**2-TCW-971៖**

**ឆ៖** បាទ សូមជម្រាបសួរបាទ។

**ស៖** តើលោកធ្លាប់ចូលរៀនវគ្គរៀនសូត្រនៅទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ អត់ទេ លោកប្រធាន អត់ដែលបានទៅរៀនទេ។

**ស៖** តើលោកធ្លាប់ជួប ឬក៏ធ្លាប់ឃើញ នួន ជា <ឬ> ខៀវ សំផន ទេ?

**ឆ៖** បាទ លោកអំពីរនាក់នេះ ខ្ញុំមិនដែលបានឃើញទេ ឮតែឈ្មោះ ហើយឃើញរូបតាមរូបថត។

**ស៖** នៅពេលដែលលោកនៅភូមិភាគពាយ័ព្យ តើលោកធ្លាប់ឮគេនិយាយថា នួន ជា មកភូមិភាគនោះទេ?

**ឆ៖** បាទ អត់ ខ្ញុំអត់ដែលបានឮទេ។

**ស៖** តើលោកធ្លាប់ឮថា នួន ជា មកភូមិភាគពាយ័ព្យទេ?

**ឆ៖** បាទ អត់ ៗដែលឮថាគាត់មកផង។

**ស៖** សូមអរគុណ។ លោកនិយាយថា លោកនៅក្នុងក្រុមទី៣របស់កម្មាភិបាលនិរតីដែលគេបញ្ជូនទៅពាយ័ព្យ។ ហើយលោកនិយាយថា តាម៉ុក គឺជាអ្នកដែលប្រាប់ឲ្យលោកទៅខាងពាយ័ព្យនោះ។ ដូច្នេះលោកដឹងទេ ថាតើក្រុមទី១ និងក្រុមទី២ហ្នឹង មកដល់ភូមិភាគពាយ័ព្យនៅពេលណាដែរ?

**ឆ៖** បាទ ខ្ញុំចាំមិនបានទេ ប៉ុន្តែដឹងថាគេមកមុនខ្ញុំទៀត។ មកក្នុងរង្វង់ឆ្នាំ៧៧ ក៏ប៉ុន្តែមិនដឹងជាថ្ងៃខែឆ្នាំណា អ្ហា! ថ្ងៃខែណា ខ្ញុំមិនចាំ។

[១៣:៤៣:០៧]

**ស៖** អ៊ីចឹងបានន័យថា នៅពេលដែលលោកមកដល់ហ្នឹងគឺ តាម៉ុក គាត់គ្រប់គ្រងតំបន់ គ្រប់គ្រងភូមិភាគនោះរួចទៅហើយ ហើយនៅពេលនុ៎ង គឺលោករាយការណ៍ឲ្យ តាម៉ុក ហើយនិងកម្មាភិបាលខាងនិរតី មិនមែនរាយការណ៍ឲ្យខាងពាយ័ព្យទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ វាមិនដឹងថាខាងពាយ័ព្យហ្នឹងពីណាគេ ខ្ញុំអត់ដឹង។ ខ្ញុំគ្រាន់តែមកដល់ជាមួយ តាចាយ គាត់មេខ្ញុំទៀត មេបន្ទាប់ពីតានុ៎ងមក។ រួចការងារអី ខ្ញុំសួរយោបល់ពី តាចាយ។

**ស៖** នៅក្នុងសំណួរចម្លើយ១៩ នៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោក លោកនិយាយថា "ថ្នាក់ដឹកនាំក្នុងគណៈភូមិភាគពាយ័ព្យមុន តាម៉ុក មកដល់គឺត្រូវគេយកទៅបាត់អស់ហើយ"។ ខ្ញុំចង់សួរថា លោកធ្វើយ៉ាងណា ដឹងអំពីព័ត៌មានមួយនេះ?

**ឆ៖** បាទ ពេលខ្ញុំមកដល់ ខ្ញុំចូលទៅកន្លែងធ្វើការ ខ្ញុំសាកសួរ សាកសួរកងចល័ត និងប្រជាពលរដ្ឋនៅទីហ្នឹង ថាកន្លែងនេះកន្លែងអីគេ? គេថាកន្លែងតំបន់។ ចុះអ្នកតំបន់គេហ្នឹង ឈ្មោះអី? បានគេប្រាប់ថា ឈ្មោះ តាតុំ។ ហើយសួរថា គាត់ទៅណា? ថាចុះ គេអត់ដឹង ថាខ្ញុំ ក៏មិនដឹងដូចគ្នា។

**ស៖** តើលោកធ្លាប់ទទួលបញ្ជាពី តាតុំ ដែរឬទេ ក្រៅពី តាចាយ ហើយនិង តាម៉ុក នោះ?

**ឆ៖** បើខ្ញុំអត់ស្គាល់ផង អត់ដែលឃើញ ខ្ញុំទៅដល់មិនដឹងជាគាត់ហ្នឹងនៅឯណា ខ្ញុំស្គាល់ តាចាយ ដែលទៅជាមួយគ្នា។ អត់ដែលបានទទួលបញ្ជាពីគាត់ទេ អត់ស្គាល់គាត់ផង មិនឃើញគាត់ផង។

**ស៖** នៅពេលលោកទៅដល់ភូមិភាគពាយព្យ ខ្ញុំចាំថាលោកទៅពីរកន្លែង ទី១ គឺដូនទាវ, ទី២ គឺថ្មគោល។ តើអ្នកដែលនៅក្រោមលោកហ្នឹង គឺជាប្រជាជននៅភូមិភាគនុ៎ងពីមុនមក ឬក៏អ្នកដែលគេយកពីកន្លែងផ្សេង? ឧទាហរណ៍ថា មកពីភ្នំពេញ ឬក៏បូព៌ា ឬក៏មកនិរតីជាដើមហ្នឹង។

[១៣:៤៥:៥៧]

**ឆ៖** បាទ ខ្ញុំស្គាល់គេមិនអស់ទេ ព្រោះអីខ្ញុំទៅដល់ហ្នឹង ឃើញតែអ្នកនៅធ្វើការងារហ្នឹងខ្លះ ដូចជាកាន់នៅខាងពាណិជ្ជអី ខាងនារីៗហ្នឹង ឮថាគេមកពីស្រែអំបិលខ្លះ។ ឯក្រោយមកទៀត ខ្ញុំចាំគេមិនបាន មិនស្គាល់ ក្នុងរយៈកាលខ្លីពេក ដែលទៅដល់នោះ។ ដូច្នេះមិនស្គាល់គេអស់ មិនដឹងគេមកពីខាងណាខ្លះ។

**ស៖** លោកនិយាយអំពីកម្មាភិបាលនារីមកពីស្រែអំបិល តើពួកគាត់ហ្នឹងមកពីខាងនិរតីមែនទេ?

**ឆ៖** បាទ មនុស្សហ្នឹង សាកសួរប្រវត្តិឃើញមកពីនិរតីប៉ុន្មាននាក់ទេ នៅនឹងកន្លែង កាន់កាប់

កន្លែងពាណិជ្ជហ្នឹង។ ប៉ុន្តែមិនដឹងគេនៅខេត្តណាទេ ដឹងថាមកពីភូមិភាគនិរតី។

**ស៖** នៅក្នុងឆ្នាំ៧៨ នៅពេលដែលលោកនៅភូមិភាគពាយ័ព្យនោះ តើលោកធ្លាប់ឃើញប្រជាជនមកពីបូព៌ាដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ មិនដឹងជាប្រជាជនពីខាងណាខ្លះ។ មិនបានដេញដោលសួរប្រវត្តិដើមរបស់គាត់ផង។

**ស៖** លោកបាននិយាយអំពីកងចល័ត គឺថាលោកប្រាប់ឲ្យអ្នកនៅកងចល័តត្រឡប់ទៅផ្ទះវិញ។ ថាតើផ្ទះរបស់ពួកគេហ្នឹងនៅកន្លែងណាដែរ? ឧទាហរណ៍ថា ប្រសិនបើពួកគេមកពីភ្នំពេញ ឲ្យទៅភ្នំពេញវិញ ឬមួយពួកគេមកពីបូព៌ា គេឲ្យទៅបូព៌ាវិញ មែនឬទេ?

[១៣:៤៧:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

គាត់បានឆ្លើយរួចទៅហើយថា គាត់មិនដឹងថា ប្រជាជនទាំងអស់នេះមកពីណានោះទេ។ ដូច្នេះប្រសិនបើសួរបែបនេះ វាហាក់ដូចជាការលើកជាសម្មតិកម្មឲ្យគាត់ស្មានតែប៉ុណ្ណោះ។

**លោក នីកូឡាស គូមជែន៖**

មានតែសាក្សីទេ ដែលគាត់អាចឆ្លើយបាន ថាគាត់ដឹង មិនដឹង។ គាត់ជាអ្នកនិយាយថា បញ្ជូនទៅផ្ទះវិញ។ ដូច្នេះមានតែគាត់ទេ ដឹងថាទៅផ្ទះហ្នឹង ផ្ទះនៅកន្លែងណា។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនអាចឆ្លើយតបទេ សាក្សីឆ្លើយរួចហើយ ថាគាត់អត់ដឹងទេ អត់ស្គាល់ទេ។

**2-TCW-971៖**

**ឆ៖** បាទ--

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍របស់លោក គឺលោកឆ្លើយថា គេបែងចែកប្រជាជនជា<>ក្រុម។ ខ្ញុំនឹងព្យាយាមរកចម្លើយដែលលោកឆ្លើយនោះ គឺសំណួរចម្លើយ២៣នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺលោកបាននិយាយថា “ប្រជាជនខ្វះបាយហូប មានការបែងចែកប្រជាពលរដ្ឋជាពីរបីផ្នែក”។

តើលោកមានន័យយ៉ាងណា នៅពេលដែលលោកឆ្លើយថា មានការបែងចែកប្រជាពលរដ្ឋជាពីរបីផ្នែកនោះ?

[១៣:៤៩:១៤]

**2-TCW-971៖**

**ឆ៖** បែងចែកជាពីរបីផ្នែក ខ្លះគេឲ្យនៅក្នុងសហករណ៍ ចំពោះមនុស្សចំណាស់ៗ យុវវ័យគេឲ្យទៅនៅកងចល័ត កុមារគេនៅក្នុងក្រុមកុមារ។

**ស៖** នៅពេលដែលលោកនិយាយអំពីផ្នែកហ្នឹង តើលោកចង់សំដៅទៅលើប្រជាជនថ្មី ប្រជាជនចាស់ ឬក៏ប្រជាជនថ្មី ប្រជាជនមូលដ្ឋានហ្នឹងមែនទេ?

**ឆ៖** បាទ ខ្ញុំមិនបានយល់ ព្រោះឃើញតែមនុស្សម្នាដូចតែគ្នា ខ្ញុំមិនដឹងអ្នកណាចាស់ អ្នកណាថ្មី អ្នកណាមកក្រោយ មកមុនអីគឺថា គ្រាន់តែឃើញក្រុមគេបែងចែកក្រុមការងារតាមវ័យចាស់ វ័យកណ្ដាល ហើយនិងកុមារ។ ខ្ញុំមិនសំដៅថាថ្មី ចាស់ ម៉េចខ្ញុំអត់ស្គាល់គាត់ផង មិនដឹងជាគាត់ចាស់ គាត់ថ្មីទេ។

**ស៖** តើលោកអាចរៀបរាប់បានទេនៅពេលដែលលោកនៅដូនទាវ គឺលោកនិយាយថាពីពាក់កណ្ដាលខែមករា រហូតដល់ចុងឆ្នាំ ថាតើលោកបំពេញភារកិច្ចអ្វីដែរនៅក្នុងអំឡុងពេលនេះ?

**ឆ៖** បាទ ខ្ញុំនៅដូនទាវប្រហែលជា១០ថ្ងៃយ៉ាងយូរប៉ុននុ៎ង គឺគ្រាន់តែចូលទៅមើលសហករណ៍ ហើយនិងកងចល័តតែប៉ុននុ៎ង បានខ្ញុំ គេឲ្យទៅថ្មគោលវិញ។

**ស៖** ខ្ញុំសូមទោស គឺថាលោកនៅដូនទាវតែ១០ថ្ងៃទេ ខ្ញុំច្រឡំចូលគ្នាឥឡូវហ្នឹង។ នៅថ្មគោល តើលោកអាចរៀបរាប់បានទេ ថាលោកធ្វើការងារអ្វី? តើលោកធ្វើការនៅក្នុង<មន្ទីរ>ពាណិជ្ជកម្មនៅក្នុងតំបន់៣ មែនទេ?

[១៣:៥១:២៤]

**ឆ៖** បាទ ខ្ញុំនៅមើលការខុសត្រូវអំពីការចែកចាយ និងរបស់របរដែលមាននៅក្នុងឃ្លាំងហ្នឹង ហើយតែប៉ុណ្ណឹងឯង។

**ស៖** នៅក្នុងការងាររបស់លោកនៅថ្មគោលពីពាក់កណ្ដាលខែមករា រហូតដល់ចុងឆ្នាំហ្នឹង លោកបានជួបជាមួយប្រធានកសិកម្មភូមិភាគ ហើយនិងអនុប្រធានរោងចក្រកិនស្រូវក្នុងភូមិភាគ។ តើលោកបានជួបពួកគាត់មែនទេ?

**ផ៖** ទេ ខ្ញុំមិនបានជួបប្រធានកសិកម្ម ខ្ញុំអត់ស្គាល់ផង ហើយនិងម៉ាស៊ីនស្រូវភូមិភាគ ក៏ខ្ញុំអត់បានស្គាល់គាត់។

**ស៖** ខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោកបន្តិច គឺឯកសាររបស់ទួលស្លែង គឺឯកសារពីស-២១។ យោងតាមបញ្ជីរបស់ការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត គឺលេខ១១៤៦១ ឈ្មោះ លឹម ណាម ជាប្រធានកសិកម្មថ្នូគោលចូលស-២១ នៅថ្ងៃ១៦, ១៨ មិថុនា ៧៨ គឺក្នុងអំឡុងពេលដែលលោកនៅទីនោះដែរ។ អ៊ំ សំអាង គឺជាអនុប្រធានរោងម៉ាស៊ីនកិនស្រូវថ្នូគោលនៅក្នុងភូមិភាគ ចូលនៅក្នុងថ្ងៃ<ទី២១ ឬ>៣០ មិថុនា ៧៨ ហើយគាត់មានលេខ១១៤៦៨ នៅក្នុងបញ្ជី។ តើលោកចាំថា ពួកគាត់ត្រូវបានគេចាប់ខ្លួនក្នុងនៅពេលដែលលោកនៅធ្វើការនៅផ្នែកពាណិជ្ជកម្មក្នុងតំបន់៣ នោះទេ?

[១៣:៥៣:៣៥]

**ផ៖** បាទ អត់ទេ អត់មានឃើញ អត់មានស្គាល់ផង អត់មានឃើញ មានស្គាល់អ្នកអស់នោះទេ។

**ស៖** លោកនិយាយថា លោកទៅខាងមន្ទីរពាណិជ្ជកម្មប្រហែលជា១០ថ្ងៃក្រោយពេលមកដល់។ តើលោកស្គាល់ឈ្មោះ វាំង ឡុប អនុប្រធានពាណិជ្ជកម្មរដ្ឋរបស់តំបន់<៣>ដែរឬទេ? ឬមួយឈ្មោះ ផៃ ឡុប ជាអនុប្រធានពាណិជ្ជកម្មនៅតំបន់៣ តើលោកស្គាល់មនុស្សពីរនាក់នេះទេ?

**ផ៖** បាទ អត់ៗស្គាល់ អត់ដែលដឹងឮឈ្មោះផង។

**ស៖** លោក លោកស្រីចៅក្រម គឺជាបញ្ជីនៅ ក.ស.ច.ស ៨០៥២ គឺ វាំង ឡុប ចូល<ស-២១> នៅ<២១ ខែមករា> ឆ្នាំ៧៨។ ចំណែក ផៃ ឡុប ចូលស-២១ នៅថ្ងៃ២១ មេសា ៧៨ ហើយក៏មានកំណត់ត្រាថា គាត់ចូលនៅ<ខែកុម្ភៈ> ឆ្នាំ៧៨។ វាំង ឡុប គឺលេខ៨០៥២, ផៃ ឡុប គឺ<៧០២៨>។ លោកសាក្សី នៅពេលដែលលោកនៅថ្នូគោល តើវាជាស្រុកមួយដាច់ពីស្រុកបវេល ឬក៏វានៅក្នុងស្រុកបវេល?

**ផ៖** បាទ កាលខ្ញុំនៅថ្នូគោលហ្នឹង គឺថ្នូគោលហ្នឹងនៅក្នុងស្រុកបវេល។

**ស៖** កំណត់ត្រាពីស-២១ បង្ហាញថាលេខាស្រុកបវេល ចេង ចន ហៅ ឈាង ចូលស-២១ នៅថ្ងៃ១៧, ១៨ មិថុនា ៧៨។ តើលោកស្គាល់ – សូមទោស ខ្ញុំទុកឱកាសឲ្យសហការីជាតិខ្ញុំអានឈ្មោះ។

**លោក ស្រ៊ា រតនៈ៖**

សូមគោរពឯកឧត្តម លោកប្រធាន អំមិញដោយសារខ្ញុំស្ដាប់ឮសូរអ្នកបកប្រែគាត់អានឈ្មោះខុសគ្នាឆ្ងាយពេក។ អ៊ីចឹងខ្ញុំសូមអានឈ្មោះដែលសហព្រះរាជអាជ្ញាអន្តរជាតិគាត់អានមុននេះ គឺឈ្មោះ

ឆេង ឆន ហៅ ឆុន នៅលេខរៀងទី៦១៧។

[១៣:៥៦:៣៣]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមអនុញ្ញាតឲ្យសហការីជាតិខ្ញុំអានឈ្មោះបុគ្គលពីរនាក់ទៀត តោះពីរនាក់ទៀតគឺមកពីស្រុកបវេល។

**លោក ស្រ៊ា រតនៈ៖**

បុគ្គលពីរនាក់ទៀត នៅក្នុងបញ្ជីហ្នឹងដែរ ដែលមកពីស្រុកបវេល គឺឈ្មោះ ជា គេ ហៅ គីម និងឈ្មោះ ពៅ ស៊ាប។ ឈ្មោះ ជា គេ នៅលេខរៀងទី៨៨៥ និងឈ្មោះ ពៅ ស៊ាប នៅលេខ៧០៥០។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សីនៅពេលដែលលោកធ្វើការនៅថ្មគោល យោងតាមកំណត់ត្រានេះគឺ លេខាស្រុកបវេល ត្រូវបានចាប់ខ្លួននៅខែមិថុនា ឆ្នាំ៧៨។ អនុប្រធានឈ្មោះ គីម ត្រូវបានចាប់ខ្លួននៅថ្ងៃ៣០ មករា ៧៨ គឺប្រាកដណាស់ពេលនុ៎ងលោកនៅទីនោះនៅឡើយ។ ហើយអ្នកមកជំនួសគាត់គឺ ពៅ ស៊ាប ត្រូវបានចាប់ខ្លួន។ ហើយ ពៅ ស៊ាប ជាសមាជិករបស់ស្រុកបវេល គឺត្រូវបានចាប់ខ្លួននៅថ្ងៃ៣០ មករា ៧៨ ដូចគ្នា។ តើលោកដឹងដែរឬទេ នៅពេលដែលលោកនៅថ្មគោល នៅពេលដែលលោកធ្វើការនៅមន្ទីរតំបន់នេះ តើលោកដឹងអំពីការចាប់ខ្លួនកម្មាភិបាលមកពីស្រុកបវេលទេ?

**ប្រធានអង្គជំនុំ៖**

ដាច់ៗអ៊ីនធឺណេតទៀតហើយ។

*(មានបញ្ហាបច្ចេកទេស)*

[១៤:០០:០០]

**ប្រធានអង្គជំនុំ៖**

សួស្តីលោកសាក្សី!

**2-TCW-971៖**

បាទ សួស្តីលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

បាទៗអរគុណ។ អំមិញដាច់អ៊ីនធឺណេត ឥឡូវយើងបន្តទៀតណា៎។

E1/514.1

**2-TCW-971៖**

បាទៗ។

**ប្រធានអង្គជំនុំ៖**

បាទ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ រៀបចំសំណួរចុងក្រោយរបស់លោកសាឡើងវិញ ព្រោះទំនងជាភ្លេចបាត់ហើយ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោក ខ្ញុំបានអាននូវកំណត់ត្រាពីស-២១ គឺទួលស្លែង ដែលបង្ហាញថាលេខាស្រុកបរេលត្រូវបានចាប់ខ្លួននៅខែមិថុនា ៧៨ ហើយអនុប្រធានរបស់គាត់គឺ គីម។ គីម ជាសមាជិកស្រុកត្រូវបានចាប់ខ្លួននៅថ្ងៃ៣០ មករា ៧៨ រួមជាមួយសមាជិកស្រុកម្នាក់ទៀតគឺឈ្មោះ ពៅ ស៊ាប គឺនៅថ្ងៃជាមួយគ្នា។ តើលោកដឹងអំពីការចាប់ខ្លួនរបស់ប្រធាន អនុប្រធានស្រុកបរេលនៅពេលដែលធ្វើការនៅថ្នល់គោលនោះទេ?

[១៤:០១:០៩]

**2-TCW-971៖**

**ឆ៖** បាទ អត់បានដឹងអីសោះ រឿងអស់នេះ។ ខ្ញុំវាថ្នាក់តូចតាច គេមិនឲ្យដឹងទេ អារឿងអីចេះរឿងធំៗ។ ហើយម៉្យាងទៀតវារយៈពេលវាខ្លីពេក ខ្ញុំអត់បានទាន់ស្គាល់ទឹក ស្គាល់ដី ស្គាល់អ្នកណាស្គាល់អ្នកណីអស់ ក៏ផ្លាស់ទៅទៀត។ ដូច្នេះសរុបមក គឺអត់បានដឹងឮ ដឹងស្គាល់អីទាំងអស់ អ្នកប៉ុន្មាននាក់នេះ មិនដឹងជាអភិបាលស្រុក -- គណៈស្រុកមុនហ្នឹងអ្នកណាខ្លះផង។

**ស៖** នៅពេលដែលលោកទៅដល់ដូនទាវ គឺថាលោកនៅនោះតែ១០ថ្ងៃទេ តើមានអ្នកណាជាអ្នកគ្រប់គ្រងនៅដូនទាវទេ?

**ឆ៖** ពេលដែលខ្ញុំទៅនៅហ្នឹង គឺមានតែឃុំគេម្នាក់ដែលខ្ញុំបានចូលទៅជួប។ ឃុំហ្នឹងនៅនឹងកន្លែងឃុំគេម្នាក់ហ្នឹង ហើយក្រៅពីនោះទៀត ខ្ញុំអត់បានទំនាក់ទំនងទេ ខ្ញុំធ្វើតាមបញ្ជារបស់ តាចាយហ្នឹង ក៏ឲ្យដើរមើលតាមសហករណ៍តែម្តង រៀបរយ សួរតាមសហករណ៍។

**ស៖** តើលោកស្គាល់ឈ្មោះ វង់ <ហើយឈ្មោះពិតរបស់គាត់គឺ ឡឹក សឿត>ដែលក្លាយជាលេខាតំបន់៤ទេ?

**ឆ៖** បាទ អត់ស្គាល់ទេ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**លោក ស្រ៊ា រតនៈ៖**

ឈ្មោះដែលគាត់បានលើកឡើងអម្បាញ់មិញនេះ គឺឈ្មោះ ឡឹក សឿត ហៅ វង់។

**2-TCW-971៖**

**ឆ៖** បាទ អត់ បាទៗអត់ស្គាល់ទេ។

[១៤:០២:៥៧]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ដើម្បីជាកំណត់ត្រាប្រតិចារឹក គឺឈ្មោះនេះ គឺលេខ ៤៣៩៥ នៅក្នុងបញ្ជីស-២១។ លោកបាននិយាយអំពីការចាប់ខ្លួន តើលោកធ្លាប់ឮ តាម៉ុក និយាយអំពីខ្មាំងទេ?

**ឆ៖** បាទ ពាក្យ "ខ្មាំង" នេះខ្ញុំ សូម្បីតែក្មេងវានិយាយគ្នា ក៏វាប្រើដែរ ក៏និយាយគ្នាដែរ យើងមនុស្សធំហ្នឹង និយាយជាមួយគ្នាឯង តែខឹងអី អាងតែយកពាក្យហ្នឹងមកដាក់ ប៉ុន្តែមិនដឹងថាគេសំដៅទៅលើពួកអ្នកណា។ ក្មេងៗជជែកគ្នា ក៏វាប្រើពាក្យហ្នឹងដែរ។

**ស៖** ចុះអ្នកដែលគេចាត់ទុកថាខ្មាំងហ្នឹង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង តើមានអីកើតឡើងចំពោះអ្នកដែលគេហៅថាខ្មាំង ឬក៏ចាត់ទុកថាខ្មាំងនោះ?

**ឆ៖** ខ្ញុំអត់ដឹងថាគេផ្តោតទៅលើអី ព្រោះមនុស្សឃើញដូចតែគ្នា មនុស្សប្រុស មនុស្សស្រី មនុស្សម្នា ខ្មែរដូចគ្នា មិនដឹងគេសំដៅទៅលើពួកណា គេហៅថាខ្មាំង ខ្ញុំមិនស្គាល់ទេ មិនៗចាប់អារម្មណ៍ដល់កម្រិតណាដែលគេហៅខ្មាំង។

**ស៖** ខ្ញុំនឹងអានចម្លើយដែលលោកប្រាប់អ្នកស៊ើបអង្កេត ហើយខ្ញុំនឹងឲ្យលោកពន្យល់។ គេសួរ៖ "ថាតើនៅពេលប្រជុំ គេធ្លាប់និយាយអំពីខ្មាំង ឬក៏ពួកក្បត់ទេ? លោកឆ្លើយថា៖ បាទ គេនិយាយថាឲ្យប្រុងប្រយ័ត្នពីខ្មាំងស៊ីរូងផ្ទៃក្នុង ហើយនិងតាមដានសកម្មភាពខ្មាំង។" ដូច្នេះខ្ញុំចង់សួរលោក ថាតើអ្នកណាជាអ្នកនិយាយពាក្យនេះ?

[១៤:០៤:៣៨]

**ឆ៖** និយាយ ថាអ្នកនិយាយហ្នឹងគឺគេអ្នកដឹកនាំប្រជុំ គេពង្រឹងដឹកនាំប្រជុំហ្នឹង គេតែង គេច្រើនប្រើពាក្យហ្នឹងឯង។

**ស៖** តើអ្នកណាជាអ្នកដឹកនាំការប្រជុំដែលលោកនិយាយហ្នឹង?

**ឆ៖** ដឹកនាំប្រជុំនៅថ្នាក់ខាងខ្ញុំហ្នឹង មានតែ តាចាយ ហ្នឹងឯង គាត់ប្រជុំ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើ តាចាយ គាត់ធ្លាប់និយាយអំពីយោធា លន់ នល់ ដែលយើងគួរតែតាមរក ឬមួយក៏តើគាត់ធ្លាប់និយាយអ្វីទាក់ទងទៅនឹងអតីតអ្នករដ្ឋការ ឬក៏យោធា លន់ នល់ ទេ?

**ឆ៖** គាត់មិនដែលនិយាយអីទេ ការប្រជុំម្ដងៗគឺសំខាន់ គឺការបង្កបង្កើនផល ប៉ុណ្ណឹង។ អត់ដែលទៅនិយាយអីពីរឿងអតីតកាលរបស់ទាហាន លន់ នល់ អី គាត់មិនដែលនិយាយផង។

**ស៖** នៅក្នុងការសម្ភាសហ្នឹងគឺថា លោកបានប្រាប់អ្នកស៊ើបអង្កេតថា គេឲ្យលោកប្រយ័ត្នអំពីក្រុមស៊ីរូងផ្ទៃក្នុង។ ហើយគេសួរថា តើលោកចង់និយាយមានន័យម៉េច នៅពេលដែលថា ជនបង្កប់ស៊ីរូងផ្ទៃក្នុងហ្នឹង គឺលោកថា គឺជាសំដៅទៅលើទាហាន លន់ នល់ ដែលអាចនឹងត្រឡប់មកបះបោរវិញ។ តើលោកចង់មានន័យយ៉ាងម៉េច? ថាតើគេមានប្រាប់លោកអ្វីដែរ ទាក់ទងទៅនឹងយោធា លន់ នល់?

**ឆ៖** គេនិយាយពីរឿងពួកស៊ីរូងផ្ទៃក្នុង គេនិយាយកម្លាំងបង្កប់ ដូចលោកមេធាវីមានប្រសាសន៍ដែរ សំដៅទៅលើពួក លន់ នល់ ស៊ីរូងផ្ទៃក្នុង សំដៅទៅលើមនុស្សខាងហ្នឹងឯង។

**ស៖** តើគេឲ្យលោកធ្វើអី? ឲ្យតាមរក ឲ្យកំណត់មុខសញ្ញា ឬមួយក៏យ៉ាងម៉េច?

[១៤:០៦:៥៣]

**ឆ៖** មិនមែនទេ គាត់ថាឲ្យប្រយ័ត្នប្រយែងនៅក្នុងអង្គភាព ក្រែងលោមានសកម្មភាពអីដែលសេរីរើ ប៉ុណ្ណឹងទេ។

**ស៖** នៅក្នុងសំណួរចម្លើយទី៧១ លោកបានឆ្លើយថា៖ “នៅពេលដែលលោកទៅដល់ថ្មគោល គឺថា មានអ្នកជំនាញនៅក្នុងមន្ទីរតំបន់ ដូចជា ជាងថតរូប ជាងជួសជុលម៉ូតូឡានជាដើម ត្រូវបានគេបញ្ឈប់ទាំងអស់។ ក្រោយពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំក៏បានឲ្យគេទៅរកមនុស្សទាំងនោះត្រឡប់មកវិញដើម្បីធ្វើការដូចមុន ប៉ុន្តែខ្លះបាត់ខ្លួនទៅហើយ។” តើលោកយល់យ៉ាងណាដែរ ឬក៏លោកគិតយ៉ាងណាដែរនៅពេលដែលលោកប្រើពាក្យថា “បាត់ខ្លួន” នោះ?

**ឆ៖** ការប្រើពាក្យ “បាត់ខ្លួន” ដោយសាររកមិនឃើញ ហើយមនុស្សអស់នោះ មិនដឹងជាស្រុកកំណើតហ្នឹងនៅឯណាខ្លះ។ ឲ្យអ្នកជិតខាងសួរទៅថា ខ្លះក៏ស្គាល់ ពុំស្គាល់ អត់ឃើញមកវិញ រកមនុស្សនោះវាមិនឃើញ។ ខ្លះក៏នៅឆ្ងាយអីចឹងទៅ ព្រោះកាលហ្នឹងគេប្រមូលផ្ដុំមនុស្ស មិនមែនយកតែអ្នកជិតៗហ្នឹង។

**ស៖** លោកសាក្សី ខ្ញុំចង់ឲ្យលោកឆ្លើយទៅនឹងអ្វីដែលអ្នកមកពីខាងពាយ័ព្យម្នាក់ដែរ បានប្រាប់ គឺឯកសារ E3/1593 ខ្មែរមានលេខ <006377991>*(ស៊ីក)*, បារាំងមានលេខ 00639207, អង់គ្លេស

មានលេខ <01150217>។ "អ្នកមូលដ្ឋានម្នាក់ទៀត ឈ្មោះ <សារី> បានបញ្ជាក់ថា៖ "នៅក្នុងឆ្នាំ៧៨ មានមនុស្សប្រហែលជា៨ទៅ១០នាក់ គឺគេចែកឲ្យអង្ករមួយកំប៉ុង។ ខាងនិរតីចោទប្រកាន់ពាយ័ព្យថាឲ្យអ្នកពាយ័ព្យ ឲ្យស៊ីបបរ ព្រោះនៅពេល -- ទោះបីជាមានស្រូវក៏ដោយ ប៉ុន្តែនៅពេលដែលនិរតីមកដល់ហ្នឹង គឺខ្វះខាតជាងពាយ័ព្យទៅទៀត។" អ្នកមូលដ្ឋាននៅពាយ័ព្យនេះ គឺបាននិយាយថា ស្ថានភាពវាកាន់តែអាក្រក់ជាងមុនទៅទៀត ទាក់ទងទៅនឹងរបបអាហារនៅពេលដែលពួកនិរតីមកដល់។ តើលោកអាចពន្យល់បានទេ?

[១៤:០៩:៤៦]

**ឆ៖** សកម្មភាពបែបនេះ មិនដឹងកើតមាននៅកន្លែងណាទេ ក៏ប៉ុន្តែបើកន្លែងខ្ញុំ កាលខ្ញុំមកនៅថ្ងៃគោលហ្នឹង គឺមានតែប្រជាពលរដ្ឋ គេសរសើរ គេសប្បាយរីករាយ ដែលយើងបានស្និទ្ធស្នាលជាមួយគេ ហើយយើងបានឲ្យជាអង្ករ ជារបស់របរប្រើប្រាស់ហូបចុកអី។ តែសកម្មភាពដែលបែរជាធ្វើឲ្យលំបាកជាងដើមហ្នឹង គឺមិនដឹងនៅត្រង់កន្លែងណា។

**ស៖** តើលោកធ្លាប់ឃើញមេដឹកនាំចិន <>អឹង យឹងគួយ មកខាងនិរតី<ក្នុងខែធ្នូ ឆ្នាំ១៩៧៧> ដែរឬទេ?

**ឆ៖** អូ!-- <បាទ អត់សោះ លោកមេធាវី។ រឿងអស់អីចេះ -- ខ្ញុំមិនដែលបានទៅជិត-->

**ប្រធានអង្គជំនុំ៖**

កុំ! កុំអាលទាន់ឆ្លើយ!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:១០:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឆ្លើយរួចទៅហើយ ប៉ុន្តែតាមពិតទៅ គឺគាត់ទៅខាងពាយ័ព្យទេ <>នៅក្នុង<ខែធ្នូ>ឆ្នាំ៧៧។

**លោក នីកូឡាស គូមជែន៖**

គឺទស្សនកិច្ចទៅនិរតីនៅក្នុងខែធ្នូ ឆ្នាំ៧៧ គឺទៅត្រាំកក់។ ខ្ញុំគិតថា មេធាវីយល់ច្រឡំទេ គឺទៅត្រាំកក់ ហើយគាត់ឈប់នៅទីនោះ ហើយគាត់ចូលទៅមើល គឺនៅក្នុងឯកសារហ្វីប៊ីស <E3/1339> ហើយសៀវភៅ "<បងប្អូនរួមអាវុធ>"<E3/9642> ក៏បានរៀបរាប់ដែរ។ ខ្ញុំគិតថាមេធាវីយល់ច្រឡំ។

**លោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្ញុំគិតថា គាត់ទៅត្រពាំងថ្មនៅពាយ័ព្យ ប៉ុន្តែប្រហែលជាគាត់ទៅខាងនិរតី ប៉ុន្តែមិនអីទេ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំបានបញ្ចប់សំណួរដែលខ្ញុំចង់សួរសាក្សីរួចទៅហើយ។ ហើយប៉ុន្តែមុននេះ ខ្ញុំបានបញ្ជាក់ថា ខ្ញុំនឹងសួរទាក់ទងទៅនឹងការសម្លាប់ខ្មែរក្រោម គឺថាទាក់ទងទៅនឹងការដកស្រង់ដែលខ្ញុំនិយាយអំពីការសម្លាប់ខ្មែរក្រោម<ដែលកើតឡើងក្នុងខែសីហា ឬពេលក្រោយមកទៀតក្នុងឆ្នាំ១៩៧៨>។ ដូច្នេះគឺខ្ញុំចង់បញ្ជាក់ថា គឺថា<ប៉ុន្មាន>ខែក្រោយពេល រស់ ញឹម ស្លាប់ហើយ វាក៏ពាក់ព័ន្ធទៅនឹងអ្វីដែលមេធាវីការពារក្ដីបានសួរទាក់ទងទៅនឹង រស់ ញឹម ហើយនិងខ្មែរក្រោម គឺខ្ញុំសូមបញ្ជាក់អំពីឯកសារយោងគឺ <E3/10683> គឺជាកំណត់ហេតុស្ដាប់ចម្លើយរបស់ឃាតករម្នាក់ ដែលសម្លាប់ខ្មែរក្រោមដែលត្រូវបានស្ដាប់ចម្លើយ។ គាត់បាននិយាយអំពីការសម្លាប់ ហើយនិងការប្រជុំ<ចេញបញ្ជា>។ ហើយនៅក្នុងសំណួរចម្លើយ<១១៤> គាត់និយាយថា ការប្រជុំហ្នឹង ធ្វើឡើងនៅខែសីហា នៅពេលនុំងគឺជាពេលដែលគេកំពុងតែចាប់ផ្ដើមដាំដុះស្រូវនៅឡើយ។ ហើយការសម្លាប់កើតឡើងក្រោយពេលដែលមានការប្រជុំ។ ហើយ <E3/5908> និង <E3/9515> គឺដើមបណ្ដឹងរដ្ឋប្បវេណី បានបញ្ជាក់អំពីចម្លើយថា ក្នុងខែកក្កដា និង សីហា <ពួកគេបានបញ្ជាឲ្យ>កងកុមារ<នៅក្នុងឃុំនោះ>ឲ្យ<>ជីករណ្ដៅ ដែលគេប្រើដើម្បីកប់ខ្មែរក្រោមដែលត្រូវគេសម្លាប់។ ដូច្នេះរណ្ដៅហ្នឹង ត្រូវបានគេ ជីកនៅក្នុងខែកក្កដា សីហា<ឆ្នាំ១៩៧៨>។

[១៤:១៣:៣៩]

<E3/9758> គឺជាការសម្ភាស<រវាងដើមបណ្ដឹងរដ្ឋប្បវេណី> ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា គឺនៅក្នុងខែតុលា ៧៨ ដែលមានហេតុការណ៍<សម្លាប់>នេះ។ រីឯឯកសារ E3/9519 គឺនិយាយអំពីការប្រជុំដដែលនេះ ដែលថាការបញ្ជាហ្នឹង គឺចេញពី<កម្មាភិបាល>និរតី ដោយ យាយរីម <នៅចុងឆ្នាំ១៩៧៨>។ ដូច្នេះភស្តុតាងដែលមាននៅក្នុងសំណុំរឿង គឺបញ្ជាក់ច្បាស់ណាស់ថា<នៅស្រុកបាកាន> មានការសម្លាប់ខ្មែរក្រោមហ្នឹង គឺប៉ុន្មានខែក្រោយពេលដែល រស់ ញឹម បានស្លាប់ទៅ ហើយធ្វើឡើងដោយខាងនិរតីនោះទេ។

**លោក វិចទ័រ កូប៉េ៖**

ដោយសារតែព្រះរាជអាជ្ញា គាត់លើកទឡ្ហីករណ៍បែបនេះ ខ្ញុំសូមឆ្លើយតប។ គាត់គឺជាសាក្សីទី១ដែលយើងអាចជឿជាក់បាន នៅពេលដែលយើងនិយាយអំពីខែ ព្រោះថា ភាគច្រើនសាក្សី គឺគាត់មិនចាំ

អំពីខែ<ឆ្នាំ>ដែលកើតឡើងនោះឡើយ។ ហើយម្យ៉ាងទៀត <ចំណុចនេះមិនបានដកចេញនូវអង្គហេតុដែលថា> ប៉ុល ពត <>គាត់អាចស៊ើបអង្កេតអំពីការដែល រស់ ញឹម សម្លាប់ទៅលើខ្មែរក្រោម។ <ចំណុចមួយដែលមិនដកចេញអ្នកផ្សេងទៀត។> នេះគឺជាអ្វីដែលខ្ញុំចង់ឆ្លើយតប។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន សូមអនុញ្ញាតឱ្យលោក ឡោ ជុនធី ជាអ្នកសួរសំណួរ លោកប្រធាន។ សូមអនុញ្ញាត។

[១៤:១៥:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក ឡោ ជុនធី៖**

បាទ សូមគោរពលោកប្រធាន សូមគោរពអង្គជំនុំជម្រះទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមជម្រាបសួរលោកពូ។ ខ្ញុំបាទ ឡោ ជុនធី ហើយជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំមកពីអង្គការជំនួសអ្នកច្បាប់នៅកម្ពុជា។ តទៅនេះ ខ្ញុំបាទសូមជម្រាបសួរនូវសំណួរមួយចំនួន ដែលលោកពូមានបទពិសោធន៍ ថាតើនៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ តើលោកពូនៅខេត្តតាកែវហ្នឹងទទួលមុខងារធ្វើជាអ្វីដែរ?

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអ៊ីនធឺណែតទៀតហើយ។

*(មានបញ្ហាបច្ចេកទេស)*

[១៤:១៨:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញតទៀត!

សួស្តីលោកសាក្សី លោកឮទេ?

**2-TCW-971៖**

បាទៗ ឮហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** បាទ អរគុណ។ ខ្ញុំសូមរំឭកសំណួរលោកពូឡើងវិញថា តើនៅក្នុងឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ ១៩៧៧ តើលោកនៅខេត្តតាកែវហ្នឹង លោកធ្វើការងារអ្វីដែរ? ហើយមានឋានៈតួនាទី ហើយនៅកន្លែងណា?

**2-TCW-971៖**

**ឆ៖** បាទ ឆ្នាំ៧៥ទៅដល់ឆ្នាំ៧៧ ខ្ញុំបង្រៀន ៗកុមារ គ្រូបង្រៀនកុមារ ហើយនិង កុមារតូច កុមារជំទង់ហ្នឹងឯង។

**ស៖** បាទ អរគុណ។ ចុះថាតើពេលដែលលោកនៅទីនោះ លោកបានសម្គាល់ឃើញថាមានប្រជាជនដែលទៅពីភ្នំពេញនៅទីនោះអត់ទេ?

**ឆ៖** បាទ ខ្ញុំសម្គាល់ឃើញមាន មានទៅតើ ទៅនៅនឹងភូមិឋានរបស់ប្រជាពលរដ្ឋមូលដ្ឋានហ្នឹង។

[១៤:២០:៣៣]

**ស៖** អរគុណ។ ថាតើនៅក្នុងរយៈពេលពី៧៥ដល់៧៧ហ្នឹង លោកពូបានសង្កេតឃើញថាប្រជាជននៅទីនោះមានជីវភាពយ៉ាងដូចម្តេចដែរ?

**ឆ៖** ប្រជាជននៅទីនោះ ទាំងកុំនិយាយពីរឿងចាស់ រឿងថ្មី ដូចគ្នា ការហូបចុកហ្នឹង ខ្ញុំជម្រាបមិនលាក់លៀម និយាយត្រង់ គឺហូបបាយតែពីរបីខែទេ ដល់ហើយពីហ្នឹងទៅគឺដល់ចុង ពាក់កណ្តាលឆ្នាំទៅចុងហ្នឹង គឺគេហូបបបរ ឬក៏បាយទន់ៗ តែប៉ុនទុំងឯង ដូចគ្នា។

**ស៖** បាទ អរគុណ។ ថាតើលោកពូមានសង្កេតឃើញថា មានគេបញ្ជូនប្រជាជនពីនិរតីទៅខាងពាយ័ព្យហ្នឹងអត់ទេ?

**ឆ៖** បញ្ជូនប្រជាជន ខ្ញុំមិន ស្ដាប់សំណួរមិនបាន សូមមួយសាទៀត។

**ស៖** ថាតើមុនលោកពូចេញទៅបាត់ដំបងហ្នឹងណា--

**ឆ៖** បាទៗ។

**ស៖** លោកពូមានដឹងថាតើមានគេបញ្ជូនប្រជាជនពីខាងតាកែវហ្នឹងទៅបាត់ដំបងទេ?

**ឆ៖** មានការបញ្ជូនមុនហ្នឹង គឺខ្ញុំមិនបានដឹងថាតើមានប្រជាជនប៉ុន្មាន និងកម្មាភិបាលប៉ុន្មានទេ។ តែដល់ខ្ញុំមកហ្នឹង គឺលើកដែលខ្ញុំមកហ្នឹង គឺមានកម្មាភិបាលតែពីរបីនាក់ទេ ឯក្រៅពីហ្នឹង សុទ្ធក្រុមគ្រួសារ។ គឺមានតែក្រុមគ្រួសារ ហើយមនុស្ស យុវជន ហ្នឹងមកលើកខ្ញុំហ្នឹង លើក១ទី៣ហើយ។

[១៤:២២:១៩]

**ស៖** បាទ អរគុណ។ គឺលោកពូបានលើកឡើងថា លោកពូបានទៅបាត់ដំបងនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៨ ថាតើនៅពេលដែលលោកពូបានទៅដល់ទីនុំង បានឃើញទិដ្ឋភាព និងជីវភាពប្រជាជននៅទីនោះយ៉ាងដូចម្ដេចដែរ?

**ឆ៖** ពេលដែលខ្ញុំទៅដល់ ទៅដល់បាត់ដំបងហ្នឹង ខ្ញុំចុះទៅមើលតាមការដ្ឋាន ដូចបានជម្រាបពីខាងដើមហើយ ទៅជា ទៅដូនទាវអី ទៅហ្នឹងទៅ ៗមើលឃើញសហករណ៍ហ្នឹងគឺការហូបចុក នៅសហករណ៍ហូបធម្មតា ការខុសប្លែកគ្នាខ្លះនៅតាមកងចល័ត។ សួរថាហេតុអីបានជាអីចឹង? គាត់ឆ្លើយថាមកពីការដឹកជញ្ជូនអីខ្លះមិនទាន់ពេលវេលា។ អាហ្នឹងខ្ញុំសំដៅទៅលើបាយ ឯការម្ហូបដែលហូបជាមួយបាយហ្នឹងធម្មតា តាមការរកបាន។

**ស៖** បាទ ចំណុចមួយទៀតថា តើ តាម៉ុក ដែលគាត់ថា បានបញ្ជូនលោកពូទៅហ្នឹង តើគាត់គ្រប់គ្រងប៉ុន្មានភូមិភាគដែរ លោកពូដឹងដែរអត់ទេ?

**ឆ៖** បាទ ខ្ញុំកាលខ្ញុំនៅតាកែវ ឯតាកែវហ្នឹងក៏គាត់គ្រប់គ្រង ហើយដល់ហើយ ដល់មកខ្ញុំដល់បាត់ដំបង គាត់មកដល់បាត់ដំបងដែរ មកនៅឯ ថាមកនៅបាត់ដំបងដែរ។ ដូច្នេះប្រហែលជាគាត់គ្រប់គ្រងពីរកន្លែង ហ្នឹងតាមខ្ញុំយល់។ ប៉ុន្តែអីចេះបាទ សូម! ពេលដែលគាត់មកដល់បាត់ដំបងហ្នឹងគឺសភាពការណ៍ព្រំដែនវាដូចថា វាមានប្រែប្រួលហើយ។

**ស៖** បាទ អរគុណ។ ចំណុចមួយទៀត ដែលសូមលោកពូជម្រាបមើល ថាតើនៅពេលប្រជុំម្ដង ៗជាមួយ តាម៉ុក ឬមួយជាមួយអ្នកផ្សេង ថាតើគាត់បានលើកអំពីចំណុចបញ្ហាអ្វីខ្លះដែលជូនទៅដល់អង្គប្រជុំ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:២៤:៤១]

**ឆ៖** ការប្រជុំធំៗ ខ្ញុំមិនដែលបានចូលទេជាមួយ តាម៉ុក អី គេមិនហៅខ្ញុំទេ ខ្ញុំថ្នាក់តូចតាច។ មានតែ តាចាយ ទេដែលគាត់ទៅប្រជុំ ប៉ុន្តែដល់ចំណែកខាងខ្ញុំ ៗមិនដែលបានទៅចូលរួមជាមួយគាត់ទេ។

**ស៖** បាទ ចំណុចមួយទៀត លោកបានលើកឡើងនូវពាក្យមួយថា "គេចង់ដុតឲ្យខ្លោច រោលឲ្យឆៅ" តើចំណុចពាក្យនេះដែលនៅក្នុងចម្លើយរបស់លោក០៣ នៅក្នុងលេខឯកសារ E3/9593 តើមានន័យម៉េច លោកអាចពន្យល់បានទេ?

**ឆ៖** បាទ ចំពោះពាក្យដែលខ្ញុំនិយាយថា "ចង់ដុតឲ្យខ្លោច រោចឲ្យឆៅ" ដោយសារខ្ញុំតាមដានសកម្មភាពការងារហ្នឹងទៅ ដូចកាលពីមុនខ្ញុំទៅ គេប្រមូលផ្តុំ ហើយមានដូចថាជម្រាបក្នុងអង្គរអី សេសសល់ខ្លះ ដល់ទៅក្រោយអ្នកក្រោយបញ្ជាឲ្យខ្ញុំរំសាយកងចល័ត ហើយឲ្យចុះទៅពិនិត្យសើរើ។ ដូច្នេះពីរហ្នឹងដឹកនាំពីរហ្នឹង វាដូចជាអត់ស៊ីគ្នា។ អ៊ីចឹងបានខ្ញុំថា ម្ខាងណាគេហៅជា ម្ខាងណាគេគំនិតចង់ដុតឲ្យខ្លោច រោចឲ្យឆៅ បានន័យថា វាអត់មានឯកភាពគ្នាថ្នាក់ដឹកនាំពីរ ទាំងពីរហ្នឹង។

**ស៖** បាទ អរគុណ។ តាមអ្វីដែលលោកពូបានឆ្លើយនេះ ថាតើលោកពូកត់សម្គាល់យ៉ាងដូច្នេះ ហើយលោកពូនៅតែធ្វើការដឹកនាំជាបន្តបន្ទាប់ទៀត ឬមួយមានការភ័យខ្លាច ឬយ៉ាងណាដែរអត់ទេ?

**ឆ៖** បាទ សូមជម្រាបត្រង់ៗ កាលធ្វើការងារក្នុងជំនាន់នុំងសុទ្ធតែរងា ព្រួយបារម្ភដែរ ពិតមែនថាយើងវាមិនជាស្អី ក៏ប៉ុន្តែ តែប្រើអីធ្វើហ្នឹងហើយ មានការខ្លាច។

**ស៖** បាទ ខ្ញុំសូមបន្តថា តើការខ្លាចរបស់លោកពូ ពាក់ព័ន្ធទៅនឹងអ្វីដែលបានលើកឡើងថា ឲ្យប្រយ័ត្នពួកស៊ីរូងផ្ទៃក្នុងហ្នឹង ឬមួយយ៉ាងណា?

[១៤:២៧:២៥]

**ឆ៖** បាទ ខ្ញុំប្រយ័ត្នរឿងអស់ហ្នឹងមួយ ខ្លាចគេចោទ។ គេចោទប្រកាន់ថា ទៅជាបក្សពួកនេះបក្សពួកនោះ ខ្លាចគេអ៊ីចឹង ម្ល៉ោះហើយធ្វើតម្រង់ទៅតាមបែបដែលបញ្ជា គេឲ្យធ្វើអីគឺធ្វើហ្នឹង មិនហ៊ានឈប់ តាមចិត្តវាមិនចង់ប៉ុន្នានទេ គ្រាន់ថាយើងឈប់ ៗវាមិនកើត។

**ស៖** បាទ ចំណុចមួយទៀតជាសំណួរខ្ញុំចុងក្រោយថា តើនៅពេលដែលលោកពូបានទៅដល់ទីនោះ ពេលនោះលោកពូថាបានទៅកែប្រែ ឬមួយរំសាយ ឬមួយអីហ្នឹង ទៅដល់កងចល័ត ថាតើពេលនោះលោកពូបានរៀបចំរចនាសម្ព័ន្ធរបស់ខ្លួន ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ សូមជម្រាបលោកមេធាវី ពេលដែលខ្ញុំទៅដល់នោះគឺទាន់ហន់ណាស់។ ទាន់ហន់

បានន័យថា ចុះទៅធ្វើការភ្លាមៗ មិនបានរៀបចំរចនាសម្ព័ន្ធអី ទៅតែគ្នាពីរបីនាក់។ ទៅដល់រៀបចំចាត់ចែងរំសាយ ៗអីចឹងទៅ យើងក៏ថយមក មិនដឹងជាសភាពការណ៍ក្រោយហ្នឹងវាមានការប្រែប្រួលយ៉ាងម៉េចទៀត។ តិចឱ្យខ្ញុំទៅត្រង់ណេះ តិចឱ្យខ្ញុំទៅត្រង់ណោះ។

**ស៖** គឺមួយទៀតដែល តើលោកពូស្គាល់ឈ្មោះ តាទិត្យ ដែរឬទេ?

**ឆ៖** អ៊ុំ! តាទិត្យ ហ្នឹងខ្ញុំធ្លាប់ស្គាល់គាត់តាំងពីគាត់នៅបួស គាត់បួសជាសង្ឃ ហើយកាលហ្នឹងនៅក្មេងៗ។ បានដល់ក្រោយមកខ្ញុំដឹងទៀត ដឹងថាគាត់បានសឹកនៅរវាងឆ្នាំ៧៥អីហ្នឹងឯង។ ហើយគាត់មិនដឹងទៅធ្វើអីឯណាខ្លះរហូតមកក្រោយមក ខ្ញុំក៏មិនបានដឹងពេលដែលផ្លាស់ចេញពី ស្គាល់គាត់តាំងគាត់នៅលោក។

**ស៖** បាទ អរគុណ។ ហើយតើលោកពូមានស្គាល់ឈ្មោះ យាយថែម ទេ? តើគាត់ធ្វើអ្វី?

**ឆ៖** បាទ យាយថែម ខ្ញុំស្គាល់តើ! ស្គាល់គាត់។ ស្គាល់ហ្នឹង មនុស្សហ្នឹងមនុស្សវានៅស្រុកឯណោះនៅឯស្រុកតាកែវដែរ ប៉ុន្តែគាត់មកពាយ័ព្យហ្នឹងមុន មកពាយ័ព្យមុន។ ហើយដល់មកដល់ពាយ័ព្យតាមខ្ញុំដឹង គាត់ធ្វើស្រុក នែ៎អី! នេះត្រង់នេះតើ! ភ្នំស្រុក! ហ្នឹងខ្ញុំដឹង។

**ស៖** បាទ អរគុណ។ ចំណុចចុងក្រោយមួយគឺ ថាតើលោកពូថាពេលដែលទៅហ្នឹង ឃើញមានកងចល័ត កងអី តើកងចល័តហ្នឹង គាត់កំពុងធ្វើអ្វីនៅទីនោះ?

**ឆ៖** បាទ គាត់ច្រូតស្រូវ ហើយកន្លែងខ្លះគេធ្វើប្រព័ន្ធ គេហៅស៊្ពីធ្វើប្រព័ន្ធភ្លឺស្រែ ក្រឡាឈើត្រង់អីនោះ ហើយអ្នកខ្លះក៏ច្រូតស្រូវ។ ហើយសំខាន់ -- ពិសេសក្រៅពីហ្នឹងទៀត មានខ្លះគេធ្វើទៅជាជីប្រមូល ជីប្រមូលអីហ្នឹង។ រឿងគេវាច្រើនណាស់ ការងារក្នុងកសិកម្មគេហ្នឹង។

**លោក ឡោ ជុនធី៖**

បាទ អរគុណ លោកប្រធាន។ ខ្ញុំបាទ អស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ចុងក្រោយផ្តល់វេទិកាជូនទៅមេធាវី -- អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៤:៣១:០៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក។ ជាដំបូង ជាសំណួរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សួរបន្តពីសំណួរកាលពីព្រឹកមិញ។ កាលពីព្រឹកមិញ សហព្រះរាជអាជ្ញាបានអានចម្លើយទី២៤របស់លោកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ឯកសារ E3/9593។ លោកបានឆ្លើយទៅអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា នៅក្រោមរបបនោះ លោកជាគ្រូបង្រៀន ហើយ<>និងឪពុកមារបស់<លោក>បីនាក់ ប្អូនបង្កើតពីរនាក់ និងបងប្អូនជីដូនមួយប្រាំពីរនាក់ បានស្លាប់ក្នុងរបបខ្មែរក្រហម។ ហើយកាលព្រឹកមិញ លោកឆ្លើយថាស្លាប់នៅក្រោមរបប លន់ នល់ ទេ។ អ៊ីចឹងខ្ញុំសួរលោកថាតើបងប្អូនជីដូនមួយរបស់លោកនេះ ប្រាំពីរនាក់ហ្នឹងគាត់ធ្វើនៅឯណា ធ្វើទាហាននៅក្នុងកងទ័ពបដិវត្ត ឬក៏កងទ័ព លន់ នល់ ទេ?

**2-TCW-971៖**

**ឆ៖** គាត់កងទ័ពបដិវត្តន៍ហ្នឹងឯង ដែលស្លាប់ហ្នឹង ព្រោះបងប្អូនជីដូនមួយ គឺនៅក្នុងកងទ័ពបដិវត្ត។ ហើយប្អូនស្រីមួយទៀតស្លាប់នៅក្នុងកងចល័ត។

**ស៖** ដូចអ៊ីចឹង បានថាពូរបស់លោក បង<ប្អូន>ប្រុសរបស់លោក ហើយនិងបងប្អូនជីដូនមួយរបស់លោកហ្នឹង មិនបានស្លាប់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ឪពុកមាស្លាប់នៅក្នុងរង្វង់ក្រោយ៧៥ ក្រោយ៧៥ បាត់ មិនដឹងគេហៅទៅណា។

**ស៖** ហើយឪពុកមាលោកហ្នឹង គាត់ជាយោធា ឬក៏ជាអ្វីដែរកាលណោះ?

[១៤:៣៣:៥១]

**ឆ៖** គាត់អតីតគ្រូបង្រៀន។

**ស៖** គាត់ជាគ្រូបង្រៀននៅដែលសង្គមចាស់ ដូចដែលលោកបានលើកឡើង គឺថារូបលោកផ្ទាល់ ហើយនិងឪពុកមារបស់លោកហ្នឹងជាគ្រូបង្រៀននៅក្នុងរបប លន់ នល់ ឬក៏ក្នុងរបបសង្គមចាស់ពីមុនមកនោះ អ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ឪពុកមាហ្នឹងតាំងពីសង្គមចាស់ រហូតមកក្នុងរបប លន់ នល់ ទៀតមក ចំណែកខ្ញុំក្រោយទេ។

**ស៖** ខ្ញុំឮថា ពូរបស់លោកបាត់ខ្លួន ឪពុកមារបស់លោកបាត់ខ្លួន តើការបាត់ខ្លួនរបស់គាត់នេះធ្វើឱ្យលោកព្រួយបារម្ភទេ?

**ឆ៖** បាទ ខ្ញុំមានការព្រួយបារម្ភ ដោយសារសាច់ឈាម វាបាត់បង់ដោយឥតដឹងមុខ។

**ស៖** លោកនិយាយថា មានក្រុមគ្រួសាររបស់លោកស្លាប់ អ៊ីចឹងខ្ញុំសួរលោកថាមានក្រុមគ្រួសារ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកស្លាប់ជាច្រើននាក់ ឬក៏មានតែឪពុកមាម្នាក់ហ្នឹងទេ?

**ឆ៖** ឪពុកមាម្នាក់ហ្នឹង បងប្អូនជីដូនមួយស្រីម្នាក់ ហើយនិងបងប្អូនបង្កើតស្រីម្នាក់ហ្នឹងនៅក្នុងរង្វង់ក្រោយឆ្នាំ៧៥។ ហើយក្រៅពីនោះ កាលពីសង្គ្រាមបដិវត្តន៍។ ក៏ប៉ុន្តែប្អូនស្រីម្នាក់ដែលស្លាប់នៅក្រោយ៧៥ហ្នឹង គឺដឹងមុខ គាត់ស្លាប់នៅក្នុងកងចល័ត ដោយជំងឺ។

**ស៖** ហើយឪពុកមារបស់លោក បងប្រុស បងស្រីរបស់លោកហ្នឹង សុទ្ធតែជាអ្នករស់នៅស្រុកត្រាំកក់មែនទេ?

[១៤:៣៦:៣៨]

**ឆ៖** បាទ។

**ស៖** តើលោកមានធ្លាប់ឮនិយាយពីមន្ទីរអប់រំកែប្រែមួយដែលឈ្មោះ "ក្រាំងតាចាន់" ដែរឬទេ?

**ឆ៖** ខ្ញុំគ្រាន់តែឮគេថា ប៉ុន្តែមិនដឹងនៅកន្លែងណា ខ្ញុំមិនដែលបានទៅអើតក្បែរ រឿងអ៊ីចេះៗគេមិនឲ្យខ្ញុំទៅជិតទេ។ ឮតែឈ្មោះគេនិយាយ។

**ស៖** តើលោកដឹងរឿងអ្វីខ្លះ អំពីការបាត់បង់ក្រុមគ្រួសារបង និងឪពុកមា ឬក៏បងប្អូនប្រុសស្រីបងប្អូនជីដូនមួយអីជាដើមហ្នឹង លោកបានដឹងរឿងអីខ្លះពីពួកគាត់ ពីការបាត់ខ្លួនពួកគាត់?

**ឆ៖** ប្អូនជីដូនមួយស្រីមួយដែលបាត់ខ្លួន គាត់ទៅធ្វើការនៅកងចល័ត ហើយគាត់ជាមនុស្សចេញពីភ្នំពេញមក ដោយឪពុកគាត់ធ្វើទាហាន។ ឪពុកមាខ្ញុំហ្នឹងធ្វើទាហាន បានកូនស្រីហ្នឹង ក៏ទៅក្នុងកងចល័ត បាត់វាអត់ឃើញ ដល់មកវិញ រកអត់ឃើញ។ ហើយឪពុកមាហ្នឹង មិនដឹងមានហេតុអីទៀតដែលបាត់ខ្លួនដែលខ្ញុំបានជម្រាបថា អត់ដឹងមុខហ្នឹង។ ខ្ញុំអត់បាននៅជិតគ្នាទេ ទៅធ្វើការឆ្ងាយៗគ្នា ប៉ុន្តែដល់ក្រោយមកបានដឹងព័ត៌មាន។

**ស៖** តើកាលនោះលោកមានបានគិតថា ការបាត់ខ្លួនរបស់ពួកគាត់ទាំងអស់ហ្នឹង វាអាចធ្វើឲ្យលោកគ្រោះថ្នាក់ដែរឬទេ? ឬក៏ធ្វើឲ្យគេសង្ស័យទៅលើរូបលោកដែរឬទេ ដែលគេសង្ស័យថា លោកហ្នឹងអាចជាខ្មាំងដែរ?

**ឆ៖** បាទ ខ្ញុំបានជម្រាបហើយតើ ខ្ញុំរងារដែរតើ ព្រោះអីសាច់ឈាមបាត់បង់ដោយអត់ដឹងមុខ ហើយមិនដឹងជាខ្លួនឯងហ្នឹងវាមានរឿងអីទៅ ក៏អត់ដឹងរឿងដែរ។ អ៊ីចឹងហើយ ម៉្លោះហើយចេះតែខិតខំកសាងខ្លួន គេប្រើធ្វើអី ធ្វើហ្នឹងទៅ។

[១៤:៣៩:០៨]

**ស៖** ខ្ញុំមានសំណួរមួយចំនួន ទាក់ទងទៅនឹងការងាររបស់លោកនៅមន្ទីរពាណិជ្ជកម្មស្រុកត្រាំកក់។ លោកឮខ្ញុំទេ លោកសាក្សី?

**ឆ៖** បាទ ខ្ញុំឮ បាទឮ។

**ស៖** ពេលដែលគេស្ដាប់លោកលើកដំបូង លោកផ្ដល់សក្ខីកម្មដំបូង លោកនិយាយថា មុនពេលចេញទៅបាត់ដំបងនោះ គឺមានកិច្ចប្រជុំមួយដែលមាន តាចាយ ហើយនិង តាម៉ុក ជាអធិបតីនៅមន្ទីរស្រុក គឺនៅផ្សារអង្គរកា។ លោកបាននិយាយដូចតទៅនេះ អំពី តាម៉ុក "គាត់ធ្លាប់ហៅយើងមកប្រាប់អំពីស្ថានការណ៍"។ នៅប្រតិចារឹកថ្ងៃទី០៩ ធ្នូ ឆ្នាំ២០១៦ ក្រោយម៉ោង១០:០២:៤៥វិនាទីបន្តិច។ លោកសាក្សី តើកាលដែលលោកធ្វើការនៅខាងពាណិជ្ជ<កម្ម>នៅអង្គរកាហ្នឹង លោកឧស្សាហ៍ត្រូវបាន តាម៉ុក ហៅទៅប្រជុំប្រាប់លោកអំពីស្ថានការណ៍ដែរឬទេ?

**ឆ៖** ចំពោះ តាម៉ុក ហើយនិងខ្ញុំកាលហ្នឹង មនុស្សកម្រឃើញមុខគ្នាណាស់ មិនចេះតែហ៊ានទៅជិតបានទេ ទាល់តែមានការអី ថ្ងៃហៅដែលប្រជុំថាឲ្យមកបាត់ដំបង គឺហៅ តាចាយ។ តាចាយ ហៅខ្ញុំបន្ត មកជាមួយគាត់។ បើតាមដែលគាត់ចុចហៅផ្ទាល់ គឺមិនដែរ។ ម្ល៉ោះហើយគាត់អ្នកធំៗ ខ្ញុំមិនសូវហ៊ានទៅក្បែរទេ។

[១៤:៤១:១៥]

**ស៖** លោកសាក្សី ខ្ញុំមិននិយាយអំពីអ្វីដែលកើតឡើងនៅបាត់ដំបងទេ ខ្ញុំនិយាយអំពីស្រុកត្រាំកក់ទេ។ តើនៅពេលដែលលោកធ្វើការនៅស្រុកត្រាំកក់នេះ តើលោកធ្លាប់ជួប តាម៉ុក ដែរឬទេ? ខ្ញុំនិយាយម្ដងទៀត អ្វីដែលលោកបានឆ្លើយនៅក្នុងសវនាការ<លើក>ទី០១ នៅទីនេះ លោកនិយាយថា តាម៉ុកហ្នឹងធ្លាប់ហៅយើងទៅប្រាប់ពីស្ថានការណ៍។ អ៊ីចឹងខ្ញុំសួរលោក ថាតើលោកធ្លាប់បានជួប តាម៉ុក ដែរឬទេ នៅពេលដែលលោកធ្វើការនៅត្រាំកក់?

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

លោកសាក្សីសម្រាកសិនចុះ ហើយយើងចាប់ផ្ដើមដំណើរការវិញ ចាប់ពីត្រឹមម៉ោងបីណា។ អ្ហ៎! អត់ឮ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤នាទី ដល់ម៉ោង ១៥:00 នាទី)*

[១៥:00:១៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បន្តការតាំងសំណួរដេញដោលចំពោះសាក្សី អង្គជំនុំជម្រះសូមសួរទៅមេធាវីការពារក្តីលោក ខៀវ សំផន តើមានសំណួរសួរដល់ចំពោះសាក្សីដែរឬទេ? ហើយប្រហែលជាទំនង បើមាន ទំនងប្រើពេលវេលាប៉ុន្មានដែរ?

**លោក គង់ សំអុន៖**

បាទ លោកចៅក្រម ឡាម៉ាក គាត់ -- ហ្សង់ម៉ាក ឡាវែន៍ គាត់ចប់សំណួរហើយនៅលោកប្រធាន? បើសិនចប់ហើយ ខ្ញុំអត់មានសំណួរទេ ប៉ុន្តែបើសិនជាគាត់មានសំណួរតទៅទៀត ហ្នឹងខ្ញុំនៅចាំសំណួរគាត់តទៅទៀតដែរ។ បាទ អញ្ជើញ!

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សួស្តីលោកសាក្សី តើលោកបានត្រៀមខ្លួនហើយនៅ?

**2-TCW-971៖**

បាទ រួចហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តទៅនេះផ្តល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរបន្តិចបន្តួចទៀតសួរទៅលោក គឺសំណួរសួរបន្តពីគេសួរលោកពីព្រឹកមិញទេ។ អម្បាញ់មិញនេះពេលដែលលោកឆ្លើយទៅនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកបាននិយាយថា មិនមានអ្នកណាមកពីភ្នំពេញដើម្បីមកធ្វើទស្សនកិច្ចនៅភូមិរបស់លោកនោះទេ។ អ៊ីចឹងលោកអាចឆ្លើយបញ្ជាក់បានដែរឬទេថា អ្នកមកភ្នំពេញហ្នឹងជាអ្នកណា? ហើយខ្ញុំសួរលោកផងដែរ តើលោកមានធ្លាប់បានឃើញ នួន ជា និង ខៀវ សំផន មកទស្សនកិច្ចនៅត្រាំកក់ ឬក៏តំបន់១៣ដែរឬទេ? ឬក៏ស្រុក១៣ ដែរឬទេ? បាទ តំបន់១៣ (សូមទោស)។

**2-TCW-971៖**

**ឆ៖** បាទ ខ្ញុំអត់ដែលបានឃើញគាត់ទេ។ តាំងពីឆ្នាំ៧០មករហូត អត់ដែលឃើញគាត់ទេ មិនដែលបានឃើញ អ៊ំជា ផង អត់ដែលឃើញគាត់មក។

**ស៖** ពេលលោកធ្វើការនៅផ្នែកពាណិជ្ជកម្មនោះ លោកអាចជម្រាបជូនតុលាការបានដែរឬទេថាអ្នកណាជាប្រធានរបស់លោក? ហើយអ្នកណាជាប្រធានខាងពាណិជ្ជកម្មហ្នឹងនៅត្រាំកក់ ឬក៏តំបន់១៣ហ្នឹង?

[១៥:០៣:២៩]

**ឆ៖** បាទ កាលហ្នឹងប្រធាន គឺប្រធានមន្ទីរ គេហៅប្រធានមន្ទីរស្រុកហ្នឹង លោក កាលហ្នឹងឈ្មោះលោក ឈឿត ប៉ុន្តែឥឡូវមិនដឹងគាត់ទៅណាទៅណីហើយ ខ្ញុំក៏មិនបានដឹង បែកគ្នាយូរណាស់ហើយតាំងពីកាលនុ៎ងមក។

**ស៖** ឈឿន ហ្នឹងគាត់ជាប្រធានមន្ទីរពាណិជ្ជកម្ម ឬក៏គាត់ជាប្រធានមន្ទីរស្រុក?

**ឆ៖** ប្រធានមន្ទីរស្រុក ប៉ុន្តែកាន់ មើលការខុសត្រូវកន្លែងពាណិជ្ជហ្នឹងដែរ។

**ស៖** សូមអរគុណ។ អ៊ីចឹងពេលដែលលោកទទួលបញ្ជា ឬក៏លោកត្រូវរាយការណ៍ហ្នឹងគឺលោកត្រូវរាយការណ៍ទៅគាត់ហ្នឹងឯង ហើយទទួលបញ្ជាក៏ពីគាត់ដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទៗ ត្រឹមត្រូវ។

**ស៖** តើនៅមន្ទីរស្រុកហ្នឹងមានអ្នកធ្វើការប៉ុន្មាននាក់ដែរ?

**ឆ៖** មានបួននាក់ បួននាក់។ មានខ្ញុំ គាត់ ហើយពីរនាក់ទៀតនោះឮថាស្លាប់មួយហើយ មិនដឹងដោយជំងឺអីទេ ម្នាក់ទៀតមិនដឹងទៅនៅឯណាទេ។ ហ្នឹងមានតែបួននាក់ទេ អ្នកនៅកន្លែងពាណិជ្ជ។

**ស៖** ឥឡូវខ្ញុំចង់ឲ្យលោកពន្យល់ខ្ញុំ អំពីភាពខុសគ្នារវាងតួនាទីរបស់លោក និងសកម្មភាពរបស់លោក ពេលលោកធ្វើការនៅត្រាំកក់ ហើយនិងតួនាទី ហើយនិងសកម្មភាពរបស់លោកពេលដែលគេបញ្ជូនលោកទៅពាយ័ព្យ។ តើមុខងាររបស់លោក តួនាទីរបស់លោក សកម្មភាពរបស់លោកហ្នឹង ដូចគ្នាដដែលទេ ឬក៏ខុសគ្នា? ហើយបើខុសគ្នាហ្នឹង ខុសគ្នាយ៉ាងដូចម្ដេចដែរ?

[១៥:០៥:៤៣]

**ឆ៖** បាទ ការធ្វើការងារ ពិតមែនតែនៅកន្លែងពាណិជ្ជដូចគ្នា ពាណិជ្ជហ្នឹងខ្ញុំបានជម្រាបហើយថាមិនមែនជាកន្លែងលក់ចេញ ទិញចូលទេ គឺគ្រាន់តែស្តុកអីវ៉ាន់សម្រាប់ចែកទៅសហករណ៍។ ហើយនៅកាលនៅៗត្រាំកក់នេះ មិនសូវរវល់ទេ មិនសូវមមាញឹក ញាប់ដៃញាប់ជើងទេ។ បានមានសម្រាកពេលស្អី។ បើមកបាត់ដំបងគឺ រវល់រហូត យ៉ាប់យឺនរហូត ដើរចុះដើរឡើង។ ខុសគ្នា នៅនេះមមាញឹកច្រើនជាងខាងបាត់ដំបង។

**ស៖** លោក ខ្ញុំយល់ថាលោកមានការងារច្រើនជាងនៅបាត់ដំបង តែខ្ញុំសួរលោក ថាតើមុខងាររបស់លោកផ្លាស់ប្តូរដែរឬទេ ឬក៏ការងារលោកនៅតែដដែលទេ គឺនៅតែគ្រប់គ្រងឃ្លាំង ហើយនិងបែងចែកអីវ៉ែអីវ៉ាន់ទៅឲ្យគេដដែលទេ?

**ឆ៖** បាទ នៅដដែល បាទលោកប្រធាន។

**ស៖** អម្បាញ់មិញលោកបាននិយាយអំពីស្ថានការណ៍នៅភូមិភាគពាយ័ព្យ ហើយនិងនៅកន្លែងដែលលោកបានទៅធ្វើការ ហើយលោកបាននិយាយថា អ្នកខ្លះហ្នឹងត្រូវការហូបចុកច្រើនជាងរបបអាហារដែលគេផ្តល់ឲ្យ។ តើមានរបបអង្ករដែលគេកំណត់ និងគណនាសម្រាប់មនុស្សម្នាក់ដែរឬទេ? តើមានបរិមាណណាមួយ ដែលបរិមាណអង្ករនេះដែលគេកំណត់ថា មនុស្សម្នាក់ត្រូវផ្តល់ជូនប៉ុន្មានក្នុងមួយថ្ងៃដែរឬទេ?

*(មានបញ្ហាបច្ចេកទេស)*

[១៥:០៩:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបជូនភាគីថា សាក្សីបម្រុងថ្ងៃនេះ 2-TCW-1042 នោះគឺទំនងជាពេលវេលាមិនអាចអំណោយផលឲ្យអង្គជំនុំជម្រះស្តាប់សក្ខីកម្មរបស់គាត់បានទេ។ ហើយអង្គជំនុំជម្រះបានជម្រាបជូនដំណឹងទៅគាត់ហើយថា ឲ្យគាត់ត្រឡប់ទៅវិញសិនចុះ ហើយរង់ចាំអង្គជំនុំជម្រះកំណត់

កាលបរិច្ឆេទសម្រាប់សួរ ស្តាប់សក្ខីកម្មគាត់នៅពេលក្រោយ អង្គជំនុំជម្រះនឹងជូនដំណឹងនៅពេលក្រោយ។ ហេតុដូច្នេះគឺច្បាស់លាស់ គឺអង្គជំនុំជម្រះមិនធ្វើសវនាការផ្តើមស្តាប់សក្ខីកម្មសាក្សី 2-TCW-1042 នៅថ្ងៃនេះទេ។ ហើយប្រសិនបើមិនទាន់ចាត់ការជម្រាបជូនដំណឹងទេ សូមមន្ត្រីក្រឡាបញ្ជី ឬក៏មន្ត្រីនៃរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកអង្គភាពគាំពារសាក្សី និងអ្នកជំនាញជម្រាបជូនដំណឹងទៅគាត់ដើម្បីឲ្យគាត់ត្រឡប់ទៅវិញចុះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមសួរបន្តទៅទៀត បើសិនណាជាអនុញ្ញាត។ តើសេចក្តីសម្រេចបានធ្វើ ឬនៅពាក់ព័ន្ធទៅនឹងសៀវភៅបញ្ជីដែលយើងបានពិភាក្សាគ្នានោះលោកប្រធាន? គឺសៀវភៅពណ៌លឿងពណ៌ទឹកក្រូចស-២១។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៤:១៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែល -- <ទំនងជាសំណើសុំរបស់ខ្ញុំក្លាយជាឥតបានការហើយ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<មិនអញ្ចឹងទេ យើងកំពុងតែពិនិត្យមើល។>

**លោក វ៉ិចទ័រ កូប៉េ៖**

<បាទ។>

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី ខ្ញុំសួរលោកថាតើលោកមានដឹងដែរឬទេ ថាតើរបបអាហារជាអង្ករដែលគេកំណត់សម្រាប់មនុស្សម្នាក់ៗដែរឬទេ នៅពេលនោះ? ហើយខ្ញុំសួរលោក ថាតើគេកំណត់សម្រាប់ម្នាក់ៗហ្នឹង ត្រូវចែកឲ្យប៉ុន្មានដែរ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**2-TCW-971៖**

**ឆ៖** បាទ ការកំណត់របបអង្ករហូបគឺមួយពេល មួយនាក់ -- ក្នុងមួយពេល មួយនាក់ មួយកំប៉ុង មួយពេល មួយនាក់ មួយកំប៉ុង។

[១៥:១៥:៣៣]

**សៈ** ហើយរបបអាហារហ្នឹង គឺអនុវត្តនៅភូមិភាគពាយ័ព្យក៏អ៊ីចឹង នៅខេត្តតាកែវ ស្រុកត្រាំកក់ហ្នឹង ក៏អនុវត្តអ៊ីចឹងដែរ បានន័យថា មួយកំប៉ុង មួយពេលដូចគ្នា ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ មួយកំប៉ុង មួយពេលដូចគ្នា។ ហ្នឹងដែលតាមខ្ញុំដឹង កន្លែងខ្ញុំរស់នៅ។

**សៈ** ហើយនៅពេលដែលលោកធ្វើការនៅត្រាំកក់ហ្នឹង តើលោកមានទទួលបន្ទុកក្នុងការធ្វើយ៉ាងណា ឲ្យគេគោរព ពេលដែលបែងចែករបបអាហារហ្នឹង គោរពតាមក្រឹត្យក្រមហ្នឹង ត្រូវតែចែកឲ្យមួយពេល មួយកំប៉ុងទាំងអស់គ្នាហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** អាហ្នឹង វាមានអ្នកទទួលខុសត្រូវទៅតាមកន្លែងមួយ កន្លែងៗទៀត កន្លែងសហករណ៍ កន្លែងសាខារបស់មន្ទីរ ឬក៏អង្គភាពហ្នឹង វាមានជាក្រុមៗគេទៀត។ មានមេក្រុមគេ អ្នកទទួលមើលខុសត្រូវ។

**សៈ** តើមេក្រុមដែលលោកនិយាយហ្នឹង ទាំងអស់ហ្នឹង គាត់រាយការណ៍ទៅអ្នកណាដែរ?

**ឆ៖** បាទ គាត់ប្រាប់មកខាងយើងមក ប្រាប់មកខាងខ្ញុំអ៊ីចឹង ខ្ញុំក៏រាយបន្តជូនទៅឲ្យប្រធាន។

**សៈ** តើលោកមានធ្លាប់ជួបប្រទះរបាយការណ៍ ដែលនៅក្នុងរបាយការណ៍ហ្នឹងសរសេរថា ខ្វះស្បៀងអាហារដែរឬទេ? ខ្វះអាហារហូបចុកដែរឬទេ?

**ឆ៖** មានចុងឆ្នាំ ចុងឆ្នាំ អង្ករជួនណា វាមិនបានគ្រប់ដូចដើមឆ្នាំ ឬក៏ពាក់កណ្ដាលឆ្នាំ ទៅចុងឆ្នាំទៅ អង្ករខ្សោយ យើង គេប្រាប់មក ក៏យើងឲ្យកាត់បន្ថយតាមហ្នឹង ដោយសារស្បៀងវាខ្វះអ៊ីចឹងទៅ។

**សៈ** តើលោកដឹងដែរឬទេ ថាតើពេលដែលខ្វះអាហារហ្នឹងនៅឆ្នាំណាដែរ? ហើយនៅកន្លែងណាដែរ? លោកនិយាយហ្នឹង និយាយនៅត្រាំកក់ ឬក៏នៅភូមិភាគពាយ័ព្យទេ?

[១៥:១៨:១៧]

**ឆ៖** ភូមិភាគពាយ័ព្យមិនមានបញ្ហាអីទេ ហ្នឹងដែលខ្ញុំធ្លាប់ជួបប្រទះ នៅនឹងត្រាំកក់។ ថាខ្វះហើយយើងត្រូវតែបន្ថយ ដូចថា១០ យើងដាក់តែប្រាំបី ឧទាហរណ៍។

**សៈ** ដូច្នេះអ្វីដែលលោកជួបប្រទះផ្ទាល់ បើតាមលោកហ្នឹង គឺស្ថានភាពរបបអាហារហ្នឹង គឺនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ត្រាំកក់ហ្នឹង ប្រសើរជាងនៅភូមិភាគពាយ័ព្យ ឬក៏ស្ថានភាពរបបហូបចុកហ្នឹង នៅពាយ័ព្យប្រសើរជាងនៅត្រាំកក់ <ឬក៏ដូចតែគ្នាទេ>?

**ឆ៖** កន្លែងដែលខ្ញុំធ្វើការនៅនឹងពាយ័ព្យហ្នឹង ឃើញនៅតែពាយ័ព្យហ្នឹង វាសម្បូរជាង គ្រប់គ្រាន់ជាង។ ហ្នឹងចំពោះអង្គភាពដែលខ្ញុំបានចូលទៅដល់ តែកន្លែងផ្សេង ខ្ញុំភ្លាប់មិនដែរ។

**ស៖** អ៊ីចឹងបើខ្ញុំសង្ខេប កន្លែងដែលលោកធ្វើការនៅភូមិភាគពាយ័ព្យហ្នឹង លោកឃើញថាអាហារហូបចុកហ្នឹងគ្រប់គ្រាន់ ក៏ប៉ុន្តែកាលដែលលោកធ្វើការនៅត្រាំកក់ហ្នឹង គឺមានគេរាយការណ៍ប្រាប់មកលោក ពេលដែលខ្វះអាហារហូបចុក។ តើខ្ញុំយល់អ៊ីចឹង ត្រឹមត្រូវទេ? ហ្នឹងពិតជាអ្វីដែលលោកបាននិយាយអំមិញ មែនទេ?

**ឆ៖** បាទៗ។

**ស៖** លោកបាននិយាយថា លោកបានទទួលរបាយការណ៍ពីមេក្រុម។ អ៊ីចឹងខ្ញុំចង់ដឹងថា លោកខាងលោកនេះ តើលោកមានចេញសេចក្តីណែនាំទៅមេក្រុម ឬក៏ប្រធានសហករណ៍ហ្នឹងទាក់ទងនឹងបរិមាណអង្ករដែលត្រូវចែកឲ្យគេដែរឬទេ? ឬក៏រូបលោកផ្ទាល់នេះ មានទទួលបញ្ជាមកប្រាប់ថា ឆ្នាំនេះត្រូវតែផលិតស្រូវ ឬក៏ដាំបង្កបង្កើនផលស្រូវនោះ ឲ្យបានកម្រិតណាមួយដែរឬទេ?

[១៥:២០:៤៩]

**ឆ៖** បាទ ការប្រជុំប្រចាំខែ គេលើកកម្ពស់ ជំរុញការបង្កបង្កើនផល លើកផលស្រូវ។ គេប្រជុំអ៊ីចឹងទៅ គេប្រាប់ទៅតាមឃុំ តាមសហករណ៍ហ្នឹងថា ឲ្យយកចិត្តទុកដាក់ខិតខំផលិតស្រូវឲ្យបានល្អមានគុណភាព មានបរិមាណច្រើនជាងឆ្នាំបច្ចុប្បន្នអ៊ីចឹងទៅ។ គេលើកឡើងរាល់តែពេលប្រជុំអ៊ីចឹង។

**ស៖** តើបរិមាណដែលគេកំណត់ហ្នឹង គឺគេកំណត់ដែរឬទេ? ខ្ញុំនិយាយពីការបង្កបង្កើនផល ចង់និយាយថាក្នុង១ហិកតាហ្នឹង គេមានកំណត់ប្រាប់ថាក្នុង១ហិកតាត្រូវតែដាំឲ្យបានផលស្រូវហ្នឹងប៉ុន្មានតោនដែរទេ?

**ឆ៖** គេកំណត់ ប៉ុន្តែកន្លែងខ្លះធ្វើបាន កន្លែងខ្លះធ្វើមិនបាន។ គេលើកគោលការណ៍គេ១០ -- ៣តោនមួយហាត់ -- ១ហិកតា៣តោន ១ហិកតា៣តោន ប៉ុន្តែមិនបានជាទូទៅទេ កន្លែងខ្លះអត់បានទេ។ អ៊ីចឹងហើយបានជាការហូបចុក បាទសូមបន្ថែម ការហូបចុកវាទៅតាមសហករណ៍ ទៅតាមឃុំ តាមកន្លែង។ កន្លែងណាដែលគេធ្វើបាន គឺហូបចុកធូរធារ។ កន្លែងណាដែលធ្វើបានតិច អាហ្នឹងគឺៗមានការថតចុះក្នុងការហូបចុកដែរ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** តើលោកមានរាយការណ៍អំពីបរិមាណស្រូវដែលដាំ បង្កបង្កើនផលបានហ្នឹងតាមការកំណត់ដែរឬទេ? ហើយបើករណីហ្នឹង លោករាយការណ៍ទៅអ្នកណាដែរ បើសិនជាលោករាយការណ៍ពីផែនការស្រូវដែលត្រូវតែដាំឲ្យបានក្នុង១ហិកតាហ្នឹង?

[១៥:២២:៥៩]

**ឆៈ** លទ្ធផល ប្រមូលផលប្រចាំឆ្នាំ ខាងឃុំគេ ខាងសហករណ៍គេ គេរាយការណ៍មកឲ្យស្រុក។

**សៈ** ឥឡូវខ្ញុំសូមបង្ហាញឯកសារមួយជូនលោក គឺជាឯកសារ E3/8418។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារនេះទៅសាក្សី ហើយនិងបញ្ចាំងនៅលើអេក្រង់ផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយមេធាវីប្រឹក្សាសាក្សី ជួយផ្តល់ឯកសារដែលរៀបចំហ្នឹងជូនទៅសាក្សីពិនិត្យតាមសំណើសុំរបស់លោកចៅក្រមណ៎ា។

**លោក ម៉ម រិទ្ធា៖**

បាទ លោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**សៈ** ខ្ញុំ<មិន>ដឹងថាឯកសារហ្នឹងអាចបញ្ចាំងនៅលើអេក្រង់បានដែរឬទេ។ ខ្ញុំសូមអានការពិពណ៌នាឯកសារហ្នឹង គឺជាឯកសារដែលមានចំណុចចង្អុលបង្ហាញពីបរិមាណ<ស្រូវផលិតបាន>ពេលរដូវប្រាំង ដែលទទួលបាន ឬក៏ដែលគេផ្តល់ឲ្យមកពី<ឃុំចំនួនប្រាំបួនក្នុង>ស្រុកត្រាំកក់ នៅថ្ងៃទី១៩ មេសា ឆ្នាំ១៩៧៧។ អ៊ីចឹងយើងឃើញមាន<១.២៣១>បាវ ដែលយក<ទៅ>រោងកិនស្រូវក្បាល<ពោធិ៍> ហើយមានបង្អួលបង្ហាញពីស្រូវដែល<ប្រើប្រាស់អស់រវាងថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៧> គឺមាន៤៥៧បាវ។ លោកសាក្សី លោកធ្លាប់ឃើញឯកសារបែបនេះដែរឬទេ ឬក៏ប្រហាក់ប្រហែលគ្នានេះ អង្កាល់ដែលលោកធ្វើការនៅមន្ទីរពាណិជ្ជកម្មនោះ លោកធ្លាប់ជួបប្រទះឯកសារបែបហ្នឹងទេ?

[១៥:២៥:៣២]

**2-TCW-971៖**

**ឆ៖** បាទ អត់ទេ ខ្ញុំមិនដែលឃើញទេ ពីព្រោះអីកាលណាគេឲ្យមានរបាយការណ៍អ៊ីចឹង គេជូនទៅមេធំគេ គឺចៅហ្វាយស្រុក អ៊្ហា! សូមទោស គណៈស្រុក។ ខ្ញុំបានជម្រាបជូនលោកមេធាវីខាងដើមថា ការចាត់ចែងនៅនឹងពាណិជ្ជ ភាគច្រើន គឺអំបិល ហើយនិងក្រណាត់ខ្លះ អង្ករអីមិនសូវមានទេ។

**ស៖** តើលោកបានអានឯកសារហ្នឹងហើយឬនៅ? តើបរិមាណសរុប<នៃចំនួនអង្ករ>ដែលបានប្រើប្រាស់មានន័យថា យ៉ាងម៉េចដែរ? ហើយចំនួនបាវអង្ករនោះ<គេប្រើដើម្បីធ្វើអ្វី តើ>គេមានការដោះដូរ ឬក៏យ៉ាងម៉េច? ចង់និយាយថាដោះដូរគ្នា ផ្ញើទៅតំបន់អ៊ីចឹងទៅ ហើយទៅដូរយកទំនិញណាមកផ្សេងវិញ ឬក៏យ៉ាងម៉េច? អង្ករដែលចំណាយហ្នឹងចំនួនបាវដែលចំណាយហ្នឹង គឺក្នុងគោលបំណងអ្វីដែរ ជាការដោះដូរជាមួយអ្វីដែរមកវិញ?

**ឆ៖** ទេ ខ្ញុំម៉េចៗនឹងយល់ អានេះគ្រាន់ដូចចំនួនស្រូវដែលគេធ្វើបាន។ ហើយគេដូរណា ដូចមិនមានដូរទេ។ ចំនួនអង្ករចំណាយគិតពីថ្ងៃទី២៧ ស្ទើ៨ ផ្សេង គិតមកដល់ថ្ងៃទី។ ជារួម៩៥៧បាវ គិតតែអង្ករដែលកិននៅ--។ ឯកសារនេះខ្ញុំបានមើលហើយ បានមើល ប៉ុន្តែមិនដឹងគេបញ្ជូនទៅតាមរយៈណាឲ្យទៅពីណា ខ្ញុំអត់ដឹងផង។ ដឹងពីណាអ្នកបញ្ជូនឲ្យទៅខាងណា។

**ស៖** មាននិយាយពីរោងម៉ាស៊ីនកិនស្រូវមួយនៅក្បាលពោធិ៍ តើលោកមានដឹងដែរឬទេ ថាតើនៅកន្លែងនុ៎ង មានរោងម៉ាស៊ីនមួយនៅក្បាលពោធិ៍ហ្នឹង? អ៊ីចឹងខ្ញុំសួរលោកថា រោងម៉ាស៊ីនកិនស្រូវហ្នឹងជារោងម៉ាស៊ីនកិនស្រូវរបស់សហករណ៍ ឬរបស់ស្រុក ឬរបស់តំបន់?

[១៥:២៨:២៣]

**ឆ៖** ទេ រោងម៉ាស៊ីនកិនស្រូវហ្នឹង ខ្ញុំភ្លាប់មិនបានច្បាស់ទេ មិនដឹងជារបស់ខាងណាគ្រប់គ្រងទេ ប៉ុន្តែម៉ាស៊ីនហ្នឹងបើតាម ឮសូរប្រជាពលរដ្ឋនិយាយ គេថា ម៉ាស៊ីនហ្នឹងម៉ាស៊ីនធំ។ បើអ៊ីចឹងប្រហែលជារបស់តំបន់ តាមមើល។ អានេះក្នុងការសន្និដ្ឋាន ស្មានៗដែរ បើស្រុកមិនអាចទៅកាន់កាប់ដល់ហ្នឹងទេ។

**ស៖** ឥឡូវខ្ញុំសូមបង្ហាញឯកសារមួយទៀត គឺឯកសារ E3/2441, ERN ជាភាសាខ្មែរគឺ <00270958> ទៅដល់59, ជាអង់គ្លេសគឺ 00369485 ដល់86, ជាភាសាបារាំងគឺ 00611761 ទៅដល់62។ លោកសាក្សី លោកឃើញឯកសារនុ៎ងហើយឬនៅ?

**ឆ៖** កំពុងទៅរកបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះលើអេក្រង់ផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយផ្នែកខាងសោតទស្សន៍ចាក់បង្ហាញឯកសារតាមសំណើសុំរបស់លោកចៅក្រម លើអេក្រង់ទូរទស្សន៍។

*(ការបង្ហាញឯកសារជារូបភាព)*

[១៥:៣០:២៦]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** អ៊ីចឹងសូមបង្ហាញកថាខណ្ឌចុងក្រោយនៃទំព័រហ្នឹង។ កថាខណ្ឌចុងក្រោយហ្នឹង គឺមានខ្លឹមសារដូចតទៅនេះ។ ដំឡើងបន្តិច គឺកថាខណ្ឌចុងក្រោយគេនៃទំព័រមុននឹងមួយទំព័រ មានខ្លឹមសារដូចតទៅនេះ៖ "នៅពេលដែលមិនមានដំឡូងមីនៅមូលដ្ឋានហ្នឹង គឺស្ថានភាពអាហារកាន់តែធ្លាក់ចុះ អ៊ីចឹងយើងមានតែបួនកំប៉ុងក្នុង១ថ្ងៃទេ សម្រាប់មនុស្ស១០នាក់ សម្រាប់ទាំងព្រឹកទាំងល្ងាច។ ដូច្នេះវាយ៉ាប់ខ្លាំងមែនទែន។ អ៊ីចឹងខ្ញុំសូមជម្រាបជូនដល់អង្គការឲ្យដឹង។" របាយការណ៍នេះចុះនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៧។ លោកសាក្សីតើខ្លឹមសារដែលខ្ញុំអាននេះ វាត្រូវនឹងរបាយការណ៍ដែលលោកធ្លាប់បានទទួលខ្លឹមសារដូចគ្នានឹងរបាយការណ៍ដែលលោកធ្លាប់បានទទួល នៅពេលដែលលោកធ្វើការនៅមន្ទីរពាណិជ្ជ-កម្មស្រុកដែរឬទេ?

**2-TCW-971៖**

**ឆ៖** ក្នុងពាណិជ្ជកម្មស្រុកនេះ មិនដែលបានទទួលរបាយការណ៍អស់នេះទេ ខ្ញុំបានជម្រាបជូនលោកខាង លោកមេធាវីថា គេរាយការណ៍ទៅឲ្យស្រុក។ អ៊ីចឹងរបាយការណ៍អស់នេះ គេអត់ដែលទម្លាក់មកដល់ឲ្យមក អ៎! គេមិនដែលរាយការណ៍មកឲ្យកន្លែងខាងខ្ញុំមើលកាន់កាប់ទេ មិនដែលបានទទួលទេ។

**ស៖** លោកអាចអាន ថាបើមើលទៅនេះ បរិមាណអង្ករដែលចែកសម្រាប់មនុស្សម្នាក់ និងសម្រាប់មួយថ្ងៃហ្នឹង គឺវាខុសពីអ្វីដែលលោកបានលើកឡើងហើយ ដែលថាម្នាក់បាន១កំប៉ុង<សម្រាប់មនុស្សម្នាក់>។ អ៊ីចឹងលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាអ្នកណាជាអ្នកចុះហត្ថលេខាលើរបាយការណ៍នេះ? លោកឃើញហត្ថលេខានៅលើឯកសារហ្នឹងទេ?

[១៥:៣២:៤៦]

**ឆ៖** បាទ អត់ស្គាល់មនុស្សទៀត អត់ស្គាល់មនុស្សទេ។ ដូចស្អី សើន ស្អីឯណាហ្នឹង។ ខ្ញុំអត់

ស្គាល់ទេ មិនដឹង សើន ណា។

**ស៖** ឥឡូវខ្ញុំសូមបង្ហាញឯកសារចុងក្រោយគឺឯកសារ E3/2109។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះ បញ្ចាំងឯកសារនេះនៅលើអេក្រង់ លោកប្រធាន។ ERN ជាភាសាបារាំងគឺ<00290272> <ដល់74> ជាភាសាអង់គ្លេសគឺ <00276555> ដល់56, ជាភាសាខ្មែរគឺ 00068014 ទៅដល់016។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

*(ការបង្ហាញឯកសារជារូបភាព)*

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** កថាខណ្ឌទី១នៃឯកសារនេះ គឺមើលទៅទាក់ទងទៅនឹងអ្នកទោស។ រាយការណ៍ថាមានអ្នកទោស<៧៥>នាក់ <មួយចំនួនត្រូវបោសសម្អាត ហើយប្រាំមួយនាក់>ស្លាប់ដោយជំងឺ<>។ លោក<បានប្រាប់យើងថា លោក>ឮអំពីក្រាំងតាចាន់ ប៉ុន្តែលោកមិនដែលទៅទីនោះទេ។ តើលោកមានធ្លាប់បានទទួលរបាយការណ៍ ឬក៏ព័ត៌មានស្តីពីអ្នកទោសនៅក្រាំងតាចាន់ដែរឬទេ?

2-TCW-971៖

**ឆ៖** ខ្ញុំគ្មានតួនាទីនឹងទទួលរបាយការណ៍អីអស់នោះផង។ ខ្ញុំមិនដែលបានពាក់ព័ន្ធអីជាមួយរឿងអស់ហ្នឹងទេ។

[១៥:៣៥:២៣]

**ស៖** ឥឡូវសូមលោកអានកថាខណ្ឌទី២ ដែលមានចំណងជើងថា "សេដ្ឋកិច្ចចំណាយ"។ មានសរសេរដូចតទៅនេះ៖ "សេដ្ឋកិច្ចចំណាយ រួមមន្ទីរទាំងមូល ចំណាយអង្ករអស់៨៦០កំប៉ុង គិតជាស្រូវហ្នឹងវាអស់៣៤ប៉ោត អំបិលហ្នឹងអស់៨០កំប៉ុង។ ចំណាយស្រូវក្នុងឃុំសំរោងហ្នឹង ៩៥បាវ ហើយ<ស្រូវ>១១បាវ<> ដំឡូងមី<កន្លះបាវ> នៅភូមិទទឹងថ្ងៃ។ យើងឧបត្ថម្ភទៅខាង១០៦ អស់ស្រូវពូជ២១បាវ<និងពូជដំឡូងបីរទេះសេះ>។" <ដូច្នេះតើមន្ទីរស្រុកត្រាំកក់គ្រប់គ្រង>ការចំណាយ<>នៅក្នុងស្រុកហ្នឹង វាយ៉ាងម៉េច លោកសាក្សី?

**ឆ៖** ខ្ញុំមិនបានដឹងរឿងអស់នេះ លោកប្រធាន។ អារឿងអីចំណាយស្រូវអង្ករហ្នឹង ខ្ញុំអត់បានដឹងផ្ញើចេញផ្ញើចូលអីទេ។ ខ្ញុំបានជម្រាបថា ខ្ញុំនៅពាណិជ្ជអង្គរកាហ្នឹង គឺមានតែអំបិល ហើយនិងក្រណាត់

ត្បាញអីនាយអាយ ដែលមានរោងតម្បាញនៅជិតហ្នឹង ហើយនិងក្រណាត់សល់ខ្លះៗ។ ឯរឿងស្បៀងអាហារ ខ្ញុំមិនបានទទួលដឹងឮទេ មិនដឹងជាគេបញ្ជូនទៅឯណាទៅឯណី។

**ស៖** តើលោកស្គាល់អក្សរ<សរសេរដោយដៃ>ហ្នឹងដែរឬទេ? អ្នកណាអ្នកសរសេរអក្សរហ្នឹង សរសេររបាយ-រណ៍ហ្នឹង លោកស្គាល់អ្នកសរសេរទេ?

**ឆ៖** បាទ អត់ទេ អត់ស្គាល់ទេ។

**ស៖** តើលោកដឹងដែរឬទេ ថាតើនៅក្នុងស្រុកត្រាំកក់ហ្នឹងមានប្រជាជនខ្លះហ្នឹង ត្រូវបានចាប់ខ្លួនដោយពីបទលួចស្បៀងអាហារហូប ដោយហេតុតែពួកគាត់ឃ្លានខ្លាំងពេក តើមានករណីហ្នឹងទេ?

[១៥:៣៨:០៦]

**ឆ៖** ការចាប់ការចង ខ្ញុំអត់បានដឹងរឿងទេ ខ្ញុំនៅតែកន្លែង អាហ្នឹងវាកើតមាននៅក្នុងសហករណ៍គេឯណាណោះ ខ្ញុំមិនដែលបានទទួលព័ត៌មានទេ។ តែកាលណាគេធ្វើសកម្មភាពអស់នេះ ហ្នឹងជារឿងរបស់គេមួយ ដឹងគេបញ្ជូនទៅតាមរយៈណាទេ។

**ស៖** តើខ្សែបណ្ដោយ ចង់និយាយថាឋានានុក្រមហ្នឹង ខ្សែរយៈទាក់ទងហ្នឹង គេធ្វើយ៉ាងម៉េចដែរ អ្នកណារាយការណ៍ទៅអ្នកណា អ្នកណាបញ្ជាមកអ្នកណាដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** មិនយល់ទេ មិនដឹងបញ្ជាក់យ៉ាងម៉េច បើរចនាសម្ព័ន្ធការងារគេ កាលហ្នឹងវាគ្មានរបៀបរៀបរយអីពិតប្រាកដ មិនដឹងគេ ឃុំគេរាយឲ្យស្រុកអីចឹងទៅ ស្រុកគេរាយទៅឲ្យខេត្ត ឲ្យតំបន់គេទៅ។ ឯខាងខ្ញុំនេះតួនាទីនៅតែកន្លែងហ្នឹង ចាំតែរបស់អីដែលគេមកហ្នឹង គឺចាត់ចែងចែកចាយទៅតែប៉ុណ្ណឹង វាអត់មានតួនាទីទទួលរបាយការណ៍អីធំដុំផងហ្នឹង។ ដូចជាជំនួយការមួយតូចនៅក្នុងរង្វង់កន្លែង ចាំមើលថែបាត់បង់អីហ្នឹងឯង។

**ស៖** លោកសាក្សី តើលោកធ្លាប់ទៅមន្ទីរតំបន់ដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលចូលទេ។ មន្ទីរតំបន់ហ្នឹង គេនៅឯតាកែវឯណោះ ហើយខ្ញុំនៅឯអង្គរកាណោះ មិនដែលបានចូលទេ។

**ស៖** តើលោកដឹងថា មន្ទីរតំបន់ហ្នឹងនៅឯណាដែរឬទេ នៅខេត្តកែវហ្នឹង?

**ឆ៖** ខ្ញុំ តាមខ្ញុំដឹងត្រង់ហ្នឹង កាលហ្នឹងគឺនៅកន្លែងអូតែលខេត្ត កាលដែលខ្ញុំចេញមកបាត់ដំបង។

[១៥:៤០:៤៩]

**ស៖** ដោយសារពេលវេលាខ្លី ខ្ញុំមិនមានសំណួរអីសួរទៀតទេ។ ខ្ញុំសល់តែសំណួរចុងក្រោយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មួយ។ ខ្ញុំសួរលោកថា តើលោកធ្លាប់ដឹងអំពីជំនួយជាស្បៀងអាហារដែលគេបញ្ជូនទៅស្រុកត្រាំកក់ដែរឬទេ? តើរូបលោកផ្ទាល់នេះ លោកមាននៅចាំដែរឬទេ ថាស្រុកត្រាំកក់នេះធ្លាប់បានទទួលជំនួយ<អង្ករ>ពីប្រទេសចិន <ឬមួយក៏ប្រទេសផ្សេងៗទៀត? ឬក៏តើមានជំនួយណាមួយផ្តល់ឲ្យប្រជាជននៅស្រុកត្រាំកក់ទេ>?

**ឆ៖** ខ្ញុំអត់បានដឹងថា យកពីណាទេ។ បើគេឲ្យមក ទៅតាមរយៈថ្នាក់ធំ ចុះមកថ្នាក់ទាបមក គេមិនដែលយកមកដល់ថ្នាក់ក្រោមទេ។ ហើយដល់ហើយថ្នាក់ធំហ្នឹង គេដឹកមកឲ្យចែកចាយទៅ ដូចថាខ្ញុំនៅកន្លែងអង្គរកា ក្រណាត់ គេដឹកយកមកឲ្យពីតាកែវ ឲ្យប៉ុន្មាន យើងចាត់ចែង ចែកចាយប៉ុណ្ណឹង។ តែដឹងជំនួយពីណា ខ្ញុំអត់បានដឹង ដឹងគេយកពីណា។

**ស៖** តើលោកដឹងដែរឬទេ ថាតើមជ្ឈិមធ្លាប់បញ្ជូន ឬក៏ផ្ញើស្រូវអង្ករនោះ ទៅស្រុកត្រាំកក់ដែរឬទេ <>ស្រូវអង្ករទាំងអស់ហ្នឹង ជាជំនួយរបស់<ប្រទេសផ្សេងៗ ជាពិសេស>ប្រទេសចិន? លោកដឹងដែរឬទេ ធ្លាប់ដឹងឮដែរឬទេ អំពីរឿងហ្នឹង?

**ឆ៖** ត្រង់ហ្នឹងខ្ញុំអត់យល់។ ខ្ញុំបានជម្រាបហើយថា អារឿងបញ្ហាស្រូវរឿងអង្ករអីហ្នឹង ខ្ញុំអត់បានដឹងឮរឿងទំនាក់ទំនងបញ្ជូនពីនោះអីទេ។ មិនដឹងគេឲ្យពីណាមកណេី ខ្ញុំបានជម្រាបខាងលើរួចហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកសាក្សី ខ្ញុំសូមអរគុណ ខ្ញុំអស់សំណួរហើយ ហើយដោយសារពេលវេលាដែលខ្ញុំមានហ្នឹងអស់ត្រឹមប៉ុណ្ណឹងហើយ។ សូមអរគុណលោកប្រធាន។

[១៥:៤៣:២៣]

**ប្រធានអង្គជំនុំ៖**

បាទ សូមប្រគល់វេទិកាជូនទៅមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្រុមមេធាវី ខៀវ សំផន អត់មានសំណួរទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះអរគុណលោកសាក្សី។ សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនាពេលនេះ ដល់ពេលទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនូវរឿងក្តីនេះ។ ហើយនាពេលនេះ លោកអាចសម្រាកបានហើយ សូម

លោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចំរើន។ ហើយអង្គជំនុំជម្រះក៏ សូមអរគុណ--

**2-TCW-971៖**

បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះក៏សូមអរគុណលោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី នាពេលនេះលោកអាចសម្រាកបានហើយ។

[១៥:៤៤:០៦]

**លោក ម៉ម រិទ្ធា៖**

បាទ អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណចំពោះបុគ្គលិកគាំពារសាក្សី និងអ្នកជំនាញ និងអ្នកទាំងឡាយដែលជួយរៀបចំប្រព័ន្ធសោតទស្សន៍សម្រួលដល់កិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មថ្ងៃនេះ ហើយនាពេលនេះអស់លោក លោកស្រី អាចសម្រាកបានហើយ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះ ទី១ គឺសម្រេចចេញសេចក្ដីសម្រេចផ្ទាល់មាត់ លើសំណើសុំរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅសាក្សីបន្ថែមចំនួនពីររូប ពាក់ព័ន្ធនឹងវគ្គសវនាការស្ដីពីតួនាទីរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះទទួលបានសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឲ្យស្ដាប់សក្ខីកម្មសាក្សីចំនួនពីររូប (ឯកសារ E3/10627 និង E3/10751) ពាក់ព័ន្ធនឹងវគ្គសវនាការស្ដីពីតួនាទីរបស់ជនជាប់ចោទ ដែលបានដាក់កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ (ឯកសារ E452)។ មេធាវីការពារក្ដី ខៀវ សំផន បានជំទាស់ទៅនឹងការស្ដាប់សក្ខីកម្មសាក្សីថ្មីនេះ ដោយសារតែសំណើនេះធ្វើឡើងយឺតពេល។ មេធាវីការពារក្ដី នួន ជា បានជំទាស់ទៅនឹងសំណើនេះ ប៉ុន្តែបានលើកឡើងថា ប្រសិនបើអង្គជំនុំជម្រះយល់ព្រមតាមសំណើនេះនោះ ឯកសារបន្ថែមទៀត ខ្លួនត្រូវបាន គួរត្រូវបានទទួលយកជាភស្តុតាង ហើយដើម្បីយក អាចយកមកប្រើប្រាស់នៅក្នុងការសួរដេញដោល។

អង្គជំនុំយល់ថា សំណើនេះត្រូវបានដាក់យឺតពេល។ ហើយបន្ថែមពីលើនេះទៀត អង្គជំនុំជម្រះយល់ឃើញថា វាមិនមែនជាប្រយោជន៍នៃយុត្តិធម៌ទេ ដែលតម្រូវឲ្យអង្គជំនុំជម្រះស្ដាប់សក្ខីកម្មសាក្សី

ទាំងពីររូបនេះ។ ហេតុដូច្នេះអង្គជំនុំជម្រះច្រានចោលសំណើសុំនេះ។ សំអាងហេតុពេញលេញនៃសេចក្តីសម្រេចនេះនឹងចេញក្នុងពេលសមស្របឆាប់ៗខាងមុខនេះ។

[១៥:៤៥:៥៩]

បញ្ហាមួយទៀត អង្គជំនុំជម្រះបានទទួលសំណើសុំរបស់សាក្សី 2-TCW-1042 តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញថា សាក្សី 2-TCW-1042 មានបំណងស្នើសុំប្រើប្រាស់កុំព្យូទ័រយួរដៃរបស់គាត់ ក្នុងខណៈពេលដែលគាត់ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាថ្ងៃខាងមុខ។ ហើយអង្គជំនុំជម្រះសូមសួរទៅភាគីទាំងអស់ថា តើសំណើរបស់សាក្សីនេះ របស់សាក្សី តើភាគីមានភាគីណាជំទាស់ដែរឬទេ?

**លោក ឌេល លីសាក់៖**

យើងខ្ញុំមិនមានការជំទាស់ទេ ពាក់ព័ន្ធទៅនឹងទំហំនៃឯកសារដែលភាគីត្រូវសួរទៅលើរូបគាត់។ ដូច្នេះយើងខ្ញុំយល់ស្របទៅនឹងសំណើសុំរបស់គាត់នេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអ្នកនៅស្ងៀម ក៏ចាត់ទុកថាយល់ស្របហើយ។

បាទ ហើយចុងក្រោយចំពោះសំណើរបស់លោកមេធាវី វ៉ិចទ័រ កូប៉េ ពីការទទួលយកនូវសៀវភៅកំណត់ត្រា--

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយលោកប្រធាន យើងខ្ញុំយល់ស្របតាមសំណើសុំ បើសិនជាសាក្សីរូបនេះគាត់មានកុំព្យូទ័រ *ឡេបថប* នេះយកមកជាមួយ។

[១៥:៤៧:៤៨]

**លោក គង់ សំអុន៖**

ខ្ញុំចង់កត់សម្គាល់អ៊ីចេះលោកប្រធាន បើសិនជាប្រើប្រាស់កុំព្យូទ័រ សំដៅទៅលើទិន្នន័យដែលទាក់ទងនឹងបញ្ជីនោះ វាមិនមានជាបញ្ហាអីទេ។ គ្រាន់តែជាការកត់សម្គាល់របស់ខ្ញុំ ក្រែងថាបើថាកុំព្យូទ័រហ្នឹងមានឯក -- ព្រោះកុំព្យូទ័រអាចផ្ទុកឯកសារបានច្រើនយ៉ាង អ៊ីចឹងបើថាវាមិន ចំណុចណាដែលវាមិនអាចជាចំណុចត្រូវប្រើកុំព្យូទ័រ អាហ្នឹងមិនគួរប្រើទេ ទៅតាមភាពជាក់លាក់នៃសំណួរផងដែរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតាមសំណើនេះ គឺបំណាង ហើយយើងមិនដែរ ព្រោះវាសំណើខ្លី ហើយតាមយើងយល់ គឺគាត់ដាក់ហ្នឹង គឺបំណាងជាក់លាក់ដើម្បីមានសមត្ថភាព និងលទ្ធភាពពេញលេញក្នុងការឆ្លើយតបបានត្រឹមត្រូវទៅនឹងសំណួរដែលពាក់ព័ន្ធ ហើយសំណួរដែលមានកំហិតដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ហើយខ្ញុំគិតថា នឹងមិនមានបញ្ហាអីកើតឡើងទេ ហើយយើងនឹងខិតខំប្រឹងប្រែងគ្រប់គ្រងកិច្ចដំណើរការសវនាការក្នុងករណីពិសេស សាក្សីដ៏ពិសេសនេះនឹងឲ្យបានល្អ។

បាទ ហើយបញ្ហាមួយទៀត គឺចំពោះសំណើរបស់លោកមេធាវី វ៉ិចទ័រ កូប៉េ អំពីការទទួលយកសៀវភៅកំណត់ត្រាពណ៌លឿង គេហៅថា “ឡុកប៊ុក” ដែលបានទទួលពី ណូវិនស្គី សាស្ត្រាចារ្យ ហេន ណូវិនស្គី នោះ អង្គជំនុំជម្រះបានដាក់បញ្ចូលនៅក្នុងផ្ទាំង ឃ្លាំងផ្ទុកឯកសាររួចហើយ ហើយតែនៅមិនទាន់បានសម្រេចទទួលយកជាឯកសារភស្តុតាងនៅឡើយទេ ហើយអង្គជំនុំជម្រះនឹងជម្រាបជូនដំណឹងទៅភាគីឆាប់ៗខាងមុខនេះ។

[១៥:៤៩:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ចំណុចមួយខ្លីទេ លោកប្រធាន ពាក់ព័ន្ធទៅនឹងបញ្ហានេះ បើអនុញ្ញាត។ ខ្ញុំដឹងច្បាស់ហើយថា អង្គជំនុំជម្រះនឹងទទួលយកសៀវភៅកំណត់ត្រាពណ៌<ទឹកក្រូច>នេះ។ តើមានការទំនាក់ទំនងជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីពិនិត្យមើលទៅលើសៀវភៅពណ៌<ទឹកក្រូច>ដើម *អរីជីណាល* នោះតែម្តង ហើយដើម្បីឲ្យយើងខ្ញុំអាចសួរទៅសាក្សីរូបនេះអំពីសៀវភៅនេះបាន។

**ប្រធានអង្គជំនុំ៖**

មិនមានបញ្ហាអីទេបាទ ជាបំណាងល្អទេ។

បាទ ហើយសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃពុធ ទី០៤ ខែមករា ឆ្នាំ២០១៧ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃពុធ ទី០៤ ខែមករា ឆ្នាំ២០១៧ អង្គជំនុំជម្រះនឹងធ្វើសវនាការដាក់បង្ហាញឯកសារគន្លឹះ ពាក់ព័ន្ធនឹងអង្គហេតុតួនាទីរបស់ជនជាប់ចោទ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥១ នាទី)*